# ការវាយតម្លៃលើគុណភាព និងការប្រើប្រាស់ព័ត៌មាន
# កំណើត មរណភាព និងមូលហេតុនៃការស្លាប់
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

# អារម្ភកថា

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានសារៈសំខាន់សម្រាប់សាធារណៈជនទូទៅ និងអ្នកធ្វើសេចក្តីសម្រេចចិត្ត។ ប្រព័ន្ធនេះត្រូវបានកត់សម្គាល់ឃើញថាបានទទួលការយកចិត្តទុកដាក់តិចតួចពីសហគមន៍សុខភាពពិភពលោក និងសហគមន៍អភិវឌ្ឍន៍។ ក្នុងន័យនេះ ដោយសារតែប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានត្រូវបានប្រើប្រាស់ក្នុងប្រទេសដែលមានការអភិវឌ្ឍន៍ខ្លាំង ដែលកំណើត និងមរណភាពទាំងអស់ត្រូវបានចុះបញ្ជី និងបញ្ជាក់ជាប្រចាំ។ ក្នុងប្រទេសអភិវឌ្ឍន៍ទាំងនេះ ប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋានដែលបានបង្កើតរួចហើយ រដ្ឋាភិបាលអាចត្រួតពិនិត្យ និងប្រើប្រាស់សម្រាប់ការរៀបចំផែនការសង្គម និងសេដ្ឋកិច្ច រួមមានវិស័យសុខាភិបាល អប់រំ ការងារ និងអចលនទ្រព្យ។ រដ្ឋាភិបាលក្នុងប្រទេសដែលមានចំណូលទាប និងមធ្យម មានតម្រូវការដូចគ្នាលើទិន្នន័យសម្រាប់រៀបចំផែនការអភិវឌ្ឍន៍ និងប្រើប្រាស់ធនធានដែលមានកម្រិតរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ជាក់ស្តែងបច្ចុប្បន្នមានសញ្ញាណថ្មីលេចឡើងជាលក្ខណៈសកលក្នុងចំណោមប្រទេសទាំងនេះ និងសហគមន៍អភិវឌ្ឍន៍ ដើម្បីពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។

ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាច្រើន ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានភាពទន់ខ្សោយ ឬក៏គ្មានប្រព័ន្ធនេះ។ ដូច្នេះ គន្លឹះប្រជាសាស្ត្រស្ថិតិមានកូន និងមរណភាព មិនមានជាមូលដ្ឋាន និងមិនគ្របដណ្តប់លើស្ថិតិប្រជាជនភាគច្រើនទេ។ ជំហានដំបូងក្នុងការលើកឡើងពីចំណុចខ្សោយទាំងនេះ គឺត្រូវធ្វើការត្រួតពិនិត្យឡើងវិញពីស្ថានភាពបច្ចុប្បន្ន ជាមួយការកំណត់ពីផ្នែកដែលទាមទារធ្វើឱ្យប្រសើរឡើង និងសកម្មភាពជាអាទិភាព។

គោលបំណងនៃការបង្កើតឱ្យមានការវាយតម្លៃទូលំទូលាយពីប្រព័ន្ធស្ថិតិ និងអត្រានុកូលដ្ឋានរបស់ប្រទេសកម្ពុជា នឹងជួយដល់អាជ្ញាធរដែលទទួលខុសត្រូវឱ្យបានយល់ដឹងច្បាស់ និងស៊ីជម្រៅពីចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងបង្កើតឱ្យមានភស្តុតាងជាមូលដ្ឋានសម្រាប់រៀបចំផែនការសកម្មភាពកែតម្រូវ។

ការវាយតម្លៃស៊ីជម្រៅ ដោយប្រើប្រាស់ឧបករណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក បានពិនិត្យឡើងវិញពីទិដ្ឋភាពចម្បងនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ ការវាយតម្លៃនេះ រួមបញ្ចូលក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋាន ការចុះបញ្ជី លិខិតបញ្ជាក់ និងការអនុវត្តការចុះលេខកូដ ព្រមទាំងការចងក្រង រៀបចំ និងប្រើប្រាស់លទ្ធផលទិន្នន័យ។ ការវាយតម្លៃនេះផ្តោតជាសំខាន់លើកំណើត មរណភាព និងមូលហេតុនៃការស្លាប់ ពីព្រោះនេះជាមូលដ្ឋានក្នុងការណែនាំកម្មវិធីសុខុមាលភាពសាធារណៈ ការត្រួតពិនិត្យលើប្រជាសាស្ត្រ និងការវាស់វែងពីសូចនាករសុខភាពសំខាន់ៗ។

## សេចក្តីថ្លែងអំណរគុណ

ដើម្បីពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ស្ថាប័នផ្សេងៗជាច្រើនបានជួយគាំទ្រក្រសួងមហាផ្ទៃក្នុងការរៀបចំឯកសារនេះឡើង។ ជាពិសេសអ្នករៀបរៀងសូមធ្វើការថ្លែងអំណរគុណដល់សមាជិកដែលមកពីក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងផែនការ អគ្គស្នងការនគរបាលជាតិ អង្គការយូនីសេហ្វ និងអង្គការ URC សម្រាប់ការគាំទ្រ និងចូលរួមក្នុងការវាយតម្លៃ និងការសម្របសម្រួលរបស់ស្ថាប័នពាក់ព័ន្ធក្នុងការគាំទ្រដល់ការសិក្សាស្រាវជ្រាវនេះ។

យើងមានសេចក្តីរីករាយសម្រាប់ការគាំទ្រពីអង្គការ WHO ប្រចាំនៅកម្ពុជា ជាពិសេសបានទទួលការណែនាំពីលោកបណ្ឌិត Rasul Baghirov នៅក្នុងដំណើរការវាយតម្លៃនេះ។ យើងក៏សូមធ្វើការកោតសរសើរចំពោះ លោកបណ្ឌិត Pieter Johannes Van Maaren, WR, និងបុគ្គលិក WHO ប្រចាំនៅកម្ពុជា ដែលបានគាំទ្រយ៉ាងខ្លាំងក្លាបំផុត និងក៏សូមថ្លែងអំណរគុណផងដែរដល់ទីប្រឹក្សាប្រចាំតំបន់ គឺលោកបណ្ឌិត Mark Landry, WHO-WPRO សម្រាប់ការខិតខំប្រឹងប្រែងរបស់លោកក្នុងការជំរុញឱ្យមានរបៀបវារៈស្តីពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានទូទាំងតំបន់។

យើងក៏សូមថ្លែងអំណរគុណផងដែរដល់ Lene Mikkelsen និង Alan Lopez មកពី School of Population Health នៃសាកលវិទ្យាល័យឃ្វីនឡែនដែលបានសហការក្នុងការសរសេរអត្ថបទសម្រាប់ឧបករណ៍វាយតម្លៃរបស់ WHO-UQ នឹងអ្នកជំនាញផ្នែកសុខភាពសាធារណៈដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ផ្នែកសុខភាពសាធារណៈ។ ហើយក៏សូមថ្លែងអំណរគុណ និងសរសើរជាពិសេសដល់ការខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធខាងក្រោមដែលធ្វើឱ្យការវាយតម្លៃលើប្រព័ន្ធ CRVS អាចធ្វើឡើងបានគឺ:

**ក្រសួងមហាផ្ទៃ**

- លោក **ប្រាក់ សំអឿន** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ
- លោក **យឹម សំអុល** អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ
- លោក **ហេង សុផាត** ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន
- លោក **ឡាយ គឹមសាន** មន្ត្រីការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន
- លោក **អាស់ សៅហាក់** មន្ត្រីការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន
- លោក **តែង វែងហុង** មន្ត្រីការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន
- លោកស្រី **ហង្ស ចំនួដា** មន្ត្រីការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋាន

**ក្រសួងផែនការ**

- លោក **ចី យាម** ប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត
- លោក **ផន ចិន្តា** អនុប្រធាននាយកដ្ឋានស្ថិតិសង្គមកិច្ច

**ក្រសួងសុខាភិបាល**

- លោកស្រីវេជ្ជបណ្ឌិត **គុល ខេមរ៉ាវី** ប្រធានការិយាល័យផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល
- លោកវេជ្ជបណ្ឌិត **យក់ សារាវិទ្ធ** មន្ត្រីផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល
- លោកវេជ្ជបណ្ឌិត **មាស វណ្ណថន** មន្ត្រីផ្នែកប្រព័ន្ធព័ត៌មានសុខាភិបាល

# អក្សរកាត់

| | | |
|---|---|---|
| ADB | - | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CCWC | - | គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ |
| CDHS | - | ការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅកម្ពុជា |
| COD | - | មូលហេតុនៃការស្លាប់ |
| COIA | - | គណៈកម្មការព័ត៌មាន និងគណនេយ្យភាព សម្រាប់សុខភាពស្ត្រី និងកុមារ |
| CRVS | - | ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន |
| DoGA | - | នាយកដ្ឋានរដ្ឋបាលទូទៅ |
| DPHI | - | នាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| DHS | - | ការអង្កេតប្រជាសាស្ត្រ និងសុខភាព |
| HMN | - | បណ្តាញវង្វាស់សុខភាពសុខាភិបាល |
| ICD | - | ចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ |
| HMIS | - | ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល |
| JICA | - | ទីភ្នាក់ងារសហប្រតិបត្តិការកម្ពុជា-ជប៉ុន |
| MCCD | - | លិខិតបញ្ជាក់មូលហេតុស្លាប់តាមបែបវេជ្ជសាស្ត្រ |
| MoI | - | ក្រសួងមហាផ្ទៃ |
| MoH | - | ក្រសួងសុខាភិបាល |
| MoP | - | ក្រសួងផែនការ |
| NRMNCHC | - | មជ្ឈមណ្ឌលគាំពារមាតា និងទារក |
| NSO | - | ការិយាល័យស្ថិតិជាតិ |
| UQ | - | សាកលវិទ្យាល័យ ឃ្វីនឡែន |
| UNHCR | - | ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន |
| URC | - | សាកលវិទ្យាល័យស្រាវជ្រាវ |
| UNFPA | - | មូលនិធិអង្គការសហប្រជាជាតិសម្រាប់ប្រជាជន |
| USAID | - | ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ |
| WHO | - | អង្គការសុខភាពពិភពលោក |
| WPRO | - | ការិយាល័យតំបន់ប៉ាស៊ីហ្វិកភាគខាងលិច របស់ WHO |

phar

# មាតិកា


| | |
|---|---|
| អារម្ភកថា | ២ |
| សេចក្តីថ្លែងអំណរគុណ | ៣ |
| អក្សរកាត់ | ៤ |
| សេចក្តីសង្ខេប | ៦ |
| ១. សេចក្តីផ្តើម | ១៣ |
| ២. សមាសភាគ ក : មូលដ្ឋានច្បាប់ និងធនធានសម្រាប់ CRVS | ២០ |
| ៣. អនុសមាសភាគ ក១ : ក្របខណ្ឌច្បាប់ជាតិ សម្រាប់ប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន | ២០ |
| ៤. អនុសមាសភាគ ក២ : ហេដ្ឋារចនាសម្ព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងធនធាន | ២៣ |
| ៥. សមាសភាគ ខ : ការអនុវត្តក្នុងការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញ | ២៦ |
| ៦. អនុសមាសភាគ ខ១ : រចនាសម្ព័ន្ធ និងមុខងារនៃប្រព័ន្ធការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន | ២៦ |
| ៧. អនុសមាសភាគ ខ២ : ការត្រួតពិនិត្យឡើងវិញអំពីទម្រង់ដែលបានប្រើប្រាស់សម្រាប់ការចុះបញ្ជីកំណើត និងមរណភាព | ៣៣ |
| ៨. អនុសមាសភាគ ខ៣ : ការគ្របដណ្តប់ និងភាពពេញលេញនៃការចុះបញ្ជីអត្រានុកូលដ្ឋាន | ៣៥ |
| ៩. អនុសមាសភាគ ខ៤ : ការរក្សាទុក និងការបញ្ជូនទិន្នន័យ | ៣៩ |
| ១០. សមាសភាគ គ : សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់ | ៤១ |
| ១១. អនុសមាសភាគ គ១ : ការអនុវត្ត និងអនុលោមទៅតាមចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ ICD សម្រាប់សំបុត្រមរណភាព | ៤២ |
| ១២. អនុសមាសភាគ គ២ : លិខិតបញ្ជាក់មរណភាពរបស់មន្ទីរពេទ្យ | ៤៣ |
| ១៣. អនុសមាសភាគ គ៣ : មរណភាពដែលកើតឡើងនៅក្រៅមន្ទីរពេទ្យ | ៤៤ |
| ១៤. អនុសមាសភាគ គ៤ : ការអនុវត្តដែលមានភាពប៉ះពាល់ទៅនឹងគុណភាពទិន្នន័យមូលហេតុនៃការស្លាប់ | ៤៤ |
| ១៥. សមាសភាគ ឃ : ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD | ៤៨ |
| ១៦. សមាសភាគ ង : ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ | ៤៩ |
| ១៧. អនុសមាសភាគ ង១ : គុណភាពទិន្នន័យ និងភាពត្រឹមត្រូវនៃការត្រួតពិនិត្យ | ៤៩ |
| ១៨. អនុសមាសភាគ ង២ : ការរៀបចំតារាងទិន្នន័យ | ៥០ |
| ១៩. អនុសមាសភាគ ង៣ : ការប្រើប្រាស់ និងការផ្សព្វផ្សាយទិន្នន័យ | ៥១ |
| ២០. សេចក្តីសន្និដ្ឋាន | ៥៣ |
| ២១. ទិសដៅអនុវត្ត (ជំហានបន្ទាប់) | ៥៤ |




phak

# សេចក្តីសង្ខេប

មុខងារសំខាន់នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន គឺមានភាពចាំបាច់ណាស់សម្រាប់និរន្តរភាពនៃការអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលរួមទាំងអ្នកពាក់ព័ន្ធសំខាន់ៗ ដែលធ្វើការងារពាក់ព័ន្ធនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅប្រទេសកម្ពុជា ទទួលស្គាល់នូវចំណុចសំខាន់នៃប្រព័ន្ធ CRVS នេះ សម្រាប់ការការពារសិទ្ធិមនុស្ស ការផលិតព័ត៌មានសំខាន់ៗ ការគាំទ្រអភិបាលកិច្ចល្អ ការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការអភិវឌ្ឍន៍ និងដំណើរការតាមដានត្រួតពិនិត្យឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍ជាតិ និងជាអន្តរជាតិ ។

កម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេស ៧៤ ដែលបានប្តេជ្ញាក្នុងការអនុវត្តនូវអនុសាសន៍របស់គណៈកម្មការព័ត៌មាន និងគណនេយ្យភាព សម្រាប់សុខភាពស្ត្រី និងកុមារ ហៅកាត់ថា (COIA) ។ អនុសាសន៍មួយដំបូងក្នុងអនុសាសន៍ ១០ របស់ COIA គឺត្រឹមឆ្នាំ២០១៥ ប្រទេសជាច្រើន នឹងសម្រេចឱ្យបានក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដើម្បីចុះបញ្ជីកំណើត មរណភាព និងមូលហេតុនៃការស្លាប់ ។

ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជា តម្រូវឱ្យមានការកសាងសមត្ថភាពដល់មន្ត្រីនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងនៅគ្រប់ផ្នែកដែលពាក់ព័ន្ធទាំងអស់ ដើម្បី :

១. ធានាឱ្យបុគ្គលម្នាក់ៗ មានឯកសារជាភស្តុតាងច្បាស់លាស់ដែលតម្រូវឱ្យមាន ដើម្បីធានាការទទួលស្គាល់នូវអត្តសញ្ញាណផ្លូវច្បាប់របស់ពួកគេ ។

២. កំណត់ និងបែងចែកព័ត៌មានពាក់ព័ន្ធនឹងកំណើត ការសុំកូន ការរៀបអាពាហ៍ពិពាហ៍ ការលែងលះ មរណភាព និងមូលហេតុនៃការស្លាប់ ដូចជាការកាត់បន្ថយបន្ទុករបស់អ្នកប្រើប្រាស់បញ្ជីដែលពាក់ព័ន្ធក្នុងការប្រើប្រាស់សេវា ។

៣. ចងក្រង និងធ្វើការវិភាគស្ថិតិ បានមកពីការកត់ត្រា

៤. ផ្សព្វផ្សាយស្ថិតិអត្រានុកូលដ្ឋាន

នៅប្រទេសកម្ពុជា ការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន គឺជាការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល រួមទាំងដៃគូអភិវឌ្ឍន៍នានា ជាពិសេស ការបែងចែកធនធានឱ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព ។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅប្រទេសកម្ពុជា ត្រូវបានអនុវត្តសម្រេចដោយជោគជ័យក្នុងទិដ្ឋភាពជាច្រើន ដោយសារការប្តេជ្ញាចិត្តពីក្រសួងមហាផ្ទៃ និងការគាំទ្រពីដៃគូអភិវឌ្ឍន៍ ដូចជា អង្គការ UNICEF ADB, Plan, UNHCR, UNFPA, USAID, JICA, URC, WHO និងដៃគូដទៃទៀត ។ ទោះបីជាមានការរីកចំរើនទៅមុខក្នុងការពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានទាំងមូលក៏ដោយ ក៏វាជាតម្រូវការឱ្យមានការគាំទ្រដោយភាពសុខដុមនីយកម្ម និងមានលក្ខណៈនិរន្តរភាព ពីដៃគូពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការចុះបញ្ជីអត្រា-នុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ។

**ការវាយតម្លៃទៅលើប្រព័ន្ធការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅប្រទេសកម្ពុជាត្រូវបានរៀបចំឡើង ចាប់ពីថ្ងៃទី០៩ ដល់ ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០១៣ នៅខេត្តព្រះសីហនុ**

សិក្ខាសាលាចំនួន ៣ថ្ងៃ ស្តីពីការវាយតម្លៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា ត្រូវបានរៀបចំឡើង ដោយមានក្រសួងមហាផ្ទៃជាភ្នាក់ងារដឹកនាំក្នុងការរៀបចំសិក្ខាសាលានេះឡើង ដើម្បីណែនាំ និងតម្រង់ទិសដល់អ្នកពាក់ព័ន្ធទៅនឹងប្រព័ន្ធ CRVS ដែលគាំទ្របច្ចេកទេសដោយអង្គការសុខភាពពិភពលោក (WHO) ក្នុងការសម្របសម្រួលដល់ដំណើរការនៃការវាយតម្លៃ (ដោយប្រើប្រាស់ឧបករណ៍ WHO/UQ) ។

ការត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន នៅប្រទេសកម្ពុជា បានបង្ហាញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធទាំងពីរនេះ។ ដំណើរការនេះបានផ្តល់នូវចំណុចចាប់ផ្តើមនៃប្រព័ន្ធ និងភាពស្មុគស្មាញនៃបរិបទប្រវត្តិសាស្ត្រដែលកើតមានឡើង ភាគច្រើនបានទទួលជោគជ័យនៅក្នុងបណ្តាឆ្នាំចុងក្រោយចាប់តាំងពីត្រូវបានបង្កើតឡើង ជាពិសេសពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត។ សម្រាប់ការចុះបញ្ជីមរណភាព លិខិតបញ្ជាក់មូលហេតុនៃការស្លាប់ និងទិដ្ឋភាពស្ថិតិចម្រុះនៃប្រព័ន្ធ CRVS របស់ប្រទេស ទាមទារកម្ពុជាឱ្យមានការយកចិត្តទុកដាក់ និងការពិចារណាលើការងារនេះថែមទៀត។

សិក្ខាសាលានេះ មានអ្នកចូលរួមចំនួន ៧៤នាក់ មកពីក្រសួងពាក់ព័ន្ធ ដូចជាក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ថ្នាក់ខេត្ត ថ្នាក់ក្រុង ស្រុក និងឃុំ សង្កាត់ ដោយបានចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សាវាយតម្លៃនេះ រួមទាំងដៃគូអភិវឌ្ឍន៍ ដូចជា អង្គការ UNICEF និងអង្គការ URC ផងដែរ។ របៀបវារៈ និងតារាងអ្នកចូលរួមសិក្ខាសាលានេះ មានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១។

**គោលបំណងនៃសិក្ខាសាលា**

១. ណែនាំដល់អ្នកពាក់ព័ន្ធទៅនឹងប្រព័ន្ធ CRVS ទាំងអស់ ដើម្បីយល់ដឹងពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃមុខងាររបស់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន

២. ណែនាំដល់អ្នកពាក់ព័ន្ធទាំងអស់នូវសមាសភាគចំបងចំនួន៥ នៃមុខងារសំខាន់របស់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន រួមមាន :

- សមាសភាគ ក : មូលដ្ឋានច្បាប់ និងធនធានសម្រាប់ CRVS
- សមាសភាគ ខ : ការអនុវត្តក្នុងការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញ
- សមាសភាគ គ : សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់
- សមាសភាគ ឃ: ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ ICD
- សមាសភាគ ង : ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ

៣. ការរៀបចំសិក្ខាសាលាវាយតម្លៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា: ការត្រួតពិនិត្យឡើងវិញពីស្ថានភាពបច្ចុប្បន្ន ការកំណត់ឧបសគ្គ និងអនុសាសន៍ដែលជាសកម្មភាពសម្រាប់ធ្វើឱ្យប្រសើរឡើង។

## ការរៀបចំសិក្ខាសាលា

សនិទានភាពដែលនាំឱ្យមានការរៀបចំធ្វើការវាយតម្លៃ គឺទោះបីជាប្រទេសកម្ពុជាមានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានកំណើត និងមរណភាពក៏ដោយ ក៏ប៉ុន្តែសក្តានុពលនៃស្ថិតិអត្រានុកូលដ្ឋានមិនទាន់ត្រូវបានពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ។ លើសពីនេះ ការធ្វើឱ្យប្រសើរឡើងនូវគ្រប់ប្រព័ន្ធទាំងអស់ កើតមានឡើងដោយមានការវាយតម្លៃពីភាពខ្លាំង និងខ្សោយដែលកំពុងមាន។ ចាប់តាំងពីប្រព័ន្ធ CRVS (ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន) គឺជាវិស័យមួយដែលមានភាពពាក់ព័ន្ធទៅនឹងវិស័យជាច្រើន ជាការចាំបាច់ណាស់ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែជាផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើង។ ការរកឃើញពីការវាយតម្លៃបានបង្កើតឱ្យមានភស្តុតាងជាមូលដ្ឋានចាំបាច់ សម្រាប់ធ្វើការអភិវឌ្ឍន៍ផែនការធ្វើឱ្យប្រសើរឡើងដែលអាចទុកចិត្តបាន និងសម្រាប់ជាទុនដើម្បីកៀរគរនូវមូលនិធិក្នុងការអនុវត្តកិច្ចការនេះ។

អ្នកចូលរួមសិក្ខាសាលាចំនួន ៧៤នាក់ ត្រូវបានបែងចែកជា៤ក្រុមតូចៗ ដើម្បីធ្វើការពិភាក្សាលើសំណួរដែលបានរៀបចំ និងទាក់ទងនឹងអនុសមាសភាគនីមួយៗ។ សេចក្តីសង្ខេបនៃការរកឃើញពីក្រុមពិភាក្សាតូចៗ ត្រូវបានបង្ហាញនៅក្នុងអង្គសិក្ខាសាលានៅថ្ងៃចុងក្រោយ ដែលបានលើកឡើងនូវចំណុចសំខាន់ៗដូចខាងក្រោម :

១- ក្រុមតូចដែលពិភាក្សាលើមូលដ្ឋានច្បាប់ រចនាសម្ព័ន្ធ និងធនធាន : ទោះបីជាក្របខណ្ឌច្បាប់ពុំចាប់បង្ខំឱ្យចុះបញ្ជីអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជាក៏ដោយ ក៏អនុក្រឹត្យលេខ ១០៣ បង្គាប់ឱ្យប្រជាពលរដ្ឋមានកាតព្វកិច្ចទៅចុះបញ្ជីអត្រានុកូលដ្ឋានកំណើតក្នុងអំឡុងពេល៣០ថ្ងៃក្រោយកើត។ ចំពោះមរណភាពត្រូវទៅចុះបញ្ជីក្នុងអំឡុងពេល ១៥ថ្ងៃ ក្រោយពីស្លាប់ នៅសាលាឃុំ សង្កាត់ ដែលពួកគេរស់នៅអចិន្ត្រៃយ៍។ ក្រៅពីលក្ខខណ្ឌពេលវេលាដែលបានចែងខាងលើការចុះបញ្ជី តម្រូវឱ្យបង់សេវាចំនួន ១០.០០០រៀល ស្មើនឹង ២,៥០ដុល្លារសហរដ្ឋអាមេរិក សម្រាប់ការចុះបញ្ជីបញ្ជាក់កំណើត និងចំនួន ៣.០០០រៀល ស្មើនឹង ០,៧៥ដុល្លារសហរដ្ឋអាមេរិក សម្រាប់ការចុះបញ្ជីមរណភាពដែលលើសពី១៥ ថ្ងៃ។ មេឃុំ ចៅសង្កាត់ ត្រូវបានប្រគល់ភារកិច្ចជាមន្ត្រីអត្រានុកូលដ្ឋាន។

**គន្លឹះរាំងស្ទះ**

- គ្មានកាតព្វកិច្ចចែងក្នុងច្បាប់ទាក់ទងនឹងមូលដ្ឋានសុខាភិបាលក្នុងការរាយការណ៍ពីព្រឹត្តិការណ៍អត្រានុកូលដ្ឋាន
- មិនបានលើកឡើងអំពីអ្នកណាដែលគួរតែបញ្ជាក់ពីមូលហេតុនៃការស្លាប់
- ទិដ្ឋភាពទូទៅមិនបានគ្របដណ្តប់ លើស្ថិតិអត្រានុកូលដ្ឋានដែលបានមកពីទិន្នន័យអត្រានុកូលដ្ឋាន
- តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធផ្សេងទៀត ដូចជា ក្រសួងសុខាភិបាល និងក្រសួងផែនការ តម្រូវឱ្យមានការកំណត់ច្បាស់លាស់។

២-ក្រុមតូចដែលពិភាក្សាលើការអនុវត្តការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញនៃទិន្នន័យអត្រានុកូលដ្ឋាន: មេឃុំ ចៅសង្កាត់ ទាំង ១,៦៣៣ ឃុំ សង្កាត់ ត្រូវបានតែងតាំងសម្រាប់អនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាន។ ការចុះបញ្ជីនៅតែផ្អែកលើការសរសេរក្រដាស និងចម្លងចូលនៅក្នុងសៀវភៅភ្លោះ។ ទោះបីជាគ្មានការវាយតម្លៃផ្លូវការណាមួយពីភាពពេញលេញត្រូវបានធ្វើឡើងក៏ដោយ តែភាពពេញលេញនៃការចុះបញ្ជីកំណើតក្រោមអាយុ

phak

៥ឆ្នាំមានប្រមាណ ៦២,១% បើយោងតាម (CDHS ២០១០) ។ ការគ្របដណ្តប់នៃការចុះបញ្ជីកំណើត គឺខ្ពស់បើប្រៀបធៀបទៅនឹងមរណភាព (ផ្នែកមួយដ៏ធំ គឺដោយសារយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តពីឆ្នាំ ២០០៤-២០០៦ ដែលគាំទ្រដោយអង្គការ UNICEF និង PLAN) ។ ការចុះបញ្ជីមរណភាពមានប្រហែលពី ១០-៣០% បើផ្អែកតាមទិន្នន័យអត្រានុកូលដ្ឋាន ។

**កត្តារាំងស្ទះ**

- ទោះបីជាការចុះបញ្ជីជាភារកិច្ចរបស់មេឃុំក៏ដោយ ក៏មេឃុំមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការអនុវត្តការងារចុះបញ្ជីទេ ដោយសារតែមានកិច្ចការងារច្រើនត្រូវបំពេញ
- ការចុះបញ្ជីមរណភាព គឺនៅមានកម្រិតទាប ហើយជាការចាំបាច់ត្រូវបង្កើនការផ្សព្វផ្សាយការយល់ដឹងជាសាធារណៈ និងភ្ជាប់ការចុះបញ្ជីមរណភាពជាមួយនឹងប្រាក់លើកទឹកចិត្ត ឬសេវា ដូចជាថវិកាសម្រាប់បញ្ចុះសព ។ ល ។
- ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅតែពឹងផ្អែកលើការសរសេរក្រដាស និងការធ្វើសេចក្តីរាយការណ៍ក៏ត្រូវបានប្រើប្រាស់ក្រដាសជាមូលដ្ឋានក្នុងការរាយការណ៍ ពីការិយាល័យថ្នាក់ក្រោមទៅការិយាល័យថ្នាក់ជាតិ ក្នុងពេលវេលាកំណត់ ។

៣- ក្រុមតូចដែលពិភាក្សាលើ សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់ និងការអនុវត្តក្នុងការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ (ICD) : មូលហេតុនៃការស្លាប់ (CoD) លើសំបុត្រមរណភាព នៅពេលចុះបញ្ជីមរណភាព ត្រូវបានកត់ត្រាដោយមន្ត្រីអត្រានុកូលដ្ឋាន ដោយផ្អែកលើអ្វីដែលសមាជិកគ្រួសារបានរាយ-ការណ៍ វាមិនត្រូវបានបំពេញ និងចងក្រង ហើយជាញឹកញាប់មូលហេតុនៃការស្លាប់ គឺរកពុំឃើញមូលហេតុពិតប្រាកដទេ។ ចំពោះមនុស្សដែលស្លាប់នៅមូលដ្ឋានសុខាភិបាលមានប្រមាណតែ ១២%ប៉ុណ្ណោះ ដែលគ្រូពេទ្យបានចូលរួមចំណែកធ្វើការបញ្ជាក់ពីមូលហេតុនៃការស្លាប់ ប៉ុន្តែទិន្នន័យនេះមិនបានភ្ជាប់ទៅនឹងប្រព័ន្ធ CRVS ដែលមានបច្ចុប្បន្នទេ ។ ទម្រង់សំបុត្រមរណភាពមិនដូចទៅនឹងទម្រង់សំបុត្រពេទ្យស្តីពីមូលហេតុនៃការស្លាប់ជាលក្ខណៈអន្តរជាតិទេ ហើយទម្រង់នេះមិនដូចទៅនឹងការអនុវត្ត ICD ដែលបានកំណត់ដោយ CoD ជាមូលដ្ឋាននោះដែរ ។ ការចុះលេខកូដ ICD នៃចំនួនអ្នកស្លាប់ មិនត្រូវបានធ្វើជាប្រចាំទេ ។

**កត្តារាំងស្ទះ**

- តម្រូវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃ MCCD និងបង្កើតការតភ្ជាប់ជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដែលមានប្រមាណតែ ១២% នៃមរណភាពទាំងអស់ ហាក់ដូចជាមាននៅក្នុង MCCD ។ ការកត់ត្រានូវមរណភាពទាំងនេះ តាមរយៈប្រព័ន្ធសុខាភិបាល និងភាគច្រើនបានមកពីមន្ទីរពេទ្យសាធារណៈ ។ មន្ទីរពេទ្យឯកជនតិចតួចបំផុតដែលបានរាយការណ៍ពីព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ទៅក្រសួងសុខាភិបាល ។
- ដោយហេតុថា មានច្រើនជាង ៥០% នៃមរណភាពនៅប្រទេសកម្ពុជា នៅតែកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល នោះការសាកល្បងប្រើប្រាស់ការធ្វើកោសល្យវិច័យផ្ទាល់មាត់គឺជាតម្រូវការ

phak

ក្នុងការកត់ត្រាពីមូលហេតុនៃការស្លាប់ដ៏សមរម្យ សម្រាប់មរណភាពទាំងនេះ ។

- ការចុះលេខកូដ ICD តម្រូវឱ្យមានការបង្ហាញតាមរបៀបមជ្ឈការ ហើយក្រុមបណ្តុះបណ្តាលអ្នកសរសេរដាក់លេខកូដ គួរតែត្រូវបានជ្រើសរើស ។
- កិច្ចសហការអន្តរក្រសួង រវាងក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃ គឺពុំមានកើតឡើងទេ ហើយយន្តការជាប្រព័ន្ធសម្រាប់បង្កើតការទំនាក់ទំនង គឺតម្រូវឱ្យបង្កើតឡើងជាស្ថាប័ន ។

៤- ក្រុមតូចដែលពិភាក្សាលើការប្រើប្រាស់ទិន្នន័យ និងការពិនិត្យគុណភាព : នៅពេលបច្ចុប្បន្ននេះ មិនមានស្ថិតិអត្រានុកូលដ្ឋាន (ទិន្នន័យចម្រុះ) ត្រូវបានរួមបញ្ចូលគ្នា ដែលទទួលបានពីទិន្នន័យអត្រានុកូលដ្ឋានទេ ។ បើទោះបីជាមានពេលវេលាកំណត់ជាក់លាក់សម្រាប់ការរាយការណ៍ពីថ្នាក់ឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និងរាជធានី ខេត្ត យ៉ាងណាក៏ដោយ ក៏ការអនុវត្តពុំទាន់ម៉ត់ចត់ និងតឹងរឹងដែរ ហើយក្រសួងមហាផ្ទៃក៏មិនបានទទួលរបាយការណ៍ស្តីពីការចុះបញ្ជីអត្រានុកូលដ្ឋានពីគ្រប់រាជធានី ខេត្តទាំងអស់ទាន់ពេលវេលាដែរ ។ នៅចុងឆ្នាំ ក្រសួងមហាផ្ទៃធ្វើការចងក្រងរបាយការណ៍ពីចំនួនសរុបនៃការចុះបញ្ជីកំណើត និងមរណភាព ដោយធ្វើការបែងចែកតាមភេទ ប៉ុន្តែមិនតាមអាយុទេ ។ នៅថ្នាក់ជាតិ ក្រសួងមហាផ្ទៃ បានធ្វើការចែករំលែកទិន្នន័យប្រមូលផ្តុំសរុប CRVS ជាមួយនឹងក្រសួងផែនការ ជារៀងរាល់ឆ្នាំ ។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលទិន្នន័យទាំងនេះយកមកធ្វើការវិភាគ តែដំណើរការទៅមុខនៃការចែករំលែកទិន្នន័យត្រូវបានកំពុងពិភាក្សា ។

**កត្តារាំងស្ទះ**

- ដោយសារតែប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាននៅពឹងផ្អែកលើការសរសេរក្រដាសជាមូលដ្ឋាន ការរាយការណ៍ពីឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ រាជធានី ខេត្ត នៅតែមិនទៀងពេល ។
- ទិន្នន័យអត្រានុកូលដ្ឋាន មិនត្រូវបានវិភាគដើម្បីបង្កើតជាស្ថិតិអត្រានុកូលដ្ឋានទេ និងជាព័ត៌មានក្នុងការរៀបចំគោលនយោបាយផ្អែកលើភស្តុតាងជាមូលដ្ឋានទេ។
- តម្រូវឱ្យមានការបង្កើតយន្តការទាក់ទងគ្នា និងតភ្ជាប់ រវាងក្រសួងសុខាភិបាល ក្រសួងផែនការ និងក្រសួងមហាផ្ទៃ ហើយលទ្ធភាពដែលអាចធ្វើបានក្នុងការបង្កើតទិន្នន័យអេឡិចត្រូនិច CRVS រួម គឺតម្រូវឱ្យមានការសាកល្បង ។

វាជាការសំខាន់ក្នុងការលើកឡើងនៅពេលនេះ ដែលភាពជាម្ចាស់នៃប្រទេស គឺជាឆ្អឹងខ្នងនៃការធ្វើអន្តរាគមន៍ជាលក្ខណៈកម្មវិធីដែលមានភាពជោគជ័យ ។ ភ្នាក់ងាររដ្ឋាភិបាលនានាដែលជាប់ទាក់ទងនឹង CRVS នៅកម្ពុជាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំការវាយតម្លៃ និងបន្តដឹកនាំជាប្រធានស្ថាបនិក និងអ្នកអនុវត្តនៃទិសដៅបន្ត ឬក៏ជំហានបន្ទាប់ ។ ជាការរំពឹងទុកមួយ ដែលរដ្ឋាភិបាលនឹងដឹកនាំការអភិវឌ្ឍន៍ និងទទួលយកនូវផែនការយុទ្ធសាស្ត្រពីថ្នាក់កណ្តាល ដែលត្រូវអនុវត្តតាមរយៈគម្រោងកម្មវិធីជាតិដែលមានមហិច្ឆតា ។

នៅចំណុចចុងក្រោយនៃសមាភាគទីមួយ៧ មានអនុសាសន៍ជាច្រើនដែលគាំទ្រដល់ការពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងដំណោះស្រាយចំពោះកត្តារាំងស្ទះ ដែលលើកឡើងដោយសិក្ខាកាមក្នុងសិក្ខាសាលាវាយតម្លៃ ។ អនុសាសន៍ចម្បង៧ទាំងនោះរួមមាន ដូចខាងក្រោម :

phaR

១- បង្កើតគណៈកម្មាធិការជាតិស្តីពីការគ្រប់គ្រងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ដែលមានសមាសភាពមកពីតំណាងនៃក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ។

២- វិសោធនកម្មក្របខណ្ឌច្បាប់ ដើម្បីទទួលស្គាល់មុខងារស្ថិតិអត្រានុកូលដ្ឋាន នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន។

៣- វិសោធនកម្មក្របខណ្ឌច្បាប់ ដោយផ្តល់តួនាទី និងការទទួលខុសត្រូវដល់មណ្ឌលសុខភាព ឱ្យជូនដំណឹងទៅការិយាល័យស្ថិតិអត្រានុកូលដ្ឋាន ពីកំណើត មរណភាព និងមូលហេតុនៃការស្លាប់ លើគ្រប់ករណីទាំងអស់ដែលកើតនៅក្នុងមណ្ឌលសុខភាព ។

៤- ការបែងចែក និងទុកពេលមួយថ្ងៃ ក្នុងមួយសប្តាហ៍ ដើម្បីឱ្យមេឃុំ ចៅសង្កាត់ប្រចាំការនៅសាលាឃុំ សង្កាត់ពេញមួយថ្ងៃ ក្នុងការចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋ ។

៥- ជំហានអន្តរកាលនៃការប្តូរពីការប្រើប្រាស់ការសរសេរក្រដាសជាមូលដ្ឋាន ទៅជាការប្រើប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន ។

៦- ការកំណត់ពីការរំពឹងទុកពីកំណើត និងមរណភាពប្រចាំឆ្នាំ និងបង្កើតប្រព័ន្ធសម្រាប់វិភាគ និងកំណត់ពីការរំពឹងទុក ជាមួយនឹងការចុះបញ្ជីអត្រានុកូលដ្ឋានជាក់ស្តែង ។

៧- យុទ្ធនាការអត្រានុកូលដ្ឋានទូទាំងប្រទេស និងលើកទឹកចិត្តដល់ការចុះបញ្ជីកំណើត និងមរណភាពបានទាន់ពេលវេលា ។

៨- ទម្រង់ដទៃទៀតនៃទិន្នន័យរដ្ឋបាលត្រូវតែប្រមូល និងប្រើប្រាស់សម្រាប់បំពេញគម្លាត និងលុបបំបាត់នូវទិន្នន័យស្ទួនក្នុងប្រព័ន្ធអត្រានុកូលដ្ឋាន ដែលបំពេញដល់ភាពពេញលេញ និងគាំទ្រដល់ទិន្នន័យដែលបានចុះបញ្ជី ។

៩- បង្កើតឱ្យមានយន្តការត្រួតពិនិត្យ និងវាយតម្លៃជាទៀងទាត់ ដោយផ្តល់នូវព័ត៌មានត្រលប់ទៅដល់ឃុំ សង្កាត់ ដើម្បីលើកទឹកចិត្តឱ្យរាយការណ៍ពីទិន្នន័យបានពេញលេញ និងទាន់ពេលវេលា ។

១០-ការទទួលយកមកប្រើប្រាស់នូវលិខិតបញ្ជាក់ជាអន្តរជាតិផ្នែកវេជ្ជសាស្ត្រ ស្តីពីមូលហេតុនៃការស្លាប់ដោយមូលដ្ឋានសុខាភិបាលទាំងផ្នែកឯកជន និងសាធារណៈ ។

១១-ផ្តល់វគ្គតម្រង់ទិស និងបណ្តុះបណ្តាលដល់វេជ្ជបណ្ឌិតទាំងអស់ និងបុគ្គលិកពេទ្យស្តីពីការអនុវត្តការបញ្ជាក់មូលហេតុនៃការស្លាប់ ការស្រាវជ្រាវពីមូលដ្ឋាននៃមូលហេតុនៃការស្លាប់ដែលស្របទៅនឹងគោលការណ៍ចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ (ICD) ។

១២-បណ្តុះបណ្តាលដល់គ្រូបង្គោលអំពីការដាក់លេខកូដ ICD-10 ការអនុវត្ត ICD 10 ត្រូវបានធ្វើការកំណត់ថាជាសកម្មភាពចម្បងនៅក្នុងផែនការយុទ្ធសាស្ត្រព័ត៌មានសុខាភិបាលរបស់ប្រទេសកម្ពុជា សម្រាប់ឆ្នាំ ២០០៨-២០១៥ ។

១៣-បង្កើត និងអនុវត្ត នូវនីតិវិធីក្នុងការបង្ហាញពីទិន្នន័យអត្រានុកូលដ្ឋាន ។ ដូចនេះ ទិន្នន័យអត្រានុកូលដ្ឋាននឹងត្រូវបានចែករំលែកជាមួយក្រសួងផែនការ ដោយការត្រួតពិនិត្យប្រកបដោយស្តង់ដារលើភាពត្រឹមត្រូវ និងជាប់លាប់អាចត្រូវបានធ្វើឡើង ។ ការវាយតម្លៃទៀងទាត់លើភាពពេញលេញ និងត្រឹមត្រូវនៃទិន្នន័យអត្រានុកូលដ្ឋានត្រូវតែធ្វើឡើង ។

១៤-ការអនុវត្តស្តង់ដារអន្តរជាតិសម្រាប់ការរៀបចំ និងប្រមូលផ្តុំទិន្នន័យ ដោយផ្អែកតាមអនុសាសន៍នៃចរិក

phak

លក្ខណៈក្នុងការរៀបចំកំណើត និងមរណភាព របស់នាយកដ្ឋានស្ថិតិរបស់អង្គការសហប្រជាជាតិ ។

**និសដៅបន្ត (ជំហានបន្ទាប់)**

១-ការរៀបចំផែនការយុទ្ធសាស្ត្រដែលអាចជឿទុកចិត្ត ផ្អែកលើការធ្វើជំរឿនទូទាំងប្រទេសក្នុងចំណោមដៃគូពាក់ព័ន្ធសម្រាប់ការអនុវត្តនៃអនុសាសន៍សំខាន់ៗ។ ផែនការគួរតែបញ្ជាក់ឱ្យច្បាស់ពីសកម្មភាព និងពេលវេលា ដើម្បីបង្កើតនូវដំណើរការឆ្ពោះទៅមុខជាក់ស្តែង ដូចអ្វីដែលបានបរិយាយរួចមកហើយ ។

២-រៀបចំសេចក្តីព្រាងថវិកាលំអិតជាមួយតម្លៃ ដែលធ្វើការប៉ាន់ស្មានឱ្យបានសមស្របជាមួយសកម្មភាពបានស្នើឡើង ។

៣- រៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ : គោលបំណងនៃកិច្ចប្រជុំគួរតែមានការគាំទ្រជាទូទៅ និងមានការឯកភាព សម្រាប់ផែនការយុទ្ធសាស្ត្រ។ ដូច្នេះ ការអនុវត្តនៃការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន ដែលមានបច្ចុប្បន្នអាចចាប់ផ្តើមផែនការអនុវត្ត និងសំណើសុំការគាំទ្រពីដៃគូ គួរត្រូវបានបង្កើត ដោយចាប់ផ្តើមអនុវត្តនូវសកម្មភាពអាទិភាពដែលធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាននេះ ។

phak

## សេចក្តីផ្តើម

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាការផ្តល់ឯកសារគតិយុត្តិដល់ប្រជាពលរដ្ឋដើម្បីប្រើប្រាស់បញ្ជាក់ពីភស្តុតាងនៃហេតុការណ៍ដែលកើតឡើង (ឧទាហរណ៍: អាយុ អត្តសញ្ញាណ) ជុំវិញព្រឹត្តិការណ៍អត្រានុកូលដ្ឋាន។ ស្ថិតិអត្រានុកូល-ដ្ឋានត្រូវបានប្រើប្រាស់ដើម្បីទទួលបានរង្វាស់ប្រជាសាស្ត្រ និងការវិភាគទៅលើអេពីដេមីសាស្ត្រជាមូលដ្ឋាន ដែលតម្រូវឱ្យមានក្នុងផែនការជាតិលើវិស័យជាច្រើនដូចជា ការអប់រំ ការងារ និងសុខាភិបាល។

ទោះបីយ៉ាងណាក៏ដោយ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ជារឿយៗ គឺនៅមានចំណុចខ្សោយ និងមិនពេញលេញ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ ប្រភពទិន្នន័យផ្សេងទៀត ដើម្បីបង្កើតបានស្ថិតិអត្រានុកូលដ្ឋាន ដូចជា ជំរឿនប្រជាពលរដ្ឋ ការធ្វើអង្កេតជាសំណាកគំរូនៅតាមគ្រួសារ ការអង្កេតប្រជាសាស្ត្រនៅកន្លែងដែលត្រូវបានកំណត់ជ្រើសរើសណាមួយ និងសំណាកគំរូនៃប្រព័ន្ធចុះបញ្ជីត្រូវបានយកមកប្រើប្រាស់។ ប្រភពទិន្នន័យទាំងនេះ គឺជាវិធីសាស្ត្រដែលចំណាយច្រើន និងមិនបានផ្តល់ស្ថិតិអត្រានុកូលដ្ឋានជាប្រចាំពេញលេញ និងមិនទាន់ពេលវេលា។

ប្រទេសកម្ពុជា បានប្តេជ្ញាក្នុងការអនុវត្តអនុសាសន៍នៃគណៈកម្មាធិការព័ត៌មាន និងគណនេយ្យភាពសម្រាប់សុខភាពស្ត្រី និងកុមារ (COIA)។ អនុសាសន៍ទីមួយក្នុងចំណោមអនុសាសន៍ ១០ នៃ COIA បញ្ជាក់ថា ត្រឹមឆ្នាំ២០១៥ ប្រទេសជាច្រើន នឹងបោះជំហានទៅមុខដើម្បីពង្រឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានរបស់ខ្លួនក្នុងការចុះបញ្ជីកំណើត មរណភាព និងមូលហេតុនៃការស្លាប់ ដើម្បីសម្រេចបាននូវកម្រិតខ្ពស់នៃភាពពេញលេញ (ទិសដៅ iERG > 75%, >60%&60% រៀងៗខ្លួន) ពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូ-លដ្ឋានជាប្រចាំ។

អត្រានុកូលដ្ឋាន គឺជាការងាររដ្ឋបាលដែលប្រើប្រាស់ដើម្បីធ្វើការកត់ត្រានូវព្រឹត្តិការណ៍សំខាន់ៗ ដូចជា កំណើត និងមរណភាព។ អត្រានុកូលដ្ឋាន ត្រូវបានកំណត់នូវការកត់ត្រាជាប្រចាំ ជាអចិន្ត្រៃយ៍ ជាកាតព្វកិច្ច និងការកត់ត្រាជាសកល ព្រមទាំងចរិកលក្ខណៈនៃព្រឹត្តិការណ៍សំខាន់ៗ (កំណើតរស់ មរណភាព មរណភាពទារកក្នុងផ្ទៃ អាពាហ៍-ពិពាហ៍ និងការលែងលះ) ហើយនឹងព្រឹត្តិការណ៍នៃភាពជាស៊ីវិលដទៃទៀត ដែលជាប់ទាក់ទងនឹងចំនួនប្រជាពលរដ្ឋដែលផ្តល់ដោយច្បាប់ ព្រះរាជក្រឹត្យ ឬលិខិតបទដ្ឋានផ្សេងៗ ស្របជាមួយនឹងតម្រូវការច្បាប់នៅក្នុងប្រទេសនីមួយៗ (អង្គការសហប្រជាជាតិ ឆ្នាំ២០០១)។

ប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន គឺជាដំណើរការរួមនៃ (ក) ការប្រមូលព័ត៌មានតាមរយៈការចុះបញ្ជីអត្រានុកូលដ្ឋាន ឬការរាប់ទៅលើព្រឹត្តិការណ៍ដែលកើតឡើងពាក់ព័ន្ធអត្រានុកូលដ្ឋាន និងដែលបានកំណត់ជាក់លាក់ណាមួយ ជាពិសេសទាក់ទងនឹងចរិកលក្ខណៈរបស់ព្រឹត្តិការណ៍នោះ ជាមួយនឹងមនុស្ស ឬបុគ្គលដែលជាប់ពាក់ព័ន្ធ និង (ខ) ការចងក្រងកែច្នៃ វិភាគ វាយតម្លៃ បង្ហាញ និងផ្សព្វផ្សាយទិន្នន័យអត្រានុកូលដ្ឋានក្នុងទម្រង់ស្ថិតិ (UN ឆ្នាំ២០០១)។

ស្ថិតិអត្រានុកូលដ្ឋាន គឺជាផ្នែកមួយនៃប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ប្រទេសមួយ។ រូបភាពទី១ បង្ហាញពីគម្លាតដ៏ធំមួយរវាងការប៉ាន់ស្មាន និងចំនួនរាយការណ៍នៃមរណភាពនៅក្នុងតំបន់ប៉ាស៊ីហ្វិកភាគខាងលិច របស់អង្គការសុខ

phak

ភាពពិភពលោក (WHO) ក្នុងឆ្នាំ២០០៧។ គម្លាតនេះបង្ហាញថាការប៉ាន់ប្រមាណមានភាពមិនសូវត្រឹមត្រូវ សម្រាប់សូចនាករមរណភាព ហើយតួលេខទាំងអស់នេះត្រូវបានយកទៅប្រើសម្រាប់ធ្វើការសម្រេចចិត្តលើការអន្តរាគមន៍សុខភាពសាធារណៈ។




រូបភាពទី១ ៖ របាយការណ៍មរណភាព នឹងការប៉ាន់ប្រមាណមរណភាព ឆ្នាំ២០០៧

យោងតាមឯកសារច្បាប់ សំបុត្រកំណើតគឺជាការកំណត់ និងការពារសិទ្ធិរបស់បុគ្គល និងសិទ្ធិជាស៊ីវិលនៅក្នុងសង្គម។ អង្គការយូនីសេហ្វ បានសរសេរអំពីសារៈសំខាន់នៃការចុះបញ្ជីកំណើត និងផលប៉ះពាល់នៃការមិនបានចុះបញ្ជីកំណើត។ លើសពីនេះ អង្គការយូនីសេហ្វ ចាត់ទុកថាការចុះបញ្ជីកំណើត គឺជាការទទួលស្គាល់ផ្លូវច្បាប់ដំបូងសម្រាប់កុមារ (UNICEF ២០០២) ។

មុខងារជាប្រក្រតីនៃប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋានគឺ រាល់កំណើត និងមរណភាព នៃប្រជាពលរដ្ឋទាំងអស់ត្រូវបានកត់ត្រា។ ក្នុងស្ថិតិមូលហេតុនៃការស្លាប់ “ការអនុវត្តត្រឹមត្រូវ (gold standard)” គឺជាភាពពេញលេញនៃអត្រានុកូលដ្ឋាន ដែលមូលហេតុមរណភាពនីមួយៗ កំណត់ដោយវេជ្ជបណ្ឌិត និងដោយអ្នកដែលបានទទួលការបណ្តុះបណ្តាលពីការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺជាអន្តរជាតិ (ICD)។ កិច្ចសហការ និងការអនុវត្តរវាងបុគ្គលិកសុខាភិបាល និងមន្ទីរពេទ្យ គឺចាំបាច់សម្រាប់ការកំណត់មូលហេតុនៃការស្លាប់បានត្រឹមត្រូវ ហើយនឹងសម្រាប់ប៉ាន់ប្រមាណថាតើមរណភាពអាចត្រូវបានចាត់ទុកថាជាមូលហេតុ “ ជំងឺ ” ឬ ដោយសារតែមូលហេតុផ្សេងៗទៀត។ នៅពេលមរណភាពកើតឡើងនៅក្នុងមន្ទីរពេទ្យ ឬនៅកន្លែងផ្សេងដែលវេជ្ជបណ្ឌិតមានវត្តមានអាចបញ្ជាក់ពីមូលហេតុនៃការស្លាប់ នោះដំណើរការបញ្ជាក់លិខិតមរណភាពត្រូវបានចាប់ផ្តើម ។

ទោះបីជាការបញ្ជាក់មូលហេតុនៃការស្លាប់ដោយខាងមន្ទីរពេទ្យបានអនុវត្តជាទូទៅក៏ដោយ ក៏មិនមានន័យថាមូលហេតុត្រឹមត្រូវនៃការស្លាប់ត្រូវបានសរសេរក្នុងសំបុត្រមរណភាពដែរ។ ភាពខ្វះខាតនៃឧបករណ៍ក្នុងការវិភាគរោគវិនិច្ឆ័យ បទពិសោធន៍ និងការយល់ដឹងពីសារៈសំខាន់នៃទិន្នន័យដែលអាចធ្វើការបញ្ជាក់ពីមូលហេតុនៃការស្លាប់ពុំបានត្រឹមត្រូវ។

រូបភាពទី២ បង្ហាញគុណភាពនៃទិន្នន័យមូលហេតុការស្លាប់ដែលមានកម្រិតទាប ក្នុងតំបន់ប៉ាស៊ីហ្វិកភាគខាងលិច (WPR) ដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ មានត្រឹមតែ ១២០ ក្នុងចំណោម ១៩៤ប្រទេសដែលជាសមាជិករបស់អង្គការសុខភាពពិភពលោក (WHO) បានផលិតទិន្នន័យមូលហេតុនៃការស្លាប់។ ក្នុងចំណោមប្រទេស

phaR

ទាំងនេះ មាន ៧០ប្រទេសដែលបានផលិតទិន្នន័យមូលហេតុនៃការស្លាប់ មានគុណភាពអាចទទួលយកបាន។ ប្រទេសចំនួន ៥០ បានផលិតទិន្នន័យមួយចំនួន ពីមូលហេតុនៃការស្លាប់ ប៉ុន្តែពុំសូវមានគុណភាពល្អ ដែលបង្ហាញពីភាពមិនអាចប្រើប្រាស់បានក្នុងគោលបំណងសុខមាលភាពសាធារណៈ។ ប្រទេសក្រៅពីនេះ មិនបានផលិតទិន្នន័យមូលហេតុនៃការស្លាប់ឱ្យបានទៀងទាត់នោះទេ។




រូបភាពទី២ ៖ គុណភាពនៃព័ត៌មានដែលអាចទទួលយកបានក្នុងសកលលោក លើមូលហេតុនៃការស្លាប់

អត្រានុកូលដ្ឋាន និងសមិទ្ធផលទិន្នន័យស្ថិតិអត្រានុកូលដ្ឋាន គឺជាទ្រព្យសម្បត្តិសាធារណៈដែលចាំបាច់ និងជាផលប្រយោជន៍សម្រាប់បុគ្គលម្នាក់ៗ និងសង្គមជាតិ។ ឯកសារផ្លូវច្បាប់ដែលបញ្ជាក់ពីអត្តសញ្ញាណ និងសញ្ជាតិ មិនត្រឹមតែជាការប្រើប្រាស់សេវាសាធារណៈ ឬការទទួលបាននូវសិទ្ធិប៉ុណ្ណោះទេ ថែមទាំងអាចការពារប្រឆាំងនឹងភាពគ្មានសញ្ជាតិ និងការកេងប្រវ័ញ្ចផងដែរ។

ខណៈពេលដែលស្ថិតិអត្រានុកូលដ្ឋានកំណើត និងមរណភាពត្រូវបានដាក់បញ្ចូលគ្នាដោយភ្ជាប់ជាមួយនឹងទិន្នន័យមូលហេតុនៃការស្លាប់បានត្រឹមត្រូវ នោះអនុញ្ញាតឱ្យអ្នកធ្វើសេចក្តីសម្រេចចិត្តផ្នែកសុខាភិបាលកំណត់ និងបង្កើតនូវគោលដៅដែលត្រូវអន្តរាគមន៍បន្ថែមទៀត និងការជួយសង្គ្រោះជីវិតមនុស្សបានប្រសើរ។ ស្ថិតិមរណភាពត្រឹមត្រូវអាចជួយជំរុញឱ្យមានសុខភាពកាន់តែល្អប្រសើរ និងជួយកាត់បន្ថយការចំណាយ។

នៅឆ្នាំ២០០៣-២០០៦ លោក LEE Jong-Wook អគ្គនាយកអង្គការ WHO បានថ្លែងទៅកាន់បុគ្គលិក WHO នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ ថា “ដើម្បីធ្វើការគណនាចំនួនប្រជាជនបាន ដំបូងយើងត្រូវមានលទ្ធភាពរាប់ចំនួនប្រជាជន”។ ការកើត និងស្លាប់របស់ប្រជាជនភាគច្រើននៅក្នុងតំបន់អាស៊ីមិនបានធ្វើការកត់ត្រាទុកនូវបញ្ជីផ្លូវច្បាប់ណាមួយ ឬស្ថិតិផ្លូវការណាមួយឡើយ។ ការគ្មានទិន្នន័យដែលអាចជឿទុកចិត្តបានសម្រាប់កំណើត មរណភាព

និងមូលហេតុនៃការស្លាប់ (CoD) គឺជាមូលហេតុចម្បងដែលធ្វើឱ្យប្រជាជនក្រីក្រក្នុងពិភពលោកត្រូវបានគេបំភ្លេច និងមិនបានរាប់បញ្ចូល។ ការចុះបញ្ជីអត្រានុកូលដ្ឋាន គឺជាភស្តុតាងមូលដ្ឋានចម្បងដែលរដ្ឋទទួលស្គាល់ និងគោរពនូវការរស់រានមានជីវិតដែលជាការទទួលខុសត្រូវក្នុងការការពារ និងការអភិវឌ្ឍន៍។

នៅក្នុងពិភពលោក កំណើត ១ ភាគ ៣ មិនត្រូវបានរាប់បញ្ចូល ហើយមរណភាព ២ ភាគ ៣ មិនត្រូវបានរាប់បញ្ចូល និងចំនួន ២ ភាគ ៣ នៃប្រជាពលរដ្ឋក្នុងពិភពលោកមិនមានមូលហេតុនៃការស្លាប់ដែលអាចជឿទុកចិត្តបាន។ ដូច្នេះ យើងកំពុងដោះស្រាយបញ្ហាសួចនាករសុខភាពដែលមិនអាចជឿទុកចិត្តបាននេះ។ បើសិនជាមិនមានទិន្នន័យទាំងនេះទេ យើងគ្មានមធ្យោបាយដឹងថា តើការអន្តរាគមន៍របស់យើងមានដំណើរការឬទេ និងថាតើជំនួយអភិវឌ្ឍន៍កំពុងបង្កើតឱ្យមានជាលទ្ធផលដែលចង់បានលើវិស័យសុខាភិបាល (វេជ្ជបណ្ឌិត Margret Chan អគ្គនាយកអង្គការសុខភាពពិភពលោក ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៧)។ យើងចាំបាច់ត្រូវកំណត់អាទិភាពប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានជាកត្តាត្រូវអភិវឌ្ឍន៍នៅក្នុងរបៀបវារៈគោលដៅអភិវឌ្ឍសហវត្សពិភពលោកបន្ទាប់។ យើងមិនអាចរង់ចាំអ្វីត្រូវអូសបន្លាយទៀតទេ។ ពិភពលោកសម័យកាលថ្មីៗនេះ ផ្តោតសំខាន់លើប្រសិទ្ធភាពជំនួយ និងសមិទ្ធផលដោយបន្សល់ទុកនូវវិវាហាសាស្ត្រ ដោយគ្មានប្រព័ន្ធមុខងារនៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រាន-កូលដ្ឋាន។

ទិន្នន័យដែលបានមកពីបញ្ជីអត្រានុកូលដ្ឋានបង្កើតជាមូលដ្ឋាននៃប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋានរបស់ប្រទេសមួយ។ ស្ថិតិអត្រានុកូលដ្ឋាននេះត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានសម្រាប់វាស់វែងប្រជាសាស្ត្រ និងអេពីដេមីសាស្ត្រ ដែលជាតម្រូវការសម្រាប់រៀបចំផែនការជាតិលើវិស័យជាច្រើន ដូចជា វិស័យអប់រំ ការងារ និងសុខាភិបាល។ ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន ជារឿយៗមានលក្ខណៈខ្សោយ និងមិនមានភាពពេញលេញទេនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។ ដូច្នេះ ជំរឿនប្រជាជន ការធ្វើអង្កេតជាសំណាកគំរូនៅតាមគ្រួសារ ការអង្កេតប្រជាសាស្ត្រនៅកន្លែងដែលត្រូវបានកំណត់ជ្រើសរើសណាមួយ និងសំណាកគំរូនៃប្រព័ន្ធចុះបញ្ជីត្រូវបានយកមកប្រើប្រាស់។ ប្រភពទិន្នន័យផ្សេងគ្នាទាំងនេះ គឺជាវិធីសាស្ត្រដែលចំណាយច្រើន ហើយមិនបានផ្តល់នូវនិរន្តរភាព ភាពពេញលេញ និងមធ្យោបាយដ៏មានប្រសិទ្ធភាព ដើម្បីទទួលបាននូវស្ថិតិសំខាន់ៗជាទៀងទាត់ និងទាន់ពេលវេលាទេ។

លើសពីនេះ ដូចមានបង្ហាញក្នុងរូបខាងក្រោម ការប្រមូលទិន្នន័យមរណភាពក្នុង ៥៧ប្រទេសដែលមានចំណូលទាបលើសពី ២៥ឆ្នាំ ចាប់ពីឆ្នាំ១៩៨០-២០០៤ បានបង្ហាញថា ដំណើរការក្នុងការទទួលបានស្ថិតិមរណភាពពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានមានតិចតួច និងមានការកើនឡើងតែពី ៥% ទៅ៩% ប៉ុណ្ណោះក្នុងរយៈពេលខាងលើនេះ។ ស្របគ្នាទៅនឹងដំណើរការដែលធ្វើឡើងដោយការប្រមូលទិន្នន័យមរណភាព បានមកពីការធ្វើអង្កេតដែលបានចាប់ផ្តើមពីដំបូងមានចំនួន ៥% ប៉ុន្តែការប្រមូលទិន្នន័យនេះបានរីកចម្រើន និងកើនឡើងរហូតដល់ចំនួន ៤៥% សម្រាប់រយៈពេលដូចគ្នានេះដែរ។

phar




ការប្រមូលទិន្នន័យមរណភាព ដោយប្រភពក្នុងចំណោម ៥៧ប្រទេស ដែលមានចំណូលទាប ១៩៨០-២០០៤

កម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេស ៧៤ ដែលបានប្តេជ្ញាគោរពតាមអនុសាសន៍ នៃគណៈកម្មាធិការព័ត៌មាន និងគណនេយ្យភាពសម្រាប់សុខភាពស្ត្រី និងកុមារ (COIA) ។

អនុសាសន៍ទី១ក្នុងចំណោមអនុសាសន៍ចំនួន ១០ នៃ COIA គឺថា ត្រឹមឆ្នាំ២០១៥ ប្រទេសជាច្រើនបានបោះជំហានដ៏សំខាន់សម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធ CRVS របស់ខ្លួនក្នុងការចុះបញ្ជីកំណើត មរណភាព និងមូលហេតុនៃការស្លាប់ ដើម្បីទទួលបាននូវភាពពេញលេញកម្រិតខ្ពស់ (iERG targets > 75%, >60%&> 60% respectively) ពីប្រព័ន្ធ CRVS ដ៏ទៀងទាត់មួយ ។

ទោះបីជាការវាយតម្លៃជាផ្លូវការអំពីភាពពេញលេញមិនត្រូវបានធ្វើឡើងក៏ដោយ បើយោងតាមទិន្នន័យអង្កេតប្រជា-សាស្ត្រ និងសុខភាព (CDHS) ឆ្នាំ២០១០ ភាពពេញលេញនៃការចុះបញ្ជីកំណើតក្រោមអាយុ៥ឆ្នាំ មានប្រមាណចំនួន៦២,១% ។ មធ្យមភាគនៃការចុះបញ្ជីកំណើត គឺមានកម្រិតខ្ពស់ បើប្រៀបធៀបទៅនឹងមរណភាព ។ ការចុះបញ្ជីមរណភាពបង្ហាញថា មានប្រមាណតិចជាង ១០% ផ្អែកទៅតាមការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានតែសំបុត្រមរណភាពចំនួនតែ ៨៤.០០០សំបុត្រប៉ុណ្ណោះដែលបានផ្តល់ជូនពីឆ្នាំ២០០២-២០១២ ។ ប្រទេសកម្ពុជាអាចរំពឹងថាមានអ្នកស្លាប់ប្រហាក់ប្រហែល ១១៣.៤០០នាក់ ក្នុងមួយឆ្នាំ ដោយប្រើប្រាស់ចំណោលប្រជាជនរបស់អង្គការសហប្រជាជាតិសម្រាប់អំឡុងពេល ២០០៥-២០១០ ជាមួយការចុះបញ្ជីមានត្រឹមប្រមាណ ៨.០០០នាក់ ជារៀងរាល់ឆ្នាំ ។ ភាពពេញលេញអាចតិចជាង ១០% (របាយការណ៍ប្រទេសកម្ពុជាដែលរៀបចំដោយសាកលវិទ្យាល័យឃ្វីនឡែន ខែសីហា ឆ្នាំ២០១២) ។

phaR

នៅប្រទេសកម្ពុជាគម្លាតនៅតែធំរវាងកំណើត និងមរណភាពដែលរំពឹងទុកបើធៀបទៅនឹងកំណើត និងមរណភាពដែលបានចុះបញ្ជី ។ ផ្អែកលើការប៉ាន់ប្រមាណនេះ មានដូចជា :

១.ភាពពេញលេញនៃការចុះបញ្ជីកំណើត : មានចំនួន ៦២,១% ( CDHS 2010)

២.ភាពពេញលេញនៃការចុះបញ្ជីមរណភាព : តិចជាង ១០% (មានត្រឹមតែ ៨៤.០០០ សំបុត្រមរណភាពដែលចេញពីឆ្នាំ២០០២-២០១២ មរណភាពរំពឹងទុកជារៀងរាល់ឆ្នាំគឺចំនួន ១១៣.៤០០នាក់ ធៀបទៅនឹងមរណភាពដែលបានចុះបញ្ជីប្រចាំឆ្នាំមានតែ ៨.០០០នាក់ តែប៉ុណ្ណោះ)

ផ្អែកតាមគោលដៅរបស់គណៈកម្មាធិការព័ត៌មាន និងគណនេយ្យភាពសម្រាប់សុខភាពស្ត្រី និងកុមារ (COIA) ត្រឹមឆ្នាំ២០១៥ ប្រទេសជាច្រើនគួរមានការចុះបញ្ជីឱ្យបានពេញលេញកំណើតលើស ៧៥% មរណភាពលើស ៦០% និងមូលហេតុនៃការស្លាប់លើសពី ៦០% ។

ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលមានដំណើរការល្អគឺមានសារៈសំខាន់ណាស់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ។ អ្នកពាក់ព័ន្ធសំខាន់ៗនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជាបានទទួលស្គាល់នូវសារៈសំខាន់នៃប្រព័ន្ធ CRVS សម្រាប់ការការពារសិទ្ធិមនុស្ស ផលិតនូវព័ត៌មានសំខាន់ៗ គាំទ្រអភិបាលកិច្ចល្អ ធ្វើឱ្យប្រសើរឡើងលទ្ធផលនៃអភិវឌ្ឍន៍ តាមដានពីការរីកចំរើនឆ្ពោះទៅរកការឯកភាពថ្នាក់ជាតិ និងអន្តរជាតិលើគោលដៅអភិវឌ្ឍន៍ ។

## ដំណើរការពិនិត្យ និងវិធីសាស្ត្រវាយតម្លៃ

សិក្ខាសាលារយៈពេលចំនួន ៣ថ្ងៃ ស្តីពីការវាយតម្លៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងដោយក្រសួងមហាផ្ទៃដែលជាភ្នាក់ងារដឹកនាំរៀបចំសិក្ខាសាលានេះ សម្រាប់អ្នកពាក់ព័ន្ធទៅនឹងប្រព័ន្ធ CRVS ដើម្បីជួបប្រជុំពិភាក្សាគ្នា ។ សិក្ខាសាលានេះគាំទ្របច្ចេកទេសដោយអង្គការសុខភាពពិភពលោក (WHO) រួមទាំងសម្របសម្រួលដល់ដំណើរការនៃការវាយតម្លៃ (ដោយប្រើប្រាស់ឧបករណ៍ WHO/UQ) ។

អ្នកចូលរួមចំនួន ៧៤នាក់ មកពីក្រសួងពាក់ព័ន្ធ ដូចជាក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ថ្នាក់ខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ បានចូលរួមយ៉ាងសកម្មក្នុងដំណើរការសិក្សាវាយតម្លៃនេះ រួមទាំងដៃគូអភិវឌ្ឍន៍ ដូចជា អង្គការយូនីសេហ្វ និងអង្គការ URC ផងដែរ ។ របៀបវារៈ និងតារាងអ្នកចូលរួមមានភ្ជាប់មកជាមួយក្នុងឧបសម្ព័ន្ធ១ ។

## គោលបំណងនៃសិក្ខាសាលា

១.អ្នកពាក់ព័ន្ធទៅនឹងប្រព័ន្ធ CRVS ទាំងអស់បានជួបប្រជុំពិភាក្សាគ្នា ដើម្បីស្វែងយល់ដឹងពីសារៈសំខាន់ និងអត្ថប្រយោជន៍ នៃមុខងាររបស់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន

២.ណែនាំដល់អ្នកពាក់ព័ន្ធទាំងអស់អំពីសមាសភាគចម្បងចំនួន ៥ នៃមុខងារសំខាន់របស់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន :

phaR

សមាសភាគ ក : មូលដ្ឋានច្បាប់ និងធនធានសម្រាប់ CRVS

សមាសភាគ ខ : ការអនុវត្តក្នុងការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញ

សមាសភាគ គ : សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់

សមាសភាគ ឃ : ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD

សមាសភាគ ង : ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ

៣. ត្រួតពិនិត្យមើលស្ថានភាពបច្ចុប្បន្ន កំណត់ឧបសគ្គ និងអនុសាសន៍ដែលជាសកម្មភាពសម្រាប់ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា ។

សនិទានភាពដែលនាំឱ្យមានការរៀបចំធ្វើការវាយតម្លៃ គឺទោះបីជាប្រទេសកម្ពុជាមានប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានកំណើត និងមរណភាពក៏ដោយ ក៏ប៉ុន្តែសក្តានុពលនៃស្ថិតិអត្រានុកូលដ្ឋានមិនទាន់ត្រូវបានពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយទេ ។ លើសពីនេះ ការធ្វើឱ្យប្រសើរឡើងនូវគ្រប់ប្រព័ន្ធទាំងអស់ កើតមានឡើងដោយមានការវាយតម្លៃពីភាពខ្លាំង និងខ្សោយដែលកំពុងមាន ។ ចាប់តាំងពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) គឺជាវិស័យមួយដែលមានភាពពាក់ព័ន្ធទៅនឹងវិស័យជាច្រើន ជាការចំបាច់ណាស់ដែលអ្នកពាក់ព័ន្ធទាំងអស់ត្រូវតែជាផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងការវាយតម្លៃ និងធ្វើឱ្យប្រសើរឡើង ។ ការរកឃើញពីការវាយតម្លៃ បានបង្កើតឱ្យមានភស្តុតាងជាមូលដ្ឋានចាំបាច់ សម្រាប់ធ្វើកាអភិវឌ្ឍន៍ផែនការធ្វើឱ្យប្រសើរឡើងដែលអាចទុកចិត្តបាន និងសម្រាប់ជាទុនដើម្បីកៀរគរមូលនិធិក្នុងការអនុវត្តការងារនេះ ។

អ្នកចូលរួមសិក្ខាសាលាចំនួន ៧៤នាក់ ត្រូវបានបែងចែកជា៤ក្រុមតូចៗ ដើម្បីធ្វើការពិភាក្សាលើសំណួរដែលបានរៀបចំ និងទាក់ទងនឹងអនុសមាសភាគនីមួយៗ ។ ក្នុងពេលសិក្ខាសាលាវាយតម្លៃសម្រាប់សំណួរនីមួយៗ សិក្ខាកាមបានពិភាក្សាពីស្ថានភាពបច្ចុប្បន្ន បញ្ហាប្រឈម និងកត្តារាំងស្ទះ ព្រមទាំងអនុសាសន៍ធ្វើឱ្យប្រសើរឡើង ។
ខាងក្រោមនេះជាក្រុមពិភាក្សាតូចៗ :

ក្រុមទី១: សមាសភាគ ក : មូលដ្ឋានច្បាប់ និងធនធានសម្រាប់ CRVS

ក្រុមទី២: សមាសភាគ ខ : ការអនុវត្តក្នុងការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញ

ក្រុមទី៣: សមាសភាគ គ : សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់

ក្រុមទី៤ : សមាសភាគ ឃ : ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD

ក្រុមទី៥ : សមាសភាគ ង : ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ

ការត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា បានបង្ហាញនូវចំណុចខ្លាំង និងចំណុចខ្សោយនៃប្រព័ន្ធទាំងពីរនេះ ។ ដំណើរការនេះបានផ្តល់នូវចំណុចចាប់ផ្តើមនៃប្រព័ន្ធ និងភាពស្មុគស្មាញនៃបរិបទប្រវត្តិសាស្ត្រដែលកើតមានឡើង ភាគច្រើនបានទទួលជោគជ័យនៅក្នុងបណ្តាឆ្នាំចុងក្រោយចាប់តាំងពីត្រូវបានបង្កើតឡើង ជាពិសេសពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត ។ សម្រាប់ការចុះបញ្ជីមរណភាព លិខិតបញ្ជាក់មូលហេតុនៃការស្លាប់ និងទិដ្ឋភាពស្ថិតិចម្រុះនៃប្រព័ន្ធ CRVS របស់ប្រទេសទាមទារកម្ពុជាឱ្យមានការយកចិត្តទុកដាក់ និងការពិចារណាលើការងារនេះថែមទៀត ។ ការរកឃើញដែលបានបង្ហាញក្នុងរបាយការណ៍នេះ គឺជា

phaR

សេចក្តីសង្ខេបនៃការពិភាក្សារបស់អ្នកចូលរួមសិក្ខាសាលា និងការប្រជុំគ្នាជាមួយនឹងមន្ត្រីពាក់ព័ន្ធមកពីក្រសួងចំនួន ៣ មានក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងក្រសួងផែនការ ។

**សមាសភាគ ក : មូលដ្ឋានច្បាប់ និងធនធានសម្រាប់ CRVS**

**អនុសមាសភាគ ក១ : ក្របខណ្ឌច្បាប់ជាតិ សម្រាប់ស្ថិតិអត្រានុកូលដ្ឋាន**

មុនសង្គ្រាមស៊ីវិល ប្រទេសកម្ពុជាធ្លាប់មានមូលដ្ឋានច្បាប់ (ក្រមរដ្ឋប្បវេណី) និងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានត្រឹមត្រូវមួយសម្រាប់ផ្តល់សេវាជូនប្រជាពលរដ្ឋ ។ ក្រមរដ្ឋប្បវេណីបានអនុញ្ញាតឱ្យរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដាក់ចេញសេចក្តីណែនាំរួមមួយសម្រាប់ទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។ នៅពេលនោះ ការអនុវត្តដំណើរការបានល្អ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដំណើរការនៃការអនុវត្តនេះមិនបានទូលំទូលាយទូទាំងប្រទេសទេ ។ ប្រជាពលរដ្ឋដែលរស់នៅតំបន់ដាច់ស្រយាល នៅតែមិនមានសំបុត្រអត្រានុកូលដ្ឋានប្រើប្រាស់ ។

នៅពេលប្រទេសមានសង្គ្រាមស៊ីវិល និងអស្ថិរភាពនយោបាយ នៅឆ្នាំ១៩៧០ ការអនុវត្តប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅមានកម្រិត ដោយមានការអនុវត្តតែនៅក្នុងតំបន់ទីក្រុង ជាពិសេសក្រុងភ្នំពេញ ។

ក្នុងអំឡុងពេលរបបខ្មែរក្រហម ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ការងារអត្រានុកូលដ្ឋានត្រូវបានលុបបំបាត់ចោលទាំងស្រុង ហើយឯកសារទាំងអស់ដែលពាក់ព័ន្ធនឹងការងារអត្រានុកូលដ្ឋាន ក៏ត្រូវបានបំផ្លាញទាំងស្រុងផងដែរ ។

បន្ទាប់ពីឆ្នាំ១៩៧៩ ដល់២០០២ ការងារអត្រានុកូលដ្ឋានបានចាប់ដំណើរការឡើងវិញទូទាំងប្រទេស ។ ទោះបីជាយ៉ាងនេះក៏ដោយ ការចុះបញ្ជី និងទម្រង់បែបបទនៃការអនុវត្តមិនមានការឯកភាព ហើយការអនុវត្តការចុះបញ្ជីនៅក្នុងប្រទេសមានភាពផ្សេងៗគ្នាពីខេត្តមួយទៅខេត្តមួយ ។ ទោះបីក្នុងរយៈពេលនេះ មានការធ្វើឡើងវិញនូវប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានក៏ដោយ ក៏ប្រជាជនភាគច្រើននៅតែមិនបានចុះបញ្ជី ។

យោងតាមរយៈអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ ស្តីពីអត្រានុកូលដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតនូវក្របខណ្ឌច្បាប់សម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅក្នុងប្រទេស ។ អនុក្រឹត្យនេះ បានដាក់ឱ្យអនុវត្តនៅថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២ ក្នុងគោលបំណងផ្តល់ឱ្យប្រជាពលរដ្ឋទាំងអស់មានសំបុត្រអត្រានុកូលដ្ឋានតាមទម្រង់បែបបទថ្មីនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាននៅត្រឹមខែសីហា ឆ្នាំ២០០៥ ។

ក្នុងការខិតខំប្រឹងប្រែងកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរបរនីដែលបានបំផ្លិចបំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធគតិយុត្ត និងតុលាការ ប្រទេសកម្ពុជាបានសម្រេចនូវគោលដៅចម្បងរបស់ខ្លួននៅខែធ្នូ ឆ្នាំ២០១១ តាមរយៈការដាក់ឱ្យប្រើក្រមរដ្ឋប្បវេណីថ្មី ដែលក្នុងនោះមានបទបញ្ញត្តិពាក់ព័ន្ធការងារអត្រានុកូលដ្ឋានផងដែរ ។

ក្នុងខណៈពេលដែលពុំទាន់មានច្បាប់ស្តីពីអត្រានុកូលដ្ឋានច្បាស់លាស់ក៏ដោយ ក៏ប៉ុន្តែមានលិខិតបទដ្ឋានច្បាប់ ឬជាបន្តបន្ទាប់ អនុក្រឹត្យដែលជាមូលដ្ឋានច្បាប់សម្រាប់អនុវត្តការងារអត្រានុកូលដ្ឋានក្នុងប្រទេសកម្ពុជា ដូចខាងក្រោម :

- ច្បាប់ស្តីពីសញ្ជាតិ
- ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ



phak

-ច្បាប់ស្តីពីអន្តោប្រវេសន៍

-ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស

-អនុក្រឹត្យលេខ ១០៣ ស្តីពីអត្រានុកូលដ្ឋាន

មាត្រា៣ នៃអនុក្រឹត្យលេខ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ បានចែងពីកាតព្វកិច្ចប្រជាពលរដ្ឋកម្ពុជាគ្រប់រូបក្នុងការចុះបញ្ជីកំណើត និងមរណភាព។ កំណើតត្រូវតែទៅចុះបញ្ជីក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីកើត ការចុះបញ្ជីនេះមិនត្រូវបង់ប្រាក់ទេ។ ករណីទុកឱ្យហួស ៣០ថ្ងៃក្រោយថ្ងៃកើតនឹងត្រូវបង់សេវាចំនួន ១០.០០០រៀល ស្មើ ២,៥០ដុល្លារសហរដ្ឋអាមេរិក។

ចំពោះមរណភាពតម្រូវឱ្យទៅចុះបញ្ជីក្នុងរយៈពេល ១៥ថ្ងៃក្រោយពីស្លាប់ ករណីលើសពីរយៈពេលនេះត្រូវបង់សេវាចំនួន ៣.០០០រៀល ស្មើ០,៧៥ដុល្លារសហរដ្ឋអាមេរិក ហើយការចុះបញ្ជីមរណភាពទុកឱ្យឆ្លងឆ្នាំ តម្រូវឱ្យសុំសាលក្រមស្ពាពរពីតុលាការ។

នៅប្រទេសកម្ពុជា នៅតែមានគម្លាតធំមួយរវាងគោលដៅដែលរំពឹងទុកសម្រាប់ភាពពេញលេញនៃការចុះបញ្ជីកំណើត និងមរណភាព ជាមួយនឹងភាពពេញលេញជាក់ស្តែងនៃការចុះបញ្ជីកំណើត និងមរណភាព។ នេះបង្ហាញថាជំហានដ៏សំខាន់មួយតម្រូវឱ្យធ្វើឡើងដើម្បីពង្រឹងក្របខណ្ឌច្បាប់សម្រាប់ការចុះបញ្ជីកំណើត និងមរណភាពដ៏ចាំបាច់។ ដូចមានក្នុងគោលដៅរបស់ COIA ត្រឹមឆ្នាំ២០១៥ កម្ពុជាគួរមានភាពពេញលេញនៃការចុះបញ្ជីកំណើតឱ្យលើស ៧៥%។ ដូចមាននៅក្នុង CDHS 2010 ភាពពេញលេញនៃការចុះបញ្ជីកំណើតគឺចំនួន ៦២,១% សម្រាប់ក្មេងអាយុក្រោម៥ឆ្នាំ។ ចំពោះការចុះបញ្ជីមរណភាពគម្លាតគឺកាន់តែធំ ដូចមានចែងក្នុងគោលដៅ COIA។ ភាពពេញលេញនៃការចុះបញ្ជីមរណភាព និងការបញ្ជាក់ពីមូលហេតុនៃការស្លាប់គួរតែលើសចំនួន ៦០% ។ ទោះជាយ៉ាងណាក៏ដោយ ផ្អែកលើការប៉ាន់ប្រមាណរបស់ក្រសួងមហាផ្ទៃ ភាពពេញលេញនៃការចុះបញ្ជីមរណភាពតិចជាង ១០% ដែលមានទិន្នន័យអាចជឿទុកចិត្តបាននូវភាពពេញលេញនៃការបញ្ជាក់មូលហេតុនៃការស្លាប់។

ការចុះបញ្ជីមរណភាពបង្ហាញថាមានប្រមាណតិចជាង ១០% បើផ្អែកទៅតាមការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានសំបុត្រមរណភាពចំនួនតែ ៨៤.០០០សំបុត្រប៉ុណ្ណោះ ដែលបានផ្តល់ជូនចាប់តាំងពីឆ្នាំ២០០២-២០១២។ ប្រទេសកម្ពុជាអាចរំពឹងថា មានអ្នកស្លាប់ប្រហាក់ប្រហែលចំនួន ១១៣.៤០០នាក់ ក្នុងមួយឆ្នាំ ដោយប្រើប្រាស់ចំណោលប្រជាជនរបស់អង្គការសហប្រជាជាតិសម្រាប់អំឡុងពេល ២០០៥-២០១០ ជាមួយការចុះបញ្ជីមានត្រឹមប្រមាណ ៨.០០០នាក់ ជារៀងរាល់ឆ្នាំ។ ភាពពេញលេញអាចតិចជាងចំនួន ១០% (របាយការណ៍ប្រទេសកម្ពុជាដែលរៀបចំដោយសាកលវិទ្យាល័យឃ្វីនឡែន ខែសីហា ឆ្នាំ២០១២)។

អនុក្រឹត្យខាងលើនេះ ត្រូវបានធ្វើប្រតិភូកម្មអំណាច និងការទទួលខុសត្រូវទៅឱ្យក្រុមប្រឹក្សាឃុំ ឬក្រុមប្រឹក្សាសង្កាត់សម្រាប់ការចេញសំបុត្រអត្រានុកូលដ្ឋាន ដែលមានមេឃុំ ចៅសង្កាត់ជាមន្ត្រីអត្រានុកូលដ្ឋានមូលដ្ឋាន។ ឪពុក ម្តាយ ឬអាណាព្យាបាលនៃកុមារមានកាតព្វកិច្ចក្នុងការរាយការណ៍សម្រាប់ការចុះបញ្ជីកំណើត។ ចំពោះមរណភាពវិញ សាច់ញាតិនៃអ្នកស្លាប់ ប្តី ឬប្រពន្ធ ឬឪពុកម្តាយ មានកាតព្វកិច្ចទៅចុះបញ្ជីមរណភាព។

ដូចមាននៅក្នុងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ កំណើត និងមរណភាព ត្រូវចុះបញ្ជី

នៅទីលំនៅអចិន្ត្រៃយ៍ ហើយកន្លែងនៃការកើតឡើងជាក់ស្តែងមិនត្រូវបានកត់ត្រាចូលក្នុងសំបុត្រកំណើតឡើយ។ ដូចមានក្នុងមាត្រា ៥៨ នៃអនុក្រឹត្យលេខ ១០៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ : ការសុំសំបុត្រអត្រានុកូលដ្ឋានកំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ ក្នុងករណីចុះបញ្ជីទាន់ពេលវេលា។ ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់។ រាល់ការសុំចម្លង ឬសម្រង់សំបុត្រអត្រានុកូលដ្ឋាន អ្នកមកសុំត្រូវមកបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រិ៍ ដើម្បីជាប្រយោជន៍សម្រាប់ឃុំ សង្កាត់ និងចំណូលថវិការដ្ឋ។ ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រិ៍ត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

មិនមានកាតព្វកិច្ចផ្លូវច្បាប់ណាមួយតម្រូវឱ្យមន្ទីរពេទ្យ ឬមូលដ្ឋានសុខាភិបាលរាយការណ៍ពីកំណើត និងមរណភាពទេ។ មូលដ្ឋានសុខាភិបាលសាធារណៈ (មានផ្នែកឯកជនតិចតួច) រាយការណ៍តែព្រឹត្តិការណ៍សំខាន់ៗដែលកើតមានឡើងនៅក្នុងស្ថាប័នរបស់ពួកគេទៅក្រសួងសុខាភិបាលប៉ុណ្ណោះ តាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល (HMIS)។ នាថ្ងៃមុខ ជាអនុសាសន៍គឺថា ច្បាប់គួរមានចែងពីសេចក្តីរាយការណ៍ចាំបាច់នៃព្រឹត្តិការណ៍សំខាន់ៗ (កើត ស្លាប់) ដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាលទៅក្នុងប្រព័ន្ធអត្រានុកូលដ្ឋាន។ លើសពីនេះ របាយការណ៍ចាំបាច់ពីមូលដ្ឋានសុខាភិបាលអាចត្រូវបានរួមបញ្ចូលទៅក្នុងច្បាប់ស្តីពីសុខភាពសាធារណៈ។ មិនមានច្បាប់ណាមួយបានចែងថា តើនរណាជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ពីមូលហេតុនៃការស្លាប់ ហើយបញ្ហានេះតម្រូវឱ្យមានការបញ្ចូលទៅក្នុងក្របខណ្ឌច្បាប់ថ្មី ស្តីពីអត្រានុកូលដ្ឋាននៃប្រទេសកម្ពុជា។

មាត្រា ៣៧ នៃអនុក្រឹត្យលេខ ១០៣ បានចែងថា ត្រូវមានឯកសារផ្លូវការមុននឹងបញ្ចុះសព ហើយឯកសារផ្លូវការនេះត្រូវចេញដោយមេឃុំ ចៅសង្កាត់ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការងារនេះមិនត្រូវបានអនុវត្តទេ ហើយការអនុញ្ញាតឱ្យបញ្ចុះសពត្រូវបានស្នើឡើងផ្អែកលើករណីពិសេសតែប៉ុណ្ណោះ។

អនុក្រឹត្យលេខ ១០៣ បានលើកឡើងពីរចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់ក្រសួងមហាផ្ទៃ នៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់។ ទោះជាយ៉ាងណាក៏ដោយ តួនាទី និងការទទួលខុសត្រូវនៃអ្នកពាក់ព័ន្ធដទៃទៀត ដូចជា ក្រសួងសុខាភិបាល ផ្នែកប៉ូលីស ក្រសួងផែនការ មិនបានលើកឡើងក្នុងអនុក្រឹត្យនេះទេ។ ដូចមាននៅក្នុងមាត្រា ៩ នៃអនុក្រឹត្យលេខ ១០៣ បានចែងថា : មន្ត្រីអត្រានុកូលដ្ឋានមានភារកិច្ច ដូចជា :

- ទទួលពិនិត្យ កត់ត្រា រឿងហេតុសំខាន់ៗទាក់ទងនឹង កំណើត អាពាហ៍ពិពាហ៍ និងមរណភាពនៃជនទាំងឡាយចុះក្នុងសៀវភៅអត្រានុកូលដ្ឋាន
- ចេញសេចក្តីចម្លង ឬសម្រង់ នៃអត្រានុកូលដ្ឋាន ដែលមានក្នុងឆ្នាំមិនទាន់ដាច់
- កែតម្រូវអក្ខរាវិរុទ្ធ លើអត្រានុកូលដ្ឋានក្នុងឆ្នាំមិនទាន់ដាច់ តាមលក្ខខណ្ឌមាត្រា ១៣ នៃអនុក្រឹត្យនេះ
- អនុញ្ញាតឱ្យរៀបអាពាហ៍ពិពាហ៍ និងធ្វើបុណ្យបូជា ឬបញ្ចុះសព
- ទទួលខុសត្រូវចំពោះសំបុត្រអត្រានុកូលដ្ឋាន ដែលខ្លួនបានអនុវត្ត
- ចុះហត្ថលេខា និងបោះត្រា លើសំបុត្រអត្រានុកូលដ្ឋាន
- កែតម្រូវ ឬបដិសេធអត្រានុកូលដ្ឋានតាមអំណាចសាលក្រមស្ថាពររបស់តុលាការ ឬតាមបទបញ្ញត្តិនៃច្បាប់

phak

- ថែរក្សាទុកដាក់សៀវភៅអត្រានុកូលដ្ឋាន តាមប្រភេទឱ្យបានគត់មត់ល្អ ងាយស្រួលក្នុងការតាមដាន និងការគ្រប់គ្រង
- បញ្ជូនសៀវភៅអត្រានុកូលដ្ឋានឆ្នាំដែលដាច់ទៅ យកទៅតម្កល់ទុកនៅសាលាក្រុង ឬសាលាស្រុក ឬសាលាខណ្ឌ ០១ ច្បាប់ និងទៅតុលាការរាជធានី ខេត្តសាមី ០១ ច្បាប់ ។
- ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ ឱ្យបានយល់ដឹងពីកាតព្វកិច្ចរបស់ខ្លួន ចំពោះអត្រានុកូលដ្ឋាន និងបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋ ដែលមកទំនាក់ទំនងអំពីអត្រានុកូលដ្ឋាន
- ធ្វើរបាយការណ៍អំពីកំណើត អាពាហ៍ពិពាហ៍ មរណភាព ចំនួនគ្រួសារ ចំនួនប្រជាពលរដ្ឋក្នុងឃុំ ឬសង្កាត់ជារៀងរាល់ខែ និងរាល់ដំណាច់ឆ្នាំនីមួយៗ ផ្ញើទៅសាលាក្រុង ស្រុក ខណ្ឌ សាមី និង
- សហការជាមួយសមត្ថកិច្ចនៅមូលដ្ឋាន អំពីការងារអត្រានុកូលដ្ឋានក្នុងករណីចាំបាច់ ។

ទោះបីជាយ៉ាងណាក៏ដោយ មិនមានឧបករណ៍ផ្លូវច្បាប់ដែលកំណត់អំពីការបង្កើតស្ថិតិអត្រានុកូលដ្ឋានចេញពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានខាងលើនេះទេ ។

លើសពីនេះ អនុក្រឹត្យមិនបានលើកឡើងពីថវិកាគាំទ្រសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានផងដែរ ។ ថវិកាសម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅថ្នាក់ឃុំ សង្កាត់ គឺជាផ្នែកមួយនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងថវិកាដែលប្រមូលបានពីការចេញសេចក្តីចម្លងសំបុត្រកំណើត មរណភាព និងអាពាហ៍ពិពាហ៍ ដែលបង់ចូលរតនាគារ និងបន្ទាប់មកផ្តល់ជូនឃុំ សង្កាត់វិញ ។

អនុក្រឹត្យនេះ ចែងពីការគ្របដណ្តប់លើប្រជាពលរដ្ឋទាំងអស់ដែលរស់នៅក្នុងប្រទេសកម្ពុជាស្របច្បាប់ និងប្រជា-ពលរដ្ឋកម្ពុជាដែលកំពុងរស់នៅឯក្រៅប្រទេស ។ ទោះជាយ៉ាងណាក៏ដោយ កម្មករចំណាកស្រុក និងអ្នកសុំសិទ្ធិជ្រកកោន ឬជនភៀសខ្លួន មិនបានគ្របដណ្តប់នៅក្នុងអនុក្រឹត្យស្តីពីអត្រានុកូលដ្ឋាននេះទេ ។ សម្រាប់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេស ពួកគេអាចទទួលបានសំបុត្រកំណើត នៅពេលដែលពួកគេមកប្រទេសកម្ពុជា ប្រសិនបើពួកគេមានទីលំនៅអចិន្ត្រៃយ៍នៅក្នុងប្រទេសកម្ពុជា ។ លើសពីនេះ មាត្រា ១១ នៃអនុក្រឹត្យនេះ បានចែងថា ស្ថានទូតកម្ពុជា មានតួនាទីជាមន្ត្រីអត្រានុកូលដ្ឋាន សម្រាប់ប្រជាពលរដ្ឋកម្ពុជាដែលរស់នៅក្រៅប្រទេស ។ ប៉ុន្តែជាក់ស្តែងត្រូវមានសេចក្តីណែនាំរួមមួយដែលឱ្យមានការពិភាក្សារវាងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីការអនុវត្តការងារនេះ ។

ទស្សនវិស័យមួយចំនួន នៃដំណើរការចុះបញ្ជីអត្រានុកូលដ្ឋានបច្ចុប្បន្ននេះ តម្រូវឱ្យមានការផ្លាស់ប្តូរ ដោយសារក្រមរដ្ឋប្បវេណីថ្មី ។ ក្រមច្បាប់ស្តីពីអត្រានុកូលដ្ឋានថ្មី គឺកំពុងស្ថិតក្នុងសេចក្តីព្រាងនៅឡើយដែលនឹងរួមបញ្ចូលទាំងអស់ពីដំណើរការ ការរៀបចំអត្តសញ្ញាណ រួមមាន លិខិតឆ្លងដែន សៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណផងដែរ ។

**អនុសមាសភាគ ក២ : មោដ្ឋារចនាសម្ព័ន្ធការចុះបញ្ជីអត្រានុកូលដ្ឋាន និងធនធាន**

យោងលើរចនាសម្ព័ន្ធនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានក្នុងប្រទេសកម្ពុជា សាលាឃុំ សង្កាត់ចំនួន ១,៦៣៣ បានបំពេញមុខងារជាកន្លែងចុះបញ្ជីអត្រានុកូលដ្ឋាននៅទូទាំងប្រទេស ។ មេឃុំ ចៅសង្កាត់ ដែលត្រូវ

បានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋរៀងរាល់ ៥ឆ្នាំម្តង មានមុខងារជាមន្ត្រីអត្រានុកូលដ្ឋាន។ ការិយាល័យអត្រានុកូលដ្ឋាន មាននៅថ្នាក់ ក្រុង ស្រុក ខណ្ឌ ថ្នាក់រាជធានី ខេត្ត និងថ្នាក់ជាតិ ប៉ុន្តែមានសាលាឃុំ សង្កាត់តែមួយគត់ដែលបំពេញមុខងារចុះបញ្ជីអត្រានុកូលដ្ឋាន។ ការយល់ដឹងជាទូទៅក្នុងចំណោមអ្នកពាក់ព័ន្ធ បង្ហាញថាកន្លែងចុះបញ្ជីមានការគ្រប់ដណ្តប់គ្រប់គ្រាន់ល្មម ក៏ប៉ុន្តែការខ្វះខាតពីការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃសំបុត្រកំណើត និងសំបុត្រមរណភាពក៏នៅមានច្រើន ដែលរាំងស្ទះដល់ភាពពេញលេញនៃការអនុវត្ត។

ស្របតាមជំពូកទី១២ នៃអនុក្រឹត្យលេខ១០៣ ថវិកាប្រចាំឆ្នាំសម្រាប់ធ្វើការបោះពុម្ពសំបុត្រ និងសៀវភៅអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល ត្រូវបានទទួលការវិភាជន៍ពីថ្នាក់ជាតិ ប៉ុន្តែមិនមានថវិកាវិភាជន៍សម្រាប់ធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអត្រានុកូលដ្ឋានជាទៀងទាត់ទេ។

ជំពូកទី១២ : អំពីថវិកា អត្រានុកូលដ្ឋាន

មាត្រា ៥៦ ចែងថា " ការបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាល អំពីការងារអត្រានុកូលដ្ឋានដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេសត្រូវស្ថិតក្នុងបន្ទុកថវិការដ្ឋ។ "

មាត្រា ៥៧ ចែងថា " ក្រសួងមហាផ្ទៃត្រូវលើកគម្រោងថវិកាប្រចាំឆ្នាំ សម្រាប់ការសុំបោះពុម្ពសៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងការបណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន។ "

មាត្រា ៥៨ ចែងថា " ការសុំចុះសំបុត្រអត្រានុកូលដ្ឋាន កំណើត និងមរណភាព អ្នកមកសុំមិនតម្រូវឱ្យបង់ថ្លៃអ្វីឡើយ។ ការសុំច្បាប់រៀបអាពាហ៍ពិពាហ៍ និងការចុះសំបុត្រអត្រានុកូលដ្ឋានអាពាហ៍ពិពាហ៍ ការសុំបញ្ជាក់កំណើត បញ្ជាក់អាពាហ៍ពិពាហ៍ និងបញ្ជាក់មរណភាព អ្នកសុំត្រូវបង់ថ្លៃក្រដាសតាមការកំណត់។ រាល់ការសុំចម្លង ឬ សម្រង់សំបុត្រអត្រានុកូលដ្ឋានអ្នកមកសុំត្រូវមកបង់ថ្លៃក្រដាស និងថ្លៃបិទតែមប្រ៊ី ដើម្បីជាប្រយោជន៍សម្រាប់ ឃុំ ឬសង្កាត់ និងចំណូលថវិការដ្ឋ។ ថ្លៃក្រដាសអត្រានុកូលដ្ឋាន និងថ្លៃតែមប្រ៊ីត្រូវកំណត់ដោយអនុក្រឹត្យ តាមសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ "

ការយល់ដឹងជាទូទៅ ខណៈពេលដែលមិនមានថវិកាវិភាជន៍សម្រាប់ការបណ្តុះបណ្តាល និងសម្ភារៈសម្រាប់ការងារអត្រានុកូលដ្ឋាន នៅក្នុងសេចក្តីណែនាំនាពេលកន្លងមកដែលទាក់ទងការងារអត្រានុកូលដ្ឋាន ត្រូវបានធ្វើការផ្សព្វផ្សាយជាសាធារណៈ តែការបណ្តុះបណ្តាលនៅទូទាំងប្រទេស ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ២០០២ និង២០០៥។ ទោះបីយ៉ាងណាក៏ដោយ ចាំបាច់ត្រូវធ្វើការវិភាជន៍ថវិកាឱ្យបានទៀងទាត់សម្រាប់សកម្មភាពបណ្តុះបណ្តាលនៅឯថ្នាក់ជាតិ ដូច្នេះវគ្គរំលឹកឡើងវិញ អាចត្រូវបានរៀបចំរៀងរាល់ឆ្នាំ។

ក្នុងឆ្នាំ២០១២ ដោយមានការគាំទ្រពីបណ្តាញរង្វាស់សុខភាពសុខាភិបាល (HMN) សៀវភៅណែនាំសម្រាប់បណ្តុះបណ្តាលការងារអត្រានុកូលដ្ឋាន ដែលគ្របដណ្តប់ទៅលើការចុះបញ្ជីកំណើត មរណភាព និងអាពាហ៍ពិពាហ៍ ត្រូវបានរៀបចំឡើងវិញ និងផ្តល់ការបណ្តុះបណ្តាលដល់ខេត្តចំនួន ០៥ ភ្ជាប់ជាមួយនឹងការបែងចែកសៀវភៅនេះផង។ ជំហានខាងមុខ សៀវភៅណែនាំនេះ ដោយភ្ជាប់ជាមួយនឹងការបណ្តុះបណ្តាល គួរត្រូវផ្តល់ឱ្យបានទូទាំងប្រទេស។

phak

**ចំណុចរាំងស្ទះ**

- មិនមានកាតព្វកិច្ចចែងក្នុងច្បាប់ដែលតម្រូវឱ្យមូលដ្ឋានសុខាភិបាល ធ្វើការរាយការណ៍ពីព្រឹត្តិការណ៍សំខាន់ៗ (កើត និងស្លាប់) នៃអត្រានុកូលដ្ឋាន
- មិនបាននិយាយអំពីថា តើនរណាជាអ្នកដែលបញ្ជាក់ពីមូលហេតុនៃការស្លាប់
- ស្ថិតិអត្រានុកូលដ្ឋាន ពីទិន្នន័យអត្រានុកូលដ្ឋាន មិនឃើញមានការគ្របដណ្តប់
- មុខងារ និងការទទួលខុសត្រូវនៃក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដូចជា ក្រសួងសុខាភិបាល និងក្រសួងផែនការ ចាំបាច់កំណត់ឱ្យបានច្បាស់លាស់។

**អនុសាសន៍**

ការពង្រឹងការងារអត្រានុកលដ្ឋាន ផ្អែកច្បាប់ គឺជាវិធីតែមួយគត់ ដើម្បីធានានិរន្តរភាព ស្ថិរភាព ភាពត្រឹមត្រូវ និងភាពទូលំទូលាយ នៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន។ ចំណុចជាអនុសាសន៍សំខាន់ៗខាងក្រោមនេះដែលបានស្នើដាក់បញ្ចូលទៅក្នុងក្របខណ្ឌច្បាប់ និងធនធានចាំបាច់មួយចំនួន សម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន សម្រាប់ព្រះរាជាណាចក្រកម្ពុជា :

**១.ការទទួលស្គាល់មុខងារស្ថិតិ និងទិន្នន័យនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន** : បច្ចុប្បន្ននេះ មិនមានស្ថិតិអត្រានុកូលដ្ឋានត្រូវបានយកមកប្រើប្រាស់ ឬគណនា ឬផលិត ដោយផ្អែកលើទិន្នន័យអត្រានុកូលដ្ឋានទេនៅក្នុងប្រទេសកម្ពុជា។ មន្ត្រីអត្រានុកូលដ្ឋានគ្រាន់តែផ្តល់នូវសេវាដែលមានតម្លៃ តាមរយៈការប្រមូល ចរិកលក្ខណៈបន្ថែមពីព្រឹត្តិការណ៍អត្រានុកូលដ្ឋានដែលពួកគេបានចុះបញ្ជីសម្រាប់គោលបំណងស្ថិតិតែប៉ុណ្ណោះ។ ការទទួលបានទិន្នន័យស្ថិតិដែលជាសមិទ្ធផលនៃដំណើរការរដ្ឋបាល គឺមានតម្លៃទាប ហើយត្រូវតែជៀសវាងនូវការប្រមូលទិន្នន័យស្ទួនៗគ្នាដោយភ្នាក់ងាររដ្ឋាភិបាលផ្សេងៗគ្នា។ តួនាទីនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋានទាមទារឱ្យមានការទទួលស្គាល់ដោយច្បាប់ និងមានធនធានគ្រប់គ្រាន់ ដោយគួរបង្កើតឱ្យមានការធានានូវនិរន្តរភាព និងប្រសិទ្ធភាព។ តួនាទី និងការទទួលខុសត្រូវរបស់ក្រសួងផែនការ នៅក្នុងការប្រមូល ចងក្រង និងបោះពុម្ពទិន្នន័យអត្រានុកូលដ្ឋាន គួរត្រូវបានកំណត់ឱ្យច្បាស់ និងបញ្ចូលទៅក្នុងច្បាប់ស្តីពីអត្រានុកូលដ្ឋាន។

**២.ការបញ្ចូលទិដ្ឋភាពសុខាភិបាលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានក្នុងក្របខណ្ឌច្បាប់:** ចំណុចនេះត្រូវបានផ្តល់អនុសាសន៍ថា ច្បាប់គួរបញ្ចូលការផ្តល់ព័ត៌មានចាំបាច់ពីមូលដ្ឋានសុខាភិបាលនៃព្រឹត្តិការណ៍សំខាន់ៗ (កើត និងស្លាប់) ដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាលទៅក្នុងប្រព័ន្ធចុះបញ្ជីអត្រានុ-កូលដ្ឋាន។ លើសពីនេះ របាយការណ៍ចាំបាច់ពីមូលដ្ឋានសុខាភិបាលគួរត្រូវបញ្ចូលទៅក្នុងច្បាប់ស្តីពីសុខភាពសាធារណៈ។ ពុំមានការលើកឡើងថាតើនរណាជាអ្នកទទួលខុសត្រូវលើការបញ្ជាក់មូលហេតុនៃការស្លាប់ទេ ច្បាប់តម្រូវឱ្យមានការបញ្ចូលនូវសមាសភាគមូលហេតុនៃការស្លាប់ ដែលចាំបាច់ត្រូវមានលិខិតបញ្ជាក់ពីវេជ្ជ-សាស្ត្រសម្រាប់មរណភាពទាំងអស់ដែលកើតឡើងនៅក្នុងមូលដ្ឋានសុខាភិបាល។

**៣.ការកំណត់ឱ្យច្បាស់ពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធផ្សេងៗ :** ក្របខណ្ឌច្បាប់គួរចែងឱ្យបានច្បាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ជាពិសេសក្រសួងសុខាភិបាល និង

phak

ក្រសួងផែនការ។ លើសពីនេះ ដោយភ្ជាប់ការចុះបញ្ជីមរណភាពជាមួយនឹងលិខិតអនុញ្ញាតបញ្ជូនសាកសពទៅកន្លែងបញ្ចុះ ឬជាមួយនឹងការផ្តល់ប្រាក់វិភាជន៍សម្រាប់បញ្ចុះ ដែលអាចលើកទឹកចិត្តដល់ការចុះបញ្ជីមរណភាពបានលឿន។ ការចូលរួមរបស់គ្រូពេទ្យ និងឆ្មប គួរមានកាតព្វកិច្ចរាយការណ៍ទៅមេឃុំ ចៅសង្កាត់ ពីព្រឹត្តិការណ៍សំខាន់ៗ (កើត និងស្លាប់)។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ ដែលមានមេភូមិ ជាជំនួយការ អាចជួយជំរុញឱ្យមានការចុះបញ្ជីយ៉ាងសកម្មផងដែរ។ ក្របខណ្ឌច្បាប់ គួរបង្កើតឱ្យមានជាកាតព្វកិច្ចសម្រាប់មន្ទីរពេទ្យទាំងអស់ និងមូលដ្ឋានសុខាភិបាល ដើម្បីរាយការណ៍ពីព្រឹត្តិការណ៍សំខាន់ៗ (កើត និងស្លាប់) ហើយព័ត៌មានទាំងនេះគួរត្រូវបានចែករំលែកជាមួយនឹងក្រសួងមហាផ្ទៃ។

**៤.គុណភាព និងភាពពេញលេញ នៃការបញ្ជាក់ពីមូលហេតុនៃការស្លាប់ :** រហូតមកទល់ពេលនេះនៅប្រទេសកម្ពុជា ការរាយការណ៍ពីមូលហេតុនៃការស្លាប់ គឺត្រូវបានបញ្ជាក់ដោយមន្ត្រីអត្រានុកូលដ្ឋាន (ពុំមានជំនាញពេទ្យ) ហើយសន្មត់ជាប្រភេទជំងឺដោយមិនដឹង។ ការអនុវត្តន៍ផ្តល់ឱ្យនូវព័ត៌មានមូលហេតុនៃការស្លាប់តិចតួចពីទស្សនៈវិស័យសុខភាពសាធារណៈ និងស្ថិតិអត្រានុកូលដ្ឋាន។ ថ្វីបើ ការអនុវត្តន៍ការបញ្ជាក់ផ្នែកវេជ្ជសាស្ត្រពីមរណភាពទាំងអស់មិនអាចធ្វើបានភ្លាមៗនោះ ការផ្លាស់ប្តូរក្របខណ្ឌច្បាប់ដើម្បីឱ្យមានការយល់ព្រមនូវការបញ្ជាក់វេជ្ជសាស្ត្រពីមូលហេតុមរណភាព (ជាពិសេស សម្រាប់អ្នកដែលបានស្លាប់នៅក្នុងមូលដ្ឋានសុខាភិបាល) ហើយនឹងការប្រើប្រាស់កោសល្យវិច័យផ្ទាល់មាត់ គឺជាជំហានដំបូងឆ្ពោះទៅការអនុវត្តដ៏ល្អប្រសើរក្នុងពេលណាមួយនៅកម្រិតមូលដ្ឋានដែលមរណភាពកើតឡើងជាយថាហេតុ។

**៥.ការបែងចែកធនធានឱ្យបានច្រើនសមស្រប :** សម្រាប់ការបណ្តុះបណ្តាល ការជ្រើសរើសបុគ្គលិក និងការរក្សាទុកនូវធនធានមនុស្ស។ លើសពីនេះ ធនធានសម្រាប់ប្រព័ន្ធព័ត៌មានវិទ្យាស្ថិតិ និងអត្រានុកូលដ្ឋាន ចាំបាច់ត្រូវមានប្រព័ន្ធទិន្នន័យស្ថិតិ និងអត្រានុកូលដ្ឋានជាតិមួយដែលជាគោល។ ការបណ្តុះបណ្តាលជាទៀងទាត់អំពីប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន និងកិច្ចសហប្រតិបត្តិជាមួយបុគ្គលិកសុខាភិបាលក្នុងសហគមន៍ជាតម្រូវការដ៏ចាំបាច់ ជាពិសេសអំពីមូលហេតុនៃមរណភាព តាមរយៈការធ្វើកោសល្យវិច័យផ្ទាល់មាត់ ។

## សមាសភាគ ខ : ការអនុវត្តក្នុងការចុះបញ្ជី ការគ្រប់ដណ្តប់ និងភាពពេញលេញ

### អនុសមាសភាគ ខ១- រចនាសម្ព័ន្ធ និងមុខងារនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន

មេឃុំ ចៅសង្កាត់ទូទាំង ១,៦៣៣ ឃុំ សង្កាត់ ត្រូវបានចាត់តាំងជាមន្ត្រីអត្រានុកូលដ្ឋានសម្រាប់អនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាននៅមូលដ្ឋាន។ ការចុះបញ្ជីអត្រានុកូលដ្ឋាននៅតែពឹងផ្អែកលើក្រដាស និងកត់ត្រាចូលក្នុងសៀវភៅភ្លោះ។

ដូចមានក្នុងគោលដៅរបស់ COIA ត្រឹមឆ្នាំ២០១៥ កម្ពុជាគួរមានភាពពេញលេញនៃការចុះបញ្ជីកំណើតឱ្យលើសចំនួន ៧៥% ។ ដូចមាននៅក្នុង CDHS 2010 ភាពពេញលេញនៃការចុះបញ្ជីកំណើតគឺចំនួន ៦២,១% សម្រាប់ក្មេងអាយុក្រោម៥ឆ្នាំ។ ចំពោះការចុះបញ្ជីមរណភាព គម្លាតគឺកាន់តែធំ ដូចមានចែងក្នុងគោលដៅ COIA។ ភាពពេញលេញនៃការចុះបញ្ជីមរណភាព និងការបញ្ជាក់ពីមូលហេតុនៃការស្លាប់គួរតែលើសចំនួន ៦០%។ ទោះជាយ៉ាង

phak

ណាក៏ដោយ ផ្អែកលើការប៉ាន់ប្រមាណរបស់ក្រសួងមហាផ្ទៃ ភាពពេញលេញនៃការចុះបញ្ជីមរណភាពតិចជាងចំនួន ១០% ដែលមានទិន្នន័យអាចជឿទុកចិត្តបាននូវភាពពេញលេញនៃការបញ្ជាក់មូលហេតុនៃការស្លាប់។

ការចុះបញ្ជីមរណភាពបង្ហាញថាមានប្រមាណតិចជាង ១០% បើផ្អែកទៅតាមការចុះបញ្ជីអត្រានុកូលដ្ឋានដែលមានសំបុត្រមរណភាពចំនួនតែ ៨៤.០០០សំបុត្រប៉ុណ្ណោះ ដែលបានផ្តល់ជូនចាប់តាំងពីឆ្នាំ២០០២-២០១២។ ប្រទេសកម្ពុជាអាចរំពឹងថា មានអ្នកស្លាប់ប្រហាក់ប្រហែលចំនួន ១១៣.៤០០នាក់ ក្នុងមួយឆ្នាំ ដោយប្រើប្រាស់ចំណោលប្រជាជនរបស់អង្គការសហប្រជាជាតិសម្រាប់អំឡុងពេល ២០០៥-២០១០ ជាមួយការចុះបញ្ជីមានត្រឹមប្រមាណ ៨.០០០នាក់ ជារៀងរាល់ឆ្នាំ។ ភាពពេញលេញអាចតិចជាងចំនួន ១០% (របាយការណ៍ប្រទេសកម្ពុជាដែលរៀបចំដោយសាកលវិទ្យាល័យឃ្វីនឡែន ខែសីហា ឆ្នាំ២០១២)។

យោងលើការវិវត្តន៍នៃប្រព័ន្ធអត្រានុកូលដ្ឋាននៅប្រទេសកម្ពុជា ប្រព័ន្ធនេះបានឆ្លងកាត់ដំណាក់កាលជាច្រើនពីឆ្នាំ ១៩៧៩-២០០២ ហើយសមិទ្ធផលនៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានពឹងផ្អែកទៅលើអាជ្ញាធរមូលដ្ឋាន និងគ្មានទម្រង់រួមមួយច្បាស់លាស់នៅទូទាំងប្រទេសសម្រាប់ការចុះបញ្ជីព្រឹត្តិការណ៍សំខាន់ៗនោះទេ។

នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០០ អនុក្រឹត្យលេខ ១០៣ អនក្រ.បក ត្រូវបានបង្កើតឡើង និងចាប់ផ្តើមអនុវត្តពីថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២។ អំឡុងពេលឆ្នាំ២០០២-២០០៤ មានចំនួន០៦ប្រភេទក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន ដែលក្នុងនោះកំណើត មរណភាព និងអាពាហ៍ពិពាហ៍ត្រូវបានចុះបញ្ជីដោយផ្អែកតាមពេលវេលាដែលកើតមានឡើងជាក់ស្តែងរួមមាន :

១. កំណើត : កំណើតដែលបានចុះបញ្ជីក្នុងរយៈពេល ៣០ថ្ងៃក្រោយកើត
២. បញ្ជាក់កំណើត : កំណើតដែលបានចុះបញ្ជីក្រោយ ៣០ថ្ងៃ បន្ទាប់ពីកើត
៣. មរណភាព : មរណភាពដែលចុះបញ្ជីក្នុងរយៈពេល ១៥ថ្ងៃ ក្រោយស្លាប់ ដែលស្លាប់ក្រោយថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២
៤. បញ្ជាក់មរណភាព : រាល់មរណភាពទាំងអស់ដែលកើតមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២
៥. អាពាហ៍ពិពាហ៍ : អាពាហ៍ពិពាហ៍ទាំងអស់ដែលចុះបញ្ជីក្នុងរយៈពេល ៣០ថ្ងៃក្រោយកើតហេតុ ដែលកើតឡើងក្រោយថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២
៦. បញ្ជាក់អាពាហ៍ពិពាហ៍ : អាពាហ៍ពិពាហ៍ទាំងអស់ដែលកើតមានមុនថ្ងៃទី០១ ខែសីហា ឆ្នាំ២០០២។

ក្នុងអំឡុងពេលឆ្នាំ ២០០៤-២០០៦ មរណភាពទាំងអស់ដែលចុះបញ្ជីក្រោយរយៈពេល ១៥ថ្ងៃ គឺត្រូវចុះបញ្ជីជាសំបុត្របញ្ជាក់មរណភាព។ ក៏ប៉ុន្តែ ចាប់ពីឆ្នាំ២០០៧ មកដល់បច្ចុប្បន្ន (២០១៣) ការបែងចែកប្រភេទនៃការបញ្ជាក់មរណភាព និងបញ្ជាក់អាពាហ៍ពិពាហ៍ត្រូវបានលុបបំបាត់ តែប្រភេទកំណើត និងបញ្ជាក់កំណើត (ចុះបញ្ជីក្រោយ៣០ថ្ងៃ) គឺនៅតែប្រើប្រាស់។

ចាប់ពីឆ្នាំ ២០០៤-២០០៦ យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅកម្ពុជាបានទទួលភាពជោគជ័យ និងបានជួយដល់ការជំរុញការចុះបញ្ជីកំណើត ពីចំនួន ៥% មុនយុទ្ធនាការឡើងទៅ ៩០% ក្រោយពេលយុទ្ធនាការ។ ក្នុងអំឡុង

phak

ពេលយុទ្ធនាការ ការចុះបញ្ជីអត្រានុកូលដ្ឋានចល័តរួមមានសំបុត្រកំណើត និងមរណភាពត្រូវបានផ្តល់ដោយឥតគិតថ្លៃ។ ក្រសួងមហាផ្ទៃ ដែលគាំទ្រដោយ ADB បានរៀបចំឱ្យមានការបណ្តុះបណ្តាលនៅទូទាំងប្រទេសលើការចុះបញ្ជីអត្រានុកូលដ្ឋានសម្រាប់ក្រុមការងារចល័ត។ លើសពីនេះ ADB បានផ្តល់ប្រាក់លើកទឹកចិត្តដល់ក្រុមចុះបញ្ជីចល័តចំនួន ៥ ដុល្លារសហរដ្ឋអាមេរិក ក្នុង១០០បញ្ជី។

សាលាឃុំ សង្កាត់ក៏បានជួយផ្សព្វផ្សាយពីសារៈសំខាន់នៃការចុះបញ្ជីអត្រានុកូលដ្ឋានដទៃទៀតដូចជា អាពាហ៍ពិពាហ៍ និងមរណភាព និងការចុះបញ្ជីត្រូវបានពិភាក្សាយ៉ាងទៀងទាត់នៅក្នុងកិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សាឃុំ។ ឃុំ សង្កាត់ខ្លះថែមទាំងផ្តល់ប្រាក់លើកទឹកចិត្តចំនួន ៥.០០០រៀល (ចំនួន ១,២៥ ដុល្លារសហរដ្ឋអាមេរិក) ដល់ការបញ្ចុះសពសមាជិកគ្រួសារ នៅពេលមានការចុះបញ្ជីមរណភាព។ ទោះបីយ៉ាងណាក៏ដោយ ការអនុវត្តនេះមិនទាន់ត្រូវបានបង្កើតឡើង ក៏គំនិតបានអនុវត្តរួចហើយដែលផ្តួចផ្តើមលើកឡើងពីក្រុមប្រឹក្សាឃុំ សង្កាត់។

នៅឆ្នាំ២០១៣ អង្គការ UNICEF កំពុងគាំទ្រដល់យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងតាមរយៈស្ព័តវិទ្យុ និងផ្ទាំងរូបភាពនៅទូទាំងប្រទេសដើម្បីលើកកំពស់ការយល់ដឹងទាក់ទងនឹងការចុះបញ្ជីកំណើត មរណភាព និងអាពាហ៍ពិពាហ៍។ សកម្មភាពនេះកំពុងតែអនុវត្ត ហើយលទ្ធផលនឹងត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ចំពោះអត្រាកំណើននៃការចុះបញ្ជីអត្រានុកូលដ្ឋាន។

ចាប់ពី ឆ្នាំ២០០៧ គ្រប់ឃុំ សង្កាត់មានគណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ (CCWC) ដែលមានសមាភាពដូចខាងក្រោម :

| | |
|---|---|
| មេឃុំ ឬចៅសង្កាត់ | ប្រធាន |
| ជំទប់ទី២ ឬចៅសង្កាត់រងទី២ | អនុប្រធាន |
| អ្នកទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ ឬសង្កាត់ | សមាជិកអចិន្ត្រៃយ៍ |
| ស្មៀនឃុំ ឬសង្កាត់ | សមាជិក |
| ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ឬសង្កាត់ | សមាជិក |
| នាយកសាលា ឬអ្នកតំណាង | សមាជិក |
| ប្រធានមណ្ឌលសុខភាព ឬអ្នកតំណាង | សមាជិក |
| មេភូមិ ឬអនុប្រធានភូមិ | សមាជិក |

គណៈកម្មាធិការទទួលបន្ទុកកិច្ចការស្ត្រី និងកុមារឃុំ សង្កាត់ (CCWC) ជួបប្រជុំជារៀងរាល់ខែដែលមានតំណាងពាក់ព័ន្ធទាំងអស់ទៅនឹង CRVS ដែលនេះគឺជាវេទិកាដ៏ល្អមួយ ក្នុងការគាំទ្រកំណើននៃភាពពេញលេញនៃការចុះបញ្ជីកំណើត និងមរណភាព។ នៅពេលដែលការចុះបញ្ជីកំណើត បានតភ្ជាប់ទៅនឹងតួនាទី និងការទទួលខុសត្រូវរបស់ CCWC។ ការចុះបញ្ជីមរណភាពទាមទារឱ្យមានការជួយគាំទ្រស្មើគ្នា ឬដូចៗគ្នា។

phaR

ផ្នែកមួយក្នុងអាណត្តិរបស់ CCWC ស្មៀនឃុំ សង្កាត់ ដោយសម្របសម្រួល និងសហការជាមួយមេភូមិ គឺទាមទារឱ្យមានការលើកទឹកចិត្តដល់ឪពុកម្តាយទាំងអស់ ដើម្បីចុះបញ្ជីកំណើត និងចូលរួមកិច្ចប្រជុំប្រចាំខែរបស់ CCWC ។ ស្មៀនឃុំ សង្កាត់គឺទាមទារឱ្យផ្តល់របាយការណ៍ស្តីពីការចុះបញ្ជីកំណើតដែលមានទម្រង់ដូចខាងក្រោម :

**<u>ទម្រង់សម្រាប់ការធ្វើរបាយការណ៍របស់ឃុំ សង្កាត់ក្នុងកិច្ចប្រជុំគណៈកម្មាធិការកិច្ចការស្ត្រី និងកុមារ ប្រចាំខែ</u>**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត/ក្រុង ៖...............
ស្រុក/ខណ្ឌ ៖............
ឃុំ/សង្កាត់ ៖.............

របាយការណ៍ចុះបញ្ជីកំណើត

ខែ...............ឆ្នាំ................

| ល.រ | បរិយាយ | ប្រុស | ស្រី | សរុប |
|---|---|---|---|---|
| ១ | ចំនួនទារកកើតក្នុងឃុំ/សង្កាត់ (ក្នុងខែនេះ) | | | |
| ២ | ចំនួនទារកចុះបញ្ជីក្នុងឃុំ/សង្កាត់ (ក្នុងខែនេះ) | | | |
| ៣ | ចំនួនភាគរយនៃទារកដែលចុះបញ្ជី (ក្នុងខែនេះ) | | | |

........ថ្ងៃទី......ខែ.......ឆ្នាំ.......
ហត្ថលេខា

ទោះបីជា CCWC ត្រូវបានបង្កើតឡើង និងជាស្ថាប័នជំនាញសម្រាប់សម្របសម្រួលរវាងអ្នកពាក់ព័ន្ធផ្សេងៗនៃ CRVS នៅថ្នាក់ឃុំ សង្កាត់ និងថ្នាក់ភូមិក៏ដោយ វានៅតែជាទំហំមួយដែលត្រូវវិភាគបន្ថែមនូវធនធានទៅលើសក្តានុពលនៃវេទិកានេះដើម្បីលើកកំពស់ការយល់ដឹងការចុះបញ្ជីកំណើត និងមរណភាព ។

## ការចុះបញ្ជីកំណើត

ការចុះបញ្ជីកំណើត គឺជាការតម្រូវដោយច្បាប់ ប៉ុន្តែកំណើតប្រហែលជាមិនបានចុះបញ្ជីរហូតដល់ក្មេងចូលសាលា និងការវាយតម្លៃទៅលើការរំពឹងទុកនៃកំណើតជាមួយនឹងកំណើតដែលបានចុះបញ្ជីរួច នេះបង្ហាញថាមានត្រឹមតែប្រមាណ ៦២,១% នៃកំណើតដែលបានចុះបញ្ជី (សម្រាប់ក្មេងក្រោមអាយុ៥ឆ្នាំ ដូចមានក្នុង CDHS ២០១០) ។ ការចុះបញ្ជីកំណើត គឺមិនមែនជាទម្រង់តែមួយក្នុងការកំណត់អត្តសញ្ញាណ ដែលត្រូវបានប្រើប្រាស់សម្រាប់តម្រូវការនៃការបញ្ជាក់អត្តសញ្ញាណនោះទេ។ កំណើតដែលបានរាប់បានមកពីការចុះបញ្ជីអត្រានុកូលដ្ឋានត្រូវបានប្រើប្រាស់ដោយនាយកដ្ឋានរដ្ឋបាលទូទៅ និងក្រុមប្រឹក្សាឃុំ ក៏ប៉ុន្តែមិនត្រូវបានប្រើជាស្ថិតិផ្លូវការ ឬដោយក្រសួងសុខាភិបាលសម្រាប់ការរៀបចំផែនការផ្នែកសុខាភិបាលនោះទេ។

ខាងក្រោមនេះ គឺជាដំណើរការចុះបញ្ជីកំណើត :

- ដើម្បីចុះបញ្ជីកំណើត គ្រួសារត្រូវផ្តល់លិខិតបញ្ជាក់ចេញពីមន្ទីរពេទ្យ ឬមេភូមិត្រូវចេញលិខិតបញ្ជាក់កំណើតជាភស្តុតាង។
- កំណើតត្រូវបានកត់ត្រាចូលទៅក្នុងសៀវភៅភ្លោះ (ដែលត្រូវធ្វើ ០១ច្បាប់ដើម្បីរក្សាទុកនៅសាលាស្រុក និង០១ច្បាប់ទៀត រក្សាទុកនៅសាលាខេត្ត រាល់ដំណាច់ឆ្នាំ)

phak

- កំណើតត្រូវបានចុះបញ្ជី ដោយឥតគិតថ្លៃក្នុងរវាង ៣០ថ្ងៃក្រោយកើត។ បន្ទាប់ពីរយៈពេលនេះ ការចុះបញ្ជីបង់សេវាចំនួន ១០.០០០រៀល ហើយកំណើតនេះត្រូវបានចុះក្នុងសៀវភៅបញ្ជាក់កំណើត។ ប៉ុន្តែនៅខេត្តចំនួន ០៥ តម្លៃនេះត្រូវបានបន្ថយមកត្រឹម ៣.០០០រៀល ដោយសារខេត្តទាំង០៥ នេះ ជាខេត្តដែលប្រជាជនមានចំណូលទាប។
- កំណើតត្រូវបានចុះបញ្ជីនៅទីលំនៅអចិន្ត្រៃយ៍។ ទីកន្លែងកើតជាក់ស្តែង (ដូចជាមន្ទីរពេទ្យ) មិនត្រូវបានកត់ត្រានោះទេ។ ក៏ប៉ុន្តែ នៅពេលដែលលិខិតបញ្ជាក់ពីមន្ទីរពេទ្យដែលផ្តល់ដោយឪពុកម្តាយ លិខិតនោះត្រូវរក្សាទុកជាមួយបញ្ជីកំណើត ក្នុងសៀវភៅក្រុមប្រឹក្សាឃុំ សង្កាត់។
- សំបុត្រកំណើតត្រូវបានចេញជូនដល់ប្រជាពលរដ្ឋដោយមេឃុំ ចៅសង្កាត់។




**ការចុះបញ្ជីមរណភាព:** ដំណើរការសម្រាប់កត់ត្រាការចុះបញ្ជីមរណភាព គឺស្រដៀងគ្នាទៅនឹងការចុះបញ្ជីកំណើត *( UQ Country Trip Report: Cambodia, August 2012):*

ការចុះបញ្ជីមរណភាពត្រូវបានកត់ត្រាក្នុងសៀវភៅភ្លោះដែលប្រើប្រាស់សម្រាប់តែការចុះបញ្ជីមរណភាព។ សៀវភៅមួយក្បាលត្រូវបានបញ្ជូនទៅសាលាស្រុក និងមួយក្បាលទៀតត្រូវបញ្ជូនទៅសាលាខេត្តនៅរៀងរាល់ដំណាច់

phak

ឆ្នាំ។ មរណភាពត្រូវតែចុះបញ្ជីក្នុងអំឡុងពេល១៥ថ្ងៃ ក្រោយពីស្លាប់។ បើការចុះបញ្ជីក្រោយអំឡុងពេលនេះ ប្រជាពលរដ្ឋត្រូវបង់សេវាចំនួន ៣.០០០រៀល។ ដោយឡែកការបង់សេវាចំនួន ១.០០០រៀល ត្រូវធ្វើឡើងនៅក្នុងខេត្តចំនួន០៥ ដែលប្រជាជនមានចំណូលទាប សម្រាប់ការចុះបញ្ជីមរណភាពយឺត។ ប្រសិនបើការចុះបញ្ជីមរណភាពឆ្លងឆ្នាំ តម្រូវឱ្យមានសាលក្រមពីតុលាការ។ ការចុះបញ្ជីមរណភាពបង្ហាញថា មានប្រមាណតិចជាង ១០% បើផ្អែកទៅតាមការចុះបញ្ជីអត្រានុកូលដ្ឋានដែលមាន សំបុត្រមរណភាពចំនួនតែ ៨៤.០០០សំបុត្រប៉ុណ្ណោះ ដែលបានផ្តល់ជូនចាប់តាំងពីឆ្នាំ២០០២-២០១២។ ប្រទេសកម្ពុជាអាចរំពឹងថា មានអ្នកស្លាប់ប្រហាក់ប្រហែលចំនួន ១១៣.៤០០នាក់ ក្នុងមួយឆ្នាំ ដោយប្រើប្រាស់ចំណោលប្រជាជនរបស់អង្គការសហប្រជាជាតិសម្រាប់អំឡុងពេល ២០០៥-២០១០ ជាមួយការចុះបញ្ជីមានត្រឹមប្រមាណ ៨.០០០នាក់ ជារៀងរាល់ឆ្នាំ។ ភាពពេញលេញអាចតិចជាងចំនួន ១០% (របាយការណ៍ប្រទេសកម្ពុជាដែលរៀបចំដោយសាកលវិទ្យាល័យឃ្វីនឡែន ខែសីហា ឆ្នាំ២០១២)។

• មរណភាពត្រូវបានកត់ត្រាផងដែរពីទីលំនៅអចិន្ត្រៃយ៍របស់អ្នកស្លាប់។ សេចក្តីលំអិតរបស់មន្ទីរពេទ្យគឺមិនត្រូវបានកត់ត្រា ប្រសិនបើស្លាប់ក្នុងមន្ទីរពេទ្យ។ ទោះបីជាយ៉ាងណាក៏ដោយ សៀវភៅចុះបញ្ជីមរណភាពគួរបានរក្សានូវច្បាប់ថតចម្លងបញ្ជាក់ពីមន្ទីរពេទ្យសម្រាប់ការចុះបញ្ជីមរណភាពមួយចំនួន។ ក៏ប៉ុន្តែផ្អែកតាមការអនុវត្តជាក់ស្តែងជារៀងរាល់ថ្ងៃមិនមានគ្រួសារទាំងអស់ដែលស្នើសុំ ឬទទួលបានទម្រង់បញ្ជាក់មរណភាពពីមន្ទីរពេទ្យនោះទេ។

• បញ្ហាមួយត្រូវបានរកឃើញ នៅពេលដែលប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ មិនអាចកត់ត្រាពីមូលហេតុនៃការស្លាប់ដែលបានពីមន្ទីរពេទ្យទៅក្នុងទម្រង់ចុះបញ្ជីមរណភាព ពីព្រោះសេចក្តីបញ្ជាក់នោះ គឺត្រូវបានសរសេរជាភាសាផ្សេង (ដូចជាភាសាអង់គ្លេស ឬបារាំង) ឬការសរសេររបស់វេជ្ជបណ្ឌិត គឺពិបាកអាន។ បញ្ជីជាច្រើនដែលត្រូវបានឃើញថាមានមូលហេតុនៃការស្លាប់ដូចជា ជរាពាទ ឬជំងឺ។

ក្នុងករណីខ្លះ សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សំបុត្រកំណើត ឬអត្តសញ្ញាណប័ណ្ណរបស់អ្នកស្លាប់ក៏ត្រូវបានទាមទារនៅពេលចុះបញ្ជីមរណភាព។ ក៏ប៉ុន្តែ ការអនុវត្តទាំងនេះគឺខុសគ្នាពីឃុំមួយទៅឃុំមួយ និងក្នុងករណីដែលគ្មានឯកសារទាំងនេះ គឺតម្រូវឱ្យមានសាក្សីក្នុងការរាយការណ៍។

• សំបុត្រមរណភាព គឺត្រូវបានចេញជូនគ្រួសារ ឬសាច់ញាតិសពដោយមេឃុំ ចៅសង្កាត់។

• វាមិនមានភាពជាក់ស្តែងណាមួយថា រាល់ការបញ្ចុះសពទាំងអស់គឺត្រូវបានធ្វើឡើងបន្ទាប់ពីមេឃុំ ឬចៅសង្កាត់ចេញសំបុត្រមរណភាពឱ្យប្រើប្រាស់នោះទេ។ សម្រាប់មរណភាពដែលកើតឡើងក្នុងមន្ទីរពេទ្យ ទោះបីជាមានការចូលរួមរបស់គ្រូពេទ្យ ឬមន្ត្រីពេទ្យផ្តល់នូវទម្រង់បញ្ជាក់ពីមូលហេតុនៃការស្លាប់ក៏ដោយ ក៏ទិន្នន័យទាំងនេះមិនមានភាពភ្ជាប់គ្នាទៅនឹងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជាទេ។ ក្នុងករណីជាច្រើន សមាជិកគ្រួសារមិនបានចុះបញ្ជីមរណភាពជាមួយមេឃុំ ទោះបីជាការស្លាប់ក្នុងមន្ទីរពេទ្យ និងទោះបីជាពួកគាត់ទៅចុះបញ្ជីមរណភាព ក៏មេឃុំមិនអាចបកប្រែពីមូលហេតុនៃការស្លាប់ចេញពីសេចក្តីបញ្ជាក់របស់មន្ទីរពេទ្យ ព្រោះសេចក្តីបញ្ជាក់របស់មន្ទីរពេទ្យតែងតែបំពេញជាភាសាបារាំង ឬមើលមិនដាច់ពីអក្សរដែលសរសេរដោយដៃ។

phaR

**ផ្អែកទៅតាមមាត្រា ៣៦ នៃអនុក្រឹត្យ ១០៣ ទាក់ទងនឹងការស្លាប់មិនតាមធម្មជាតិ :**

បើមានអ្នកស្លាប់ដោយមូលហេតុណាមួយ ដែលពាក់ព័ន្ធដល់ការមន្ទិលសង្ស័យ ដល់អំពើឃាតកម្មនៃបទល្មើសឧក្រិដ្ឋ មន្ត្រីអត្រានុកូលដ្ឋាន ឬជនទាំងឡាយណាដែលមានការពាក់ព័ន្ធត្រូវរាយការណ៍ភ្លាមដល់អាជ្ញាធរមានសមត្ថកិច្ច នៅកន្លែងដែលអ្នកនោះស្លាប់ ដើម្បីឱ្យសមត្ថកិច្ចជំនាញនានា ពិនិត្យស្រាវជ្រាវ និងដោះស្រាយឱ្យបានរួសរាន់។ ក្រោយពីមានការសម្រេចយ៉ាងណាពីភ្នាក់ងារមានសមត្ថកិច្ច ទើបមន្ត្រីអត្រានុកូលដ្ឋានអនុញ្ញាតឱ្យធ្វើបុណ្យបូជា ឬបញ្ចុះសពបាន។




បញ្ហាមួយដែលគួរកត់សម្គាល់ គឺមានការប្តេជ្ញាចិត្តក្នុងការបំពេញការងាររបស់មេឃុំតែមិនមានពេលវេលាគ្រប់គ្រាន់នៅសាលាឃុំសម្រាប់ការចុះបញ្ជី។ ជាលទ្ធផល ប្រជាពលរដ្ឋជាញឹកញាប់បានធ្វើដំណើរឆ្ងាយទៅចុះបញ្ជីកំណើត ឬមរណភាព និងត្រលប់មកវិញដោយគ្មានសំបុត្រកំណើត ឬមរណភាព។ អនុសាសន៍មួយដើម្បីដោះស្រាយបញ្ហានេះគឺការកំណត់ថ្ងៃចុះបញ្ជី ១ដងក្នុងមួយសប្តាហ៍ ដែលមេឃុំត្រូវនៅប្រចាំនៅសាលាឃុំ ហើយការងារនេះត្រូវផ្សព្វផ្សាយ

ជូនប្រជាពលរដ្ឋទាំងអស់ឱ្យបានដឹង ។ មេភូមិ មណ្ឌលសុខភាព និងអ្នកទទួលបន្ទុកកិច្ចការនារី និងកុមាររបស់ឃុំសង្កាត់ គួរចែករំលែកព័ត៌មាននេះឱ្យបានសកម្មដល់ប្រជាពលរដ្ឋ ។

ការស្នើសុំសេចក្ដីចម្លងសំបុត្រកំណើត ឬមរណភាព ដែលឆ្លងឆ្នាំ សមាជិកគ្រួសារតម្រូវឱ្យបង់សេវា ៥.០០០រៀល សម្រាប់សំបុត្រកំណើត ៥.០០០រៀល សម្រាប់សំបុត្រមរណភាព និង៥.០០០រៀល សម្រាប់សំបុត្រអាពាហ៍ពិពាហ៍ ។ ដោយឡែក ៣.០០០រៀល សម្រាប់ការស្នើសុំសេចក្ដីចម្លងត្រូវធ្វើឡើងនៅខេត្តចំនួន០៥ ដែលប្រជាជនមានចំណូលទាប ។ ប្រសិនបើការស្នើសុំចម្លងសំបុត្រអត្រានុកូលដ្ឋានស្ថិតនៅក្នុងឆ្នាំដែលកំពុងអនុវត្ត សេចក្ដីចម្លងនឹងស្នើនៅសាលាឃុំ សង្កាត់ ក៏ប៉ុន្តែសម្រាប់សេចក្ដីចម្លងដែលឆ្លងឆ្នាំ នោះការសុំសេចក្ដីចម្លង គឺត្រូវទៅធ្វើនៅសាលាក្រុង ស្រុក ខណ្ឌ ។

**អនុសមាគត ១២-ការត្រួតពិនិត្យឡើងវិញអំពីទម្រង់ដែលបានប្រើប្រាស់សម្រាប់ការចុះបញ្ជីកំណើត និងមរណភាព**

ទម្រង់ដែលប្រើប្រាស់សម្រាប់ចុះបញ្ជីកំណើត គឺមានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ និងទម្រង់ដែលប្រើប្រាស់សម្រាប់ចុះបញ្ជីមរណភាព គឺមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៣ ។ ប្រអប់ខាងក្រោម កំណត់ពីអនុសាសន៍របស់អង្គការសហប្រជាជាតិ និងចរិកលក្ខណៈដែលរួមបញ្ចូលក្នុងទម្រង់ចុះបញ្ជីកំណើត និងមរណភាពក្នុងប្រទេសកម្ពុជា ។

**ប្រអប់ ៣.២ : តារាងអនុសាសន៍នៃចរិកលក្ខណៈអាទិភាពខ្ពស់ដែលបញ្ចូលក្នុងព័ត៌មានរបស់អត្រានុកូលដ្ឋានកំណើត និងមរណភាព**

អង្គការសហប្រជាជាតិផ្ដល់អនុសាសន៍ថា ទិន្នន័យដែលប្រមូលក្នុងអំឡុងពេលចុះបញ្ជីកំណើត និងមរណភាពត្រូវបញ្ចូលចរិកលក្ខណៈរបស់ព្រឹត្តិការណ៍របស់ឪពុកម្ដាយ (ប្រសិនបើកំណើត) ឬនៃអ្នកស្លាប់(ប្រសិនបើមរណភាព) ។ ចរិកលក្ខណៈដែលបង្ហាញខាងក្រោមត្រូវបានជ្រើសរើស ពីព្រោះវាមានសក្ដានុពល និងប្រយោជន៍ខ្លាំងសម្រាប់គាំទ្រដល់គោលនយោបាយជាតិ និងកម្មវិធីអភិវឌ្ឍន៍ជាតិ រួមទាំងបង្កើត និងរក្សាតុល្យភាពថ្នាក់តំបន់ និងសកលលោក ។ ទោះបីជាតារាងនេះបានបង្ហាញពីលក្ខណៈសម្បត្តិដែលជាកត្តាចម្បងទាំងឡាយក៏ដោយ (ដែលអាចបង្កើតដោយឥតខ្ចោះភ្លាមៗនូវគោលបំណងមួយ) ក៏ប្រទេសជាច្រើននៅតែចង់ឱ្យមានការចាប់ផ្ដើមជាមួយនឹងបញ្ជីដែលខ្លីជាង ។ ជាឧទាហរណ៍ ដូចជាតារាងវែងស្ដីពីលក្ខណៈសម្បត្តិជារបស់ឪពុកម្ដាយប្រហែលជាមិនជាប់ទាក់ទងទៅនឹងប្រទេសមួយចំនួន ឬជាបន្ទុកធ្ងន់ធ្ងរពេក ។ លើសពីនេះ ព័ត៌មានមួយចំនួនត្រូវបានបង្កើតឡើងចេញពីព័ត៌មានផ្សេងទៀត និងមិនចាំបាច់លើកជាសំណួរទៀតនោះទេ ។ ប្រទេសជាច្រើនត្រូវបានជំរុញ និងលើកទឹកចិត្តក្នុងការកំណត់សម្គាល់នូវចំណុចអាទិភាពរបស់ខ្លួន ដោយផ្អែកលើតារាងដែលផ្ដល់ជូនដូចខាងក្រោមនេះ ។

ទោះបីជាប្រទេសនីមួយៗ ទាមទារឱ្យមានការចុះលេខបញ្ជីយ៉ាងណាក៏ដោយ ក៏ទីកន្លែងនៃការចុះបញ្ជីនេះ (ឬលេខកូដរបស់ការិយាល័យចុះបញ្ជី) និងឈ្មោះរបស់ប្រជាពលរដ្ឋទាំងនោះ ត្រូវបានកត់ត្រាទាក់ទងជាមួយព្រឹត្តិការណ៍អត្រានុកូលដ្ឋាន (១) ។

<table>
<tr><td colspan="2">កំណើតរស់</td></tr>
<tr><td>ចរិកលក្ខណៈរបស់ព្រឹត្តិការណ៍<br>• ថ្ងៃខែឆ្នាំកើត<br>• ថ្ងៃខែឆ្នាំចុះបញ្ជី<br>• ទីកន្លែងកើត<br>• ទីកន្លែងចុះបញ្ជី<br>• ទីកន្លែងកើតជាក់ស្តែង<br>• កើតនៅទីក្រុង ឬជនបទ<br>• ប្រភេទនៃកំណើត (មួយ ភ្លោះពីរ ភ្លោះបី ។ល។...)</td><td>ចរិកលក្ខណៈរបស់ឪពុកម្តាយ<br>• ថ្ងៃខែឆ្នាំកំណើត និងអាយុរបស់ឪពុកម្តាយ<br>• ស្ថានភាពគ្រួសាររបស់ឪពុកម្តាយ<br>• កម្រិតវប្បធម៌របស់ឪពុកម្តាយ<br>• ទីលំនៅអចិន្ត្រៃយ៍របស់ឪពុកម្តាយ<br>• ទីកន្លែងស្នាក់នៅ<br>• ទីលំនៅទីប្រជុំជន ឬជនបទ<br>• ម្តាយដែលផ្តល់កំណើតដល់កូនរស់ទាំងអស់ (មកដល់ពេលនេះ)<br>• ម្តាយដែលផ្តល់កំណើតដល់កូន ហើយនៅរស់<br>• ទារកស្លាប់ក្នុងផ្ទៃម្តាយ<br>• ថ្ងៃខែឆ្នាំដែលម្តាយផ្តល់កំណើតដល់កូនដែលរស់ចុងក្រោយ<br>• ថ្ងៃខែឆ្នាំ និងរយៈពេលរៀបអាពាហ៍ពិពាហ៍</td></tr>
<tr><td colspan="2">ចរិកលក្ខណៈរបស់កូន<br>• ភេទ<br>• ទំងន់ទារក</td></tr>
<tr><td colspan="2">មរណភាព</td></tr>
<tr><td>ចរិកលក្ខណៈរបស់ព្រឹត្តិការណ៍<br>• ថ្ងៃខែឆ្នាំស្លាប់<br>• ថ្ងៃខែឆ្នាំចុះបញ្ជី<br>• ទីកន្លែងស្លាប់<br>• ទីកន្លែងចុះបញ្ជី<br>• ទីកន្លែងស្លាប់ជាក់ស្តែង<br>• ស្លាប់នៅទីប្រជុំជន ឬជនបទ<br>• មូលហេតុនៃការស្លាប់<br>• អ្នកបញ្ជាក់ និងប្រភេទនៃការបញ្ជាក់</td><td>ចរិកលក្ខណៈរបស់អ្នកស្លាប់<br>• ថ្ងៃខែឆ្នាំកំណើត និងអាយុរបស់អ្នកស្លាប់<br>• ភេទ<br>• ស្ថានភាពគ្រួសារ<br>• ទីលំនៅអចិន្ត្រៃយ៍របស់អ្នកស្លាប់<br>• ទីលំនៅជាក់ស្តែងរបស់អ្នកស្លាប់<br>• ទីលំនៅរបស់អ្នកស្លាប់នៅទីប្រជុំជន ឬជនបទ</td></tr>
</table>

phak

វាជាការចាំបាច់ក្នុងការបង្កើតឱ្យមានទំនាក់ទំនងរវាងទម្រង់នៃការចុះបញ្ជីអត្រានុកូលដ្ឋាន និងទម្រង់ដទៃទៀតនៃការចុះបញ្ជី និងការផ្ដល់សេវាកម្ម ដូចជាប័ណ្ណពណិលឿង ដែលចេញដោយមណ្ឌលសុខភាពពេលទារកកើត។ គ្រួសារជាញឹកញាប់មិនបានយល់ដឹងពីភាពខុសគ្នារវាងបញ្ជីទាំងពីរ និងយល់ថាប័ណ្ណពណ៌លឿងមានតម្លៃស្មើសំបុត្រកំណើត។ ជាការចាំបាច់ណាស់សម្រាប់បង្កើតឱ្យមានការយល់ដឹងទូលំទូលាយដល់ប្រជាពលរដ្ឋ អំពីភាពខុសគ្នារវាងប័ណ្ណពណ៌លឿង និងសំបុត្រកំណើត ហើយបទប្បញ្ញត្តិត្រូវដាក់បញ្ចូលពីតម្រូវការនៃសំបុត្រកំណើតទាមទារព្រោះភាពចាំបាច់ និងការមិនអាចយកសំបុត្រកំណើតទៅផ្លាស់ប្ដូរ ជាមួយនឹងទម្រង់ចុះបញ្ជីដទៃទៀត ដូចជាប័ណ្ណពណ៌លឿងនោះទេ។

**អនុសមាសភាគ ខ៣- ការគ្របដណ្ដប់ និងភាពពេញលេញនៃការចុះបញ្ជីអត្រានុកូលដ្ឋាន**

បញ្ជីអត្រានុកូលដ្ឋានរបស់ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញទាំងស្រុងនៅសម័យប៉ុលពត ហើយរាជរដ្ឋាភិបាលកំពុងបង្កើតឱ្យមានការចុះបញ្ជីអត្រានុកូលដ្ឋានរបស់ខ្លួនឡើងវិញ។ បើផ្អែកតាមការអង្កេតប្រជាសាស្ត្រសុខាភិបាលឆ្នាំ២០០០ ភាគរយជាមធ្យមនៃកុមារដែលមានអាយុពី ០-៤ឆ្នាំ នៅកម្ពុជា ដែលកំណើតបានចុះបញ្ជីមានតែចំនួន ២២% ហើយអ្នកដែលមានសំបុត្រកំណើតមាន ២០,៩%។ តំបន់ទីប្រជុំជនមានអត្រាចុះបញ្ជីកំណើតខ្ពស់ (៣០%) ជាងតំបន់ជនបទដែលមាន (២១%)។

ទោះបីជាគ្មានការវាយតម្លៃផ្លូវការណាមួយពីភាពពេញលេញត្រូវបានធ្វើឡើងក៏ដោយ ដូចមាននៅក្នុង CDHS (២០១០) ភាពពេញលេញនៃការចុះបញ្ជីកំណើតក្រោមអាយុ៥ឆ្នាំ មានប្រមាណចំនួន ៦២,១%។ ការគ្របដណ្ដប់នៃការចុះបញ្ជីកំណើត គឺខ្ពស់បើធៀបទៅនឹងមរណភាព (ផ្អែកមួយដ៏ធំ គឺដោយសារយុទ្ធនាការចុះបញ្ជីកំណើតចល័តឆ្នាំ២០០៤-២០០៦ ដែលជាជំនួយរបស់អង្គការ UNICEF/PLAN) ការចុះបញ្ជីមរណភាពមានប្រហែលពី១០-៣០%បើផ្អែកតាមទិន្នន័យអត្រានុកូលដ្ឋាន។

ដំណើរការនៃការចុះបញ្ជីអត្រានុកូលដ្ឋាននៅកម្ពុជាបានចាប់ផ្ដើមនៅឆ្នាំ២០០២ ក៏ប៉ុន្តែរហូតដល់ឆ្នាំ២០០៤ មានតិចជាង ៥%នៃប្រជាពលរដ្ឋទាំងអស់ ស្មើនឹង ៦៤០.០០០នាក់ ដែលបានចុះបញ្ជី។ នៅខែតុលា ឆ្នាំ២០០៤ ក្រសួងមហាផ្ទៃបានបើកយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តទូទាំងប្រទេស។ ក្រុមការងារចល័តទាំងអស់ត្រូវបានបង្កើតឡើងដើម្បីចុះទៅតាមភូមិផ្សេងៗ និងធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានគ្រប់ប្រភេទ (អត្រានុកូលដ្ឋានកំណើត អាពាហ៍ពិពាហ៍ និងមរណភាព)។ ក្រុមចល័តសរុបមានចំនួន ១៣.០០០នាក់ សម្រាប់ធ្វើការចុះបញ្ជី។ ការចុះបញ្ជីអត្រានុកូលដ្ឋានចល័ត ជាលទ្ធផលសម្រេចបានជាង៩០%នៃអ្នកដែលគ្មានសំបុត្រកំណើត ដោយធ្វើការចុះបញ្ជីកំណើតទូទាំងប្រទេស តំណាងឱ្យអ្នកដែលបានចុះបញ្ជីកំណើតចំនួន ១១លាននាក់ នៅពេលដែលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តបានបញ្ចប់នៅចុងខែធ្នូ ឆ្នាំ២០០៦។ នេះគឺជាការកើនឡើងយ៉ាងខ្លាំងពី ៧០%នៃអត្រាចុះបញ្ជីកំណើត (តំណាងឱ្យ ៨,៦លាននាក់នៃអ្នកចុះបញ្ជី) ក្នុងខែធ្នូ ឆ្នាំ២០០៥ និងដែលមានកំណើន ៥% នៃអត្រាចុះបញ្ជីកំណើតនៅពេលចាប់ផ្ដើមយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តនៅខែតុលា ឆ្នាំ២០០៤ ( UNICEF, Policy note: accelerating Universal Birth Registration in Cambodia)។

phak

តាមរយៈយុទ្ធនាការចុះបញ្ជីចល័ត អង្គការ Plan International និង UNICEF បានគាំទ្រក្រសួងមហាផ្ទៃក្នុងយុទ្ធនាការលើកកំពស់ការយល់ដឹងសាធារណៈស្តីពីអត្រានុកូលដ្ឋាន រួមមាន ការផ្សព្វផ្សាយតាមទូរទស្សន៍ ផ្ទាំងរូបភាព និងវិទ្យុ ។

នៅពេលដែលយុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តត្រូវបានចាត់ទុកថាទទួលបានជោគជ័យភាគច្រើន តែជាលទ្ធផលដែលទទួលបានពីយុទ្ធនាការបានក្លាយទៅជាបញ្ហាប្រឈមនៅឆ្នាំ២០០៧។ ការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់នៅដើមឆ្នាំ ២០០៧ បានធ្វើឱ្យដំណើរការនៃសេវាចុះបញ្ជីកំណើតថយចុះ ក៏ដូចជាការប្រមូលទិន្នន័យ និងរបាយការណ៍របស់មន្ត្រីអត្រានុកូលដ្ឋាន ដែលពួកគាត់មួយចំនួនត្រូវបានផ្លាស់ប្តូរក្រោយពីការបោះឆ្នោត។ សេចក្តីណែនាំថ្មីរបស់ក្រសួងមហាផ្ទៃ ស្តីពីការចុះសៀវភៅអត្រានុកូលដ្ឋានឱ្យមាននិរន្តរភាពក្រោយបញ្ចប់យុទ្ធនាការចុះសៀវភៅអត្រានុ-កូលដ្ឋានចល័ត ដែលចែងលម្អិតពីតួនាទីនៃអាជ្ញាធរមូលដ្ឋានគ្រប់កម្រិតទាក់ទងនឹងការចុះបញ្ជីកំណើត ក៏ដូចជានីតិវិធីចុះបញ្ជីអត្រានុកូលដ្ឋានក្រោយយុទ្ធនាការចល័តដែលចេញដោយក្រសួងមហាផ្ទៃនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០០៧ បានផ្សព្វផ្សាយដល់មន្ត្រីអត្រានុកូលដ្ឋានទូទាំងប្រទេស ដោយមានការបណ្តុះបណ្តាលបន្តិចបន្តួច។ ទោះបីជាមានការផ្សព្វផ្សាយ និងបណ្តុះបណ្តាលក៏ដោយ ចំនួននៃការចុះបញ្ជីកំណើតនៅតែមានកម្រិតនៅឆ្នាំបន្តបន្ទាប់។ នៅឆ្នាំ២០០៦ ក្រសួងមហាផ្ទៃបានណែនាំដល់គ្រប់ថ្នាក់ដឹកនាំខេត្តទាំងអស់ ឱ្យប្រមូលទិន្នន័យប្រជាពលរដ្ឋអាយុក្រោម ១៨ឆ្នាំ ដែលបានចុះសំបុត្រកំណើត តែបច្ចុប្បន្នការប្រមូលព័ត៌មានតាមអាយុ និងភេទ គឺមិនបានអនុវត្តទេ។ ( *UNICEF, Policy note: accelerating Universal Birth Registration in Cambodia)*

ចំពោះការចុះបញ្ជីមរណភាព នាយកដ្ឋានរដ្ឋបាលទូទៅ (DoGA) បានបញ្ជាក់ថាការចុះបញ្ជីមរណភាព គឺមានចំនួនតិចនៅប្រទេសកម្ពុជា ដែលមានចំនួនតែ ៨៤.០០០សំបុត្រប៉ុណ្ណោះ ដែលបានផ្តល់ជូនចាប់តាំងពីឆ្នាំ២០០២-២០១២។ ប្រទេសកម្ពុជាអាចរំពឹងថា មានអ្នកស្លាប់ប្រហាក់ប្រហែលចំនួន ១១៣.៤០០នាក់ ក្នុងមួយឆ្នាំ ដោយប្រើប្រាស់ចំណោលប្រជាជនរបស់អង្គការសហប្រជាជាតិសម្រាប់អំឡុងពេល ២០០៥-២០១០ ជាមួយការចុះបញ្ជីមានត្រឹមប្រមាណ ៨.០០០នាក់ ជារៀងរាល់ឆ្នាំ។ ភាពពេញលេញអាចតិចជាងចំនួន ១០% (របាយការណ៍ប្រទេសកម្ពុជាដែលរៀបចំដោយសាកលវិទ្យាល័យឃ្វីនឡែន ខែសីហា ឆ្នាំ២០១២)។

ដូចមាននៅក្នុង CDHS ឆ្នាំ២០១០ មានតិចជាងពាក់កណ្តាលនៃកំណើត ក្នុងអំឡុងពេល ៥ឆ្នាំមុនការធ្វើអង្កេតបានសម្រាលនៅផ្ទះ និង៥៤% បានសម្រាលនៅមូលដ្ឋានសុខាភិបាល។ ចំនួនភាគរយនៃការសម្រាលនៅផ្ទះបានធ្លាក់ចុះក្នុងទស្សវត្សចុងក្រោយនេះដោយធ្លាក់ចុះពី ៨៩% នៃកំណើតក្នុងឆ្នាំ២០០០ មកត្រឹម ៧៨%ក្នុងឆ្នាំ២០០៥ និង ៤៥%ក្នុងឆ្នាំ២០១០។

ផ្អែកតាមកំណើនកំណើតក្នុងមូលដ្ឋានសុខាភិបាល វាតម្រូវឱ្យបង្កើតយន្តការមួយសម្រាប់មូលដ្ឋានសុខាភិបាលក្នុងការជូនព័ត៌មានទៅការិយាល័យអត្រានុកូលដ្ឋាន ស្តីពីកំណើតជារៀងរាល់ខែ។ លើសពីនេះ សម្រាប់សមាមាត្រកាន់តែច្រើននៃកំណើតនៅតែកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល អ្នកស្ម័គ្រចិត្តសុខាភិបាលសហគមន៍ និងមេភូមិអាចធ្វើជាអ្នកផ្តល់ព័ត៌មាន។

phat

មានព័ត៌មានដូចគ្នាមួយចំនួនស្តីពីព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ដែលត្រូវប្រមូលដោយក្រុមប្រឹក្សាឃុំ សង្កាត់ និង ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់។ ប៉ុប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ គឺត្រូវបានប្រគល់សិទ្ធិឱ្យមានភារកិច្ចធ្វើបច្ចុប្បន្នភាពសៀវភៅគ្រួសារ ហើយរបាយការណ៍របស់ប៉ូលីសត្រូវបញ្ជូនទៅក្រុមប្រឹក្សាឃុំ សង្កាត់ និងការិយាល័យរដ្ឋបាលក្រុង ស្រុកជារៀងរាល់ខែ រួមមានចំនួនប្រជាពលរដ្ឋអាយុក្រោម១៨ឆ្នាំ ដែលរស់នៅក្នុងឃុំ សង្កាត់ ចំនួនទារកទើបកើត និងចំនួនជនចំណាកស្រុក។

ខណៈពេលដែលតួនាទី និងការទទួលខុសត្រូវនៅថ្នាក់ជាតិ (នាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ) ការិយាល័យថ្នាក់ខេត្ត ក្រុង ស្រុក និងសាលាឃុំ សង្កាត់ត្រូវបានកំណត់យ៉ាងច្បាស់ ហើយទម្រង់នៃរបាយការណ៍ និងពេលវេលារាយការណ៍ក៏ត្រូវបានកំណត់ច្បាស់ផងដែរ តែការអនុវត្តមិនដូចគ្នាទេ។ ទោះបីមានការតាមដាន និងត្រួតពិនិត្យពីថ្នាក់ជាតិក៏ដោយ ក៏ខេត្តទាំងអស់មិនបានផ្ញើរបាយការណ៍ប្រចាំខែជាទៀងទាត់ដែរ ករណីនេះបណ្តាលមកពីការរាយការណ៍មិនទៀងទាត់របស់ឃុំ។ ស្មៀនឃុំមានបន្ទុកការងារច្រើន ហើយរបាយការណ៍ប្រចាំខែដែលត្រូវចងក្រងរួមមានចំនួនកំណើត ចំនួនមរណភាព និងអាពាហ៍ពិពាហ៍ ការប្រើប្រាស់សៀវភៅ សំបុត្រអត្រានុកូលដ្ឋាន និងសម្ភារៈផ្គត់ផ្គង់មិនត្រូវបានរៀបចំឱ្យបានទាន់ពេលកំណត់ទេ។

ប្រជាពលរដ្ឋភាគច្រើនខកខានមិនបានមកចុះបញ្ជីក្នុងប្រព័ន្ធអត្រានុកូលដ្ឋានទេ រួមមានប្រជាជនដែលរស់នៅតំបន់ដាច់ស្រយាល និងតំបន់ភ្នំ ប្រជាជនចំណាកស្រុក និងករណីចុះបញ្ជីមរណភាព ជាពិសេសនៅពេលដែលមានការចុះបញ្ជីយឺតដែលតម្រូវឱ្យមានសាលក្រមតុលាការ។ ការខិតខំប្រឹងប្រែងតម្រូវឱ្យមាន ដើម្បីធានាថាករណីទាំងនេះត្រូវបានកត់ត្រាទុកដ៏ត្រឹមត្រូវក្នុងប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋាន។

អត្ថប្រយោជន៍ និងកាលានុវត្តភាពដែលទម្រង់ផ្សេងៗនៃអត្តសញ្ញាណផ្លូវច្បាប់ប្រើប្រាស់ក្នុងប្រទេសកម្ពុជា ត្រូវតែមានភ្ជាប់មក ប៉ុន្តែមិនបានកម្រិត ឬតម្រូវឱ្យមានសំបុត្រកំណើតទេ :

- ការទទួលបានការងារធ្វើ
- ការប្រលងថ្នាក់ជាតិ
- ការបើកគណនីធនាគារ
- ការចូលប្រើប្រាស់សេវាប៉ូលីស
- ការចូលប្រើប្រាស់សេវាផ្នែកតុលាការ
- ការក្លាយទៅជាសមាជិកនៃសម្ព័ន្ធមួយ
- ការចុះបញ្ជីពាណិជ្ជកម្ម
- ការចូលបម្រើកងទ័ព
- ការបោះឆ្នោត
- ការបើកការិយាល័យសាធារណៈ
- ការទិញ ឬចុះបញ្ជីដីធ្លី និងទោចក្រយានយន្ត
- ការទទួលបានជំនួយពីរដ្ឋាភិបាល

phak

- ការធ្វើដំណើរទៅក្រៅប្រទេស ឬធ្វើការក្រៅប្រទេស
- ការទទួលបានឯកសារផ្សេងៗជាកម្មសិទ្ធ
- ការទទួលបានការការពារ ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ កំលាំងពលកម្មកុមារ និងការជួញដូរ
- ការទទួលបានការការពារពីតុលាការ

តាមសារីតា សៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ និងមានប្រយោជន៍យ៉ាងច្រើនជាឯកសារបញ្ជាក់អត្តសញ្ញាណ ក្នុងប្រទេសកម្ពុជា។ ផ្អែកតាមស្ថិតិរបស់ក្រសួងមហាផ្ទៃ នៅខែមិថុនា ឆ្នាំ២០០៥ ៩១% នៃប្រជាជនកម្ពុជាទាំងអស់ត្រូវបានកត់បញ្ចូលក្នុងសៀវភៅស្នាក់នៅ និង ៨៨% ត្រូវបានគ្រប់ដណ្តប់ដោយសៀវភៅគ្រួសារ។ សៀវភៅគ្រួសារដែលចេញដោយប៉ូលីសឃុំ គឺតាមដានយ៉ាងជិតដល់នូវសមាជិកគ្រួសារដែលមានដើមកំណើតជាខ្មែរជាមួយនឹងកូន។ សៀវភៅទាំងនេះកត់ត្រាឈ្មោះរបស់សមាជិកគ្រួសារម្នាក់ៗ។ សៀវភៅគ្រួសារមួយអាចមានព័ត៌មានលំអិតលើគ្រួសារដែលមានសមាជិកច្រើន ដូចជាបងប្អូន ឬកូនដែលមានគ្រួសាររៀងខ្លួនៗហើយរស់នៅជាមួយគ្នា។ គ្រួសារ ឈ្មោះសមាជិកក្នុងគ្រួសារត្រូវបានកត់ក្នុងសៀវភៅគ្រួសារ ដែលបញ្ចូលទៅជាក្រុមគ្រួសារ។ សៀវភៅស្នាក់នៅកត់ត្រាពីចំនួន និងអត្តសញ្ញាណរបស់មនុស្សដែលរស់នៅក្នុងដំបូលផ្ទះតែមួយ និងតាមដានពីចំនួន និងទីកន្លែងរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេស។ មិនដូចជាសៀវភៅគ្រួសារទេ សៀវភៅស្នាក់នៅមិនកំណត់ពីទំនាក់ទំនងក្នុងគ្រួសារ ឬសញ្ជាតិទេ។ វាគ្រាន់តែកត់ពីចំនួនប្រជាជនដែលរស់នៅទីកន្លែងជាក់លាក់មួយ។ មេគ្រួសារទាំងអស់ត្រូវមានម្នាក់ដែលទទួលខុសត្រូវ។ ឯកសារដ៏ទៃទៀតដែលអាចបម្រើដល់ការបង្កើតឱ្យមានអត្ថប្រយោជន៍ និងកាលានុវត្តភាពរួមមាន អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន ប័ណ្ណពណ៌លឿង និងសំបុត្រអាពាហ៍ពិពាហ៍ និងមរណភាព។

ក្នុងក្របខណ្ឌឧបសគ្គចម្បងក្នុងការចុះបញ្ជីដែលបានរកឃើញ ទោះបីជាមានទីកន្លែងចុះបញ្ជីគ្រប់គ្រាន់ក៏ដោយ ប៉ុន្តែមានការខ្វះខាតនូវធនធានមនុស្សក្នុងការអនុវត្តការងារចុះបញ្ជីអត្រានុកូលដ្ឋាន ពីព្រោះស្មៀនឃុំមានការងារច្រើន ហើយពុំសូវមានវត្តមាននៅសាលាឃុំ ឬគ្មានពេលគ្រប់គ្រាន់ដើម្បីផ្ញើរបាយការណ៍ប្រចាំខែទៅសាលាស្រុក។ លើសពីនេះតម្រូវឱ្យមានការបណ្តុះបណ្តាលជាទៀងទាត់ និងចែករំលែកបទពិសោធន៍លើការងារអត្រានុកូលដ្ឋាន និងបង្កើតឱ្យមានព័ត៌មានត្រលប់មកវិញ។ ដូចនេះសាលាឃុំត្រូវបានលើកទឹកចិត្តឱ្យរាយការណ៍ពីទិន្នន័យពេញលេញ នៅពេលដែលពួកគាត់ដឹងថាវាមានតម្លៃសម្រាប់គោលនយោបាយសាធារណៈ ហើយគុណភាពត្រូវបានត្រួតពិនិត្យ។

បញ្ហាពិបាកដោះស្រាយមួយទៀតពាក់ព័ន្ធនឹងអត្រានុកូលដ្ឋាន គឺការចុះបញ្ជីរបស់ប្រជាពលរដ្ឋដែលចំណាកស្រុក ព្រោះក្រសួងមហាផ្ទៃទាមទារឱ្យមានទីលំនៅអចិន្ត្រៃយ៍សម្រាប់ការចុះបញ្ជី ដូចនេះអាជ្ញាធរមិនអាចចុះបញ្ជីនូវព្រឹត្តិការណ៍សំខាន់ៗរបស់ជនចំណាកស្រុក ដោយសារតែគ្មានទីលំនៅអចិន្ត្រៃយ៍។

ដើម្បីទទួលបានភាពជោគជ័យលើការងារអត្រានុកូលដ្ឋាន គឺទាមទារឱ្យមានយុទ្ធសាស្ត្រច្បាស់លាស់ពីរ ពីព្រោះវាជាបញ្ហាទាំងខាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ។ ដូចនេះ ចំណុចសំខាន់ គឺតម្រូវការឱ្យមានយុទ្ធនាការការយល់ជាសាធារណៈអំពីការប្រើប្រាស់សំបុត្រអត្រានុកូលដ្ឋាន ដែលមានគោលដៅ គឺប្រជាពលរដ្ឋ។ សម្រាប់ការចុះបញ្ជីមរណភាព ការភ្ជាប់ការលើកទឹកចិត្តជាប្រាក់សម្រាប់បញ្ចុះសពអាចមានសារៈសំខាន់ក្នុងការជំរុញការចុះបញ្ជី។

**អនុសាសន៍ :**

១.ថ្ងៃចុះបញ្ជីប្រចាំសប្តាហ៍ : កំណត់ពេលមួយថ្ងៃក្នុងមួយសប្តាហ៍ជា " ថ្ងៃចុះបញ្ជីអត្រានុកូលដ្ឋាន " អំឡុងពេលនេះ មេឃុំនឹងប្រចាំការនៅសាលាឃុំដើម្បីចុះបញ្ជីព្រឹត្តិការណ៍អត្រានុកូលដ្ឋានពេញមួយថ្ងៃ។ ព័ត៌មាននេះតម្រូវឱ្យមានការជូនដំណឹងដល់ប្រជាពលរដ្ឋ មេភូមិ មណ្ឌលសុខភាព និងសមាជិក គកនក។

២. យុទ្ធនាការការយល់ដឹងជាសាធារណៈដើម្បីលើកទឹកចិត្តដល់ការចុះបញ្ជីកំណើត និងមរណភាព : យុទ្ធនាការទូទាំងប្រទេសក្នុងការលើកទឹកចិត្តការចុះបញ្ជីកំណើត និងមរណភាព ទាមទារឱ្យមានការផ្សព្វផ្សាយតាមរយៈវិទ្យុ ទូរទស្សន៍ និងផ្ទាំងរូបភាព។ លើសពីនេះ មេភូមិ គ.ក.ន.ក គ្រូបង្រៀន បុគ្គលិកសុខាភិបាលក្នុងសហគមន៍ឆ្មប គឺទាមទារឱ្យមានការលើកទឹកចិត្តគ្រប់ពេលវេលាលើការចុះបញ្ជីកំណើត និងមរណភាព។

៣. ការភ្ជាប់ការចុះបញ្ជីកំណើត និងមរណភាពទៅនឹងសេវា និងការលើកទឹកចិត្ត : ការចុះបញ្ជីកំណើត និងមរណភាពទាមទារឱ្យមានការតភ្ជាប់ទៅនឹងសេវាដទៃទៀតដែលនឹងត្រូវផ្តល់ជូនដោយរដ្ឋាភិបាល។ ដូចនេះតម្រូវការនៃការចុះបញ្ជីព្រឹត្តិការណ៍សំខាន់ៗត្រូវបានពង្រឹង ដូចជា ការចុះឈ្មោះចូលរៀន សោធន៍និវត្ត ការអនុញ្ញាតបញ្ចុះសព និងប្រាក់សេវាសង្គមដទៃទៀត។ លើសពីនេះ ការលើកទឹកចិត្តក្នុងការចុះបញ្ជីមរណភាពដោយផ្តល់នូវប្រាក់សម្រាប់បញ្ចុះសពអាចនឹងត្រូវបានពិចារណា ដើម្បីជំរុញអត្រាចុះបញ្ជីមរណភាព។

**អនុសមាសភាគ ១៤-ការរក្សាទុក និងការបញ្ជូនទិន្នន័យ**

ការិយាល័យចុះបញ្ជីនៅមូលដ្ឋាន កត់ត្រាព្រឹត្តិការណ៍សំខាន់ៗក្នុងសៀវភៅភ្លោះ។ ទស្សនទានក្នុងការប្រើប្រាស់សៀវភៅភ្លោះសម្រាប់ចុះបញ្ជី គឺដើម្បីកាត់បន្ថយជាអប្បបរមាក្នុងការបាត់បង់។

**ដូចមាត្រា ១៤ នៃអនុក្រឹត្យលេខ ១០៣** :"សៀវភៅអត្រានុកូលដ្ឋានតាមឆ្នាំនីមួយៗ ត្រូវបើកឱ្យប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែមករា ហើយត្រូវបញ្ឈប់នៅថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ។ នៅខែមករាឆ្នាំបន្ទាប់ មន្ត្រីអត្រានុកូលដ្ឋានត្រូវបញ្ជូនសៀវភៅតាមប្រភេទនីមួយៗ ០១ច្បាប់ ទៅសាលាស្រុក ឬខណ្ឌសាមី ដើម្បីត្រួតពិនិត្យ និងតម្កល់ទុកនៅទីនោះ និងបញ្ជូន ០១ច្បាប់ទៀតដែលដូចគ្នាទៅតម្កល់ទុកនៅតុលាការរាជធានី ឬខេត្តសាមី ដើម្បីមុខការតាមផ្លូវច្បាប់"។

មានតែទិន្នន័យដែលបានប្រមូលទេ ដែលត្រូវបញ្ជូនទៅការិយាល័យអត្រានុកូលដ្ឋានថ្នាក់កណ្តាល ហើយបច្ចុប្បន្នក្រសួងមហាផ្ទៃ ធ្វើការប្រមូលទិន្នន័យតាមភេទ ប៉ុន្តែមិនតាមអាយុទេ។

នៅឆ្នាំ២០០៩ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងទីភ្នាក់ងារអភិវឌ្ឍន៍ប្រទេសស៊ុយអ៊ែត (SIDA) បានគាំទ្រគម្រោងមួយសម្រាប់វាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានកំណើត និងបញ្ជាក់កំណើត ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាដែលសំបុត្រអត្រានុកូលដ្ឋានទាំងអស់ដែលបានអនុវត្តនៅក្នុងអំឡុងពេលពីឆ្នាំ២០០២ ដល់ ២០០៦។ សំបុត្រទាំងនេះត្រូវបានស្កេន ដោយតម្កល់ទុកជាមួយនឹងគ្រប់ទិន្នន័យទាំងអស់ទៅក្នុងប្រព័ន្ធទិន្នន័យអត្រានុកូលដ្ឋានថ្មី។ ការីបញ្ចូលទិន្នន័យចំនួន ៧៥នាក់ ត្រូវបានបណ្តុះបណ្តាល និងបញ្ចូលទិន្នន័យ ហើយចំនួនបញ្ជីជាង ៦លានបញ្ជី ត្រូវបាន

phat

វាយបញ្ចូលក្នុងប្រព័ន្ធទិន្នន័យអត្រានុកូលដ្ឋាន។ ការវាយបញ្ចូលសំបុត្រកំណើតកន្លងមកត្រូវបានកំណត់ជាអាទិភាពក្នុងប្រព័ន្ធនេះ ក៏ប៉ុន្តែនាពេលបច្ចុប្បន្ន ចាប់តាំងពីជំនួយត្រូវបានផ្អាក មជ្ឈមណ្ឌលទិន្នន័យអត្រានុកូលដ្ឋានបានដំណើរការតិចតួចបំផុត។

បញ្ជីត្រូវបានរក្សាទុកក្នុងសៀវភៅភ្លោះ និងគ្មានការ "Back Up" បញ្ជីទេ។ សៀវភៅត្រូវបានទុកដាក់តាមឆ្នាំចុះបញ្ជី និងឈ្មោះឃុំ។ ទោះជាមានពេលកំណត់សម្រាប់ការធ្វើរបាយការណ៍ត្រូវបានបង្កើតក៏ដោយ ក៏ការអនុវត្តមិនមានភាពតឹងរឹង ហើយការធ្វើរបាយការណ៍ពីរាជធានី ខេត្តជាច្រើន មិនបានតាមពេលកំណត់ដែរ ដូចជា :

ថ្ងៃទី៥ នៃខែបន្ទាប់ : ឃុំធ្វើរបាយការណ៍អត្រានុកូលដ្ឋានប្រចាំខែទៅសាលាស្រុក

ថ្ងៃទី១០ នៃខែបន្ទាប់: ស្រុកធ្វើរបាយការណ៍ដែលបានប្រមូលបញ្ជូនទៅសាលាខេត្ត

ថ្ងៃទី១៥ នៃខែបន្ទាប់: សាលាខេត្តធ្វើររបាយការណ៍ដែលបានប្រមូលបញ្ជូនទៅក្រសួងមហាផ្ទៃ។

កន្លងមកការធ្វើរបាយការណ៍ពីភូមិទៅឃុំ ត្រូវបានធ្វើឡើងដោយផ្ទាល់មាត់នៅពេលប្រជុំប្រចាំខែនៅឃុំ។ បច្ចុប្បន្នមានឃុំចំនួន៣២ ដែលអង្គការយូនីសេហ្វ កំពុងគាំទ្រការសាកល្បង ដែលមេភូមិត្រូវបានផ្តល់ឱ្យនូវសៀវភៅពណ៌លឿងសម្រាប់កត់ត្រាទិន្នន័យពីចំនួនកំណើត អាពាហ៍ពិពាហ៍ មរណភាព និងមូលហេតុនៃការស្លាប់សម្រាប់ប្រជាជនក្នុងភូមិ។ ពួកគាត់ តម្រូវឱ្យយកសៀវភៅពណ៌លឿងដែលបំពេញរួចទៅចូលរួមកិច្ចប្រជុំប្រចាំខែនៅថ្នាក់ឃុំ ហើយមេភូមិអាចដើរតួនាទីជាអ្នកផ្តល់ព័ត៌មានពីកំណើត អាពាហ៍ពិពាហ៍ និងមរណភាព។ នេះអាចក្លាយជាសេចក្តីយោងដោយមានចំនួនតួលេខពិតប្រាកដនៃព្រឹត្តិការណ៍សំខាន់ៗដែលបានចុះបញ្ជីក្នុងអំឡុងពេលដូចគ្នា។ បច្ចុប្បន្ននេះ គ្មានការអនុវត្តការត្រួតពិនិត្យទិន្នន័យទេ ហើយតម្រូវឱ្យមានការបង្កើតយន្តការក្នុងការត្រួតពិនិត្យ និងវាយតម្លៃយ៉ាងទៀងទាត់។

**កត្តារាំងស្ទះ :**

- ទោះជាកន្លែងចុះបញ្ជីមានគ្រប់គ្រាន់ក៏ដោយ ដោយសារមេឃុំការងារច្រើន មេឃុំមិនអាចអនុវត្តការចុះបញ្ជីអត្រានុកូលដ្ឋានបានជាប់លាប់ទេ
- ការចុះបញ្ជីមរណភាពនៅតែមានចំនួនទាប ហើយវាមានការចាំបាច់ដើម្បីលើកកំពស់ការយល់ដឹង និងការភ្ជាប់ការចុះបញ្ជីអត្រានុកូលដ្ឋានមរណភាពជាមួយនឹងការលើកទឹកចិត្ត ឬការផ្តល់សេវា ដូចជា ប្រាក់សម្រាប់បញ្ចុះសព... ។ល។
- ប្រព័ន្ធចុះបញ្ជី គឺប្រើប្រាស់ក្រដាសជាគោល ហើយមានរយៈពេលកំណត់ក្នុងការធ្វើរបាយការណ៍ពីការិយាល័យមូលដ្ឋាន និងតំបន់ទៅកាន់ការិយាល័យកណ្តាល។ ការពង្រីកប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន គឺជាតម្រូវការមួយចាំបាច់បំផុត។

**អនុសាសន៍ :**

១. ថ្ងៃចុះបញ្ជីប្រចាំសប្តាហ៍ : កំណត់មួយថ្ងៃក្នុងមួយសប្តាហ៍ជាថ្ងៃចុះបញ្ជីអត្រានុកូលដ្ឋាន ហើយនៅថ្ងៃនោះមេឃុំត្រូវនៅប្រចាំការនៅសាលាឃុំដើម្បីចុះបញ្ជីពេញមួយថ្ងៃ។ ព័ត៌មាននេះត្រូវតែចែករំលែកដល់ប្រជាពលរដ្ឋ មេភូមិ មណ្ឌលសុខភាព និងសមាជិក គ.ក.ន.ក។

phaR

២. **ការវាយបញ្ចូលទិន្នន័យអត្រានុកូលដ្ឋានទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា** : ដោយមានការគាំទ្រពីអង្គការ USAID អង្គការ URC បានគាំទ្រក្រសួងមហាផ្ទៃ ក្នុងការអនុវត្តសាកល្បងនៃការវាយបញ្ចូលទិន្នន័យតាមប្រព័ន្ធព័ត៌មានវិទ្យាក្នុងឃុំ សង្កាត់ចំនួន១១ ដែលមានទម្រង់តែមួយ។ ការសាកល្បងនេះអនុញ្ញាតដល់ការវាយបញ្ចូលទិន្នន័យសម្រាប់ព្រឹត្តិការណ៍សំខាន់ៗទាំងអស់ និងការបង្កើតរបាយការណ៍ប្រចាំខែព្រមទាំងស្ថិតិអត្រានុកូលដ្ឋានសម្រាប់នៅគ្រប់កម្រិត។ លើសពីនេះ ទិន្នន័យស្ថិតិអត្រានុកូលដ្ឋានដែលបានចុះក្នុងប្រព័ន្ធ អាចត្រូវបានប្រើប្រាស់ភ្លាមៗដោយអាជ្ញាធរមានសមត្ថកិច្ច។ ការសាកល្បងនេះតម្រូវឱ្យមានការវាយតម្លៃ និងសក្តានុពលសម្រាប់ពង្រីកទូទាំងប្រទេស។

៣. **ប្រាក់វិភាជន៍ និងការបណ្តុះបណ្តាល** : នេះគឺជាតម្រូវការមួយក្នុងការបែងចែកថវិកាទៅសាលាឃុំ សង្កាត់សម្រាប់ការងារដែលពាក់ព័ន្ធនឹងការងារស្ថិតិអត្រានុកូលដ្ឋាន ដើម្បីធានាដល់ភាពគ្រប់គ្រាន់ផ្នែកផ្គត់ផ្គង់សំបុត្រអត្រានុកូលដ្ឋាន តែមប្រិ៍ដែលទាមទារសម្រាប់ការចម្លងសំបុត្រអត្រានុកូលដ្ឋាន និងតម្លៃផ្នែករដ្ឋបាលផ្សេងៗ។ ទោះបីជាធនធានមនុស្សមាននៅសាលាឃុំ សង្កាត់សម្រាប់ការងារអត្រានុកូលដ្ឋានក៏ដោយ ក៏ទាមទារឱ្យមានការបណ្តុះបណ្តាលឱ្យបានល្អប្រសើរ។ ការបណ្តុះបណ្តាលប្រចាំឆ្នាំ និងសិក្ខាសាលាត្រូវតែធ្វើឡើង ដើម្បីធានាដល់ភាពទៀងទាត់ក្នុងការចុះបញ្ជី និងធ្វើរបាយការណ៍ស្តីពីព្រឹត្តិការណ៍សំខាន់ៗ ព្រមទាំងផ្តល់របាយការណ៍អត្រានុកូលដ្ឋានប្រចាំខែឱ្យទាន់ពេលវេលា។

៤. **ការសម្របសម្រួលពីអន្តរក្រសួង**: វាក៏ជាតម្រូវការមួយក្នុងការលើកទឹកចិត្តឱ្យមានកិច្ចសហប្រតិបត្តិការ និងការទំនាក់ទំនងរវាងមណ្ឌលសុខភាព និងសាលាឃុំ សង្កាត់។ មណ្ឌលសុខភាពអាចចែករំលែករបាយការណ៍ពីចំនួនកំណើត និងមរណភាព ដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល ហើយការចែករំលែកនេះអាចមានប្រយោជន៍ក្នុងការកំណត់ពីគម្លាតក្នុងការចុះបញ្ជីអត្រានុកូលដ្ឋាន។

៥. **ការត្រួតពិនិត្យគុណភាពទិន្នន័យជាទៀងទាត់** : នាពេលបច្ចុប្បន្ន គ្មានការត្រួតពិនិត្យទៀងទាត់ត្រូវបានធ្វើនៅសាលាឃុំ សង្កាត់ទេ វាក៏ជាតម្រូវការមួយសម្រាប់បង្កើតឱ្យមានការត្រួតពិនិត្យទៀងទាត់ដោយសាលារាជធានី ខេត្ត។ វាក៏មានសារៈសំខាន់ក្នុងការទទួល និងផ្តល់ព័ត៌មានត្រលប់ ព្រមទាំងលើកទឹកចិត្តឱ្យមានការរាយការណ៍បានទាន់ពេលវេលាដោយឃុំ សង្កាត់ផងដែរ។

៦. **ការភ្ជាប់ការចុះបញ្ជីកំណើត និងមរណភាពទៅកាន់ទម្រង់ និងសេវាដទៃទៀត** : វាជាតម្រូវការក្នុងការភ្ជាប់ការចុះបញ្ជីកំណើត និងមរណភាពទៅកាន់ទម្រង់ចុះបញ្ជី និងសេវាដទៃ ដូចជាសៀវភៅគ្រួសារ សៀវភៅស្នាក់នៅ ការអនុញ្ញាតបញ្ចុះសព ការចុះឈ្មោះចូលរៀន ។ល។ ជាការលើកទឹកចិត្តដល់ការចុះបញ្ជីមរណភាព ដូចជាការផ្តល់ប្រាក់បញ្ចុះសពដល់ក្រុមគ្រួសារអាចមានប្រយោជន៍ដល់ការជំរុញឱ្យមានការចុះបញ្ជីមរណភាពបានទាន់ពេលវេលា។

## សមាសភាគ គ : សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់

សំបុត្របញ្ជាក់មូលហេតុនៃការស្លាប់ គឺជាទិដ្ឋភាពមួយរបស់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋានដែលត្រូវបានគេមិនយកចិត្តទុកដាក់ក្នុងប្រទេសកម្ពុជា។ មូលហេតុមួយផ្នែក គឺការចុះបញ្ជីសំបុត្រមរណភាពត្រូវធ្លាក់ទៅលើនាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ តែអ្នកជំនាញពិតប្រាកដ គឺក្រសួងសុខាភិបាល (សម្រាប់លិខិត

phak

បញ្ជាក់មរណភាពដែលស្លាប់នៅមន្ទីរពេទ្យធ្វើដោយវេជ្ជបណ្ឌិត និងដោយមន្ត្រីសុខាភិបាលតាមរយៈការប្រើប្រាស់ការធ្វើអង្កេតសាកសួរផ្ទាល់មាត់សម្រាប់មរណភាពនៅក្នុងសហគមន៍)។ ដើម្បីបោះជំហានដ៏សំខាន់មួយក្នុងការធ្វើឱ្យប្រសើរឡើងនូវមូលហេតុនៃការស្លាប់ (COD)។ វាមានសារៈសំខាន់ណាស់ ដែលវិស័យសុខាភិបាលត្រូវទទួលខុសត្រូវលើការអនុវត្តការចេញសំបុត្របញ្ជាក់មូលហេតុនៃការស្លាប់ (COD) និងត្រូវរៀបចំពង្រឹងដល់ការគាំទ្រការអភិវឌ្ឍន៍ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) នាពេលអនាគត រួមមាន :

- ធានាថាប្រព័ន្ធសុខាភិបាលត្រូវបានពង្រឹង ដើម្បីគាំទ្រដល់ការចេញលិខិតបញ្ជាក់ពីកំណើត និងមរណភាពក្នុងមូលដ្ឋានសុខាភិបាលរបស់ខ្លួន និង
- ធានាថាប្រព័ន្ធសុខាភិបាលអាចបង្កើតព័ត៌មានមូលហេតុនៃការស្លាប់ តាមរយៈលិខិតបញ្ជាក់ផ្នែកវេជ្ជសាស្ត្រ និងរយៈពេលអន្តរកាល ដូចជាការធ្វើការអង្កេតសាកសួរផ្ទាល់មាត់។

  ដូច្នេះ អនុសាសន៍ជាច្រើន គឺថាទិដ្ឋភាពសុខាភិបាលក្នុងប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រាកូលដ្ឋាន (CRVS) ត្រូវបញ្ចូលទៅក្នុងក្របខណ្ឌច្បាប់សម្រាប់ប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រាកូលដ្ឋាន (CRVS) នៅកម្ពុជា ជាពិសេស ការបញ្ជាក់ជាចាំបាច់នៃព្រឹត្តិការណ៍អត្រានុកូលដ្ឋានពីមូលដ្ឋានសុខាភិបាលទៅកាន់ការិយាល័យអត្រានុកូលដ្ឋាន ព្រមទាំងការបញ្ជាក់មូលហេតុនៃការស្លាប់តាមវេជ្ជសាស្ត្រសម្រាប់មរណភាពទាំងអស់ដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល។

**អនុសមាសភាគ គ១ : ការអនុវត្ត និងអនុលោមទៅតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD សម្រាប់សំបុត្រមរណភាព**

មូលហេតុនៃការស្លាប់ក្នុងសំបុត្រមរណភាពនៅពេលចុះបញ្ជីមរណភាព ត្រូវបានកត់ត្រាទុកដោយមន្ត្រីអត្រានុកូលដ្ឋានដោយផ្អែកលើរបាយការណ៍ពីគ្រួសារ។ ព័ត៌មានទាំងនេះ មិនត្រូវបានចងក្រង និងភាគច្រើនពុំបានកំណត់មូលហេតុនៃការស្លាប់ទេ។

ចរិកលក្ខណៈទូទៅនៃសំបុត្រមរណភាពប្រើប្រាស់ក្នុងប្រទេសកម្ពុជា គឺមិនស្របទៅនឹងទម្រង់វេជ្ជសាស្ត្រជាអន្តរជាតិនៃមូលហេតុនៃការស្លាប់ទេ។ វាបានផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ទម្រង់វេជ្ជសាស្ត្រជាអន្តរជាតិនៃមូលហេតុនៃការស្លាប់ ពីព្រោះនេះអាចអនុញ្ញាតដល់ការបញ្ជាក់ពីមូលហេតុនៃការស្លាប់ និងដែលស្របទៅនឹងចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) សម្រាប់សំបុត្រមរណភាព។

សម្រាប់មរណភាពដែលកើតឡើងក្នុងមូលដ្ឋានសុខាភិបាល ទម្រង់លិខិតចម្លងបញ្ជាក់មរណភាពចំនួន ០២ច្បាប់ត្រូវបានធ្វើឡើង។ មួយសម្រាប់គ្រួសារដែលប្រើប្រាស់សម្រាប់បញ្ចុះសព (ក្នុងការអនុវត្ត គឺត្រូវបានធ្វើឡើងជាបណ្តោះអាសន្ន និងមិនត្រូវបានអនុវត្តពេញលេញទេ) និងទម្រង់មួយទៀត ដែលរក្សាទុកនៅមន្ទីរពេទ្យ។ ប្រសិនបើមរណភាពនៅក្រៅមន្ទីរពេទ្យ ទាមទារឱ្យមានទម្រង់បញ្ជាក់ពីសាលាឃុំ។

លិខិតបញ្ជាក់ពីមូលហេតុនៃការស្លាប់ គឺមិនមានគ្រប់គ្រាន់ទេ ហើយមានតែ ១២% នៃមរណភាពទាំងអស់ ដែលទំនងជាមានការបញ្ជាក់ផ្នែកវេជ្ជសាស្ត្រពីមូលហេតុនៃការស្លាប់។ មរណភាពទាំងនេះ ត្រូវបានកត់ត្រាតាមរយៈប្រព័ន្ធសុខាភិបាល និងភាគច្រើនពីមន្ទីរពេទ្យសាធារណៈ (Public Establishment)។ មានមន្ទីរពេទ្យឯកជនតិចតួច

phak

ប៉ុណ្ណោះដែលរាយការណ៍ពីព្រឹត្តិការណ៍អត្រានុកូលដ្ឋាន ទៅក្រសួងសុខាភិបាល។ ក្នុងទំនាក់ទំនងទៅនឹងការប្រមូលផ្នែកបញ្ជីអត្រានុកូលដ្ឋាន វាជាការកត់សម្គាល់ថាប្រព័ន្ធសុខាភិបាលអាចប្រមូលព័ត៌មានស្តីពីកំណើត និងមរណភាពពីទិន្នន័យសុខាភិបាលសាធារណៈ ជាមួយនឹងការរាយការណ៍ពីវិស័យឯកជនដែលមានតិចតួច។

**អនុសមាភាគ គ២- លិខិតបញ្ជាក់មរណភាពរបស់មន្ទីរពេទ្យ**

សម្រាប់អ្នកស្លាប់នៅមូលដ្ឋានសុខាភិបាល គ្រូពេទ្យជាអ្នកកំណត់មូលហេតុនៃការស្លាប់ដោយបញ្ជាក់តាមផ្នែកវេជ្ជសាស្ត្រ ហើយដែលមានតែ ១២% នៃមរណភាពទាំងអស់ប៉ុណ្ណោះទូទាំងប្រទេស ក៏ប៉ុន្តែទិន្នន័យនេះមិនបានភ្ជាប់ទៅប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) ពេលបច្ចុប្បន្ននេះទេ។ *(UQ Country Trip Report Cambodia August 2012).*

នៅពេលដែលមរណភាពកើតឡើងក្នុងមន្ទីរពេទ្យ វេជ្ជបណ្ឌិតនឹងសរសេរនូវព័ត៌មាន (រួមមានមូលហេតុនៃការស្លាប់) ក្នុងសៀវភៅចុះបញ្ជីតាមផ្នែកនីមួយៗក្នុងមន្ទីរពេទ្យ (ward register book)។ ព័ត៌មាននេះត្រូវបានផ្ទេរទៅក្នុងទម្រង់លិខិតបញ្ជាក់មរណភាព។ លេខកូដព័ត៌មាន ដែលផ្តល់ដោយក្រសួងសុខាភិបាល (មិនមែនកូដរបស់ចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD ទេ) គឺត្រូវបានបកប្រែចេញពីសៀវភៅចុះបញ្ជីតាមផ្នែកនីមួយៗក្នុងមន្ទីរពេទ្យ (Ward Register book)។ ដើម្បីប្រមូលទិន្នន័យពីមន្ទីរពេទ្យ ព័ត៌មានបានពីសៀវភៅចុះបញ្ជីតាមផ្នែកនីមួយៗក្នុងមន្ទីរពេទ្យ (ward Register book) ត្រូវបានរាប់ដោយគិលានុបដ្ឋាយិការ និងរបាយការណ៍ប្រចាំខែត្រូវបានរៀបចំ។ ព័ត៌មានទាំងនេះត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល " Web-based " របស់ក្រសួងសុខាភិបាល។ ករណីមរណភាពពេលមកដល់មន្ទីរពេទ្យ មិនត្រូវបានបញ្ជាក់ដោយវេជ្ជបណ្ឌិតទេ តែក្នុងករណីមួយចំនួនដែលមានការស្នើសុំដោយគ្រួសារ នោះគណៈកម្មការត្រូវបានបង្កើតឡើងនៅមន្ទីរពេទ្យ ដោយផ្អែកលើការកត់ត្រាប្រវត្តិព័ត៌មាន និងការព្យាបាលពីមុន ហើយមូលហេតុនៃការស្លាប់ (COD) ត្រូវបានកំណត់។

ក្រសួងសុខាភិបាលកំពុងចាត់វិធានការតម្រឹម និងពង្រីកប្រព័ន្ធ " web-based " គ្រប់គ្រងព័ត៌មានសុខាភិបាល (HMIS) ដែលត្រូវបានប្រើប្រាស់ដោយមូលដ្ឋានសុខាភិបាលសាធារណៈច្រើនជាង ១.០០០ រួមមាន មន្ទីរពេទ្យសាធារណៈ ៩៥ និងជិត២០០មន្ទីរពេទ្យឯកជនដែលត្រូវរាយការណ៍ប្រចាំខែជាទៀងទាត់ក្នុងចំនួន ១០០%។ ការចូលរួមធ្វើឱ្យល្អប្រសើរនូវទិន្នន័យកំណើត មរណភាព និងកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) មូលហេតុនៃការស្លាប់ (CoD) តាមរយៈប្រព័ន្ធព័ត៌មានសុខាភិបាលតាមគេហទំព័រ (HMIS) គឺជាគោលបំណងដ៏សំខាន់មួយក្នុងការកំណត់ពេលអនាគត ជាពិសេសសម្រាប់គោលបំណងនៃការត្រួតពិនិត្យ និងវាយតម្លៃហើយអាចកាត់បន្ថយបន្ទុកក្នុងការរាយការណ៍ និងប្រមូលព័ត៌មានតាមផ្នែក។

ពាក់ព័ន្ធទៅនឹងប្រព័ន្ធការចុះបញ្ជីអត្រានុកូលដ្ឋាន ទោះជាក្នុងករណីដែលមរណភាពកើតឡើងនៅមូលដ្ឋានសុខាភិបាល មេឃុំ ចៅសង្កាត់ មិនអាចបកប្រែមូលហេតុនៃការស្លាប់បានគ្រប់គ្រាន់ទេ ដោយសាររបាំងភាសា ពីព្រោះលិខិតបញ្ជាក់មរណភាពផ្នែកវេជ្ជសាស្ត្រ ដែលតែងតែបំពេញដោយប្រើប្រាស់ជាភាសាបារាំង ឬអង់គ្លេស។ វាត្រូវបានផ្តល់អនុសាសន៍ថា ការថតចម្លងលិខិតបញ្ជាក់មរណភាពផ្នែកវេជ្ជសាស្ត្រ គួរត្រូវបានផ្តល់ឱ្យការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាន តែការកត់ត្រាកូដមូលហេតុនៃការស្លាប់ដោយប្រើប្រាស់ចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) ត្រូវធ្វើឡើង

phuR

ដោយក្រសួងសុខាភិបាល។ ដោយសារមូលហេតុនៃការស្លាប់ (CoD) តែងតែបាត់បង់ដោយសាររបាំងភាសានោះ ការធ្វើមជ្ឈការទៅលើតួនាទីនេះ នឹងតម្រូវឱ្យមានលិខិតបញ្ជាក់មូលហេតុស្លាប់តាមបែបវេជ្ជសាស្ត្រ (MCCD) ទាំងអស់តម្រូវឱ្យបកប្រែ ទោះបីភាសាបារាំង អង់គ្លេស ឬខ្មែរ ពីព្រោះភាសាមិនមែនជាឧបសគ្គនៅថ្នាក់កណ្តាលនោះទេ។

**អនុសមាសភាគ គ៣- មរណភាពកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល**

ប្រសិនបើមនុស្សម្នាក់ស្លាប់នៅក្រៅមូលដ្ឋានសុខាភិបាល ទម្រង់ពីសាលាឃុំ គឺទាមទារដើម្បីចុះបញ្ជីមរណភាព។ តាមប្រព័ន្ធអត្រានុកូលដ្ឋាន ដែលបានដំណើរការមក មូលហេតុស្លាប់ត្រូវបានកត់ត្រាលើបញ្ជីមរណភាពដោយផ្អែកទៅលើសេចក្តីរាយការណ៍ពីសមាជិកគ្រួសារដែលទៅចុះបញ្ជីមរណភាព និងដែលជាញឹកញាប់ គឺត្រូវបានសន្មត់មូលហេតុស្លាប់ថា ជំងឺគ្រុន ឬគាំងបេះដូង ដែលផ្តល់តម្លៃយ៉ាងតិចតួចដល់សុខុមាលភាពសាធារណៈ។

ក្នុងប្រទេសកម្ពុជា ច្រើនជាង ៥០% នៃមរណភាពនៅតែកើតឡើងនៅក្រៅមូលដ្ឋានសុខាភិបាល ហើយមរណភាពទាំងនេះមិនត្រូវបានបញ្ជាក់ដោយវេជ្ជសាស្ត្រទេ។ យន្តការធ្វើការអង្កេតសាកសួរផ្ទាល់មាត់មិនត្រូវបានប្រើនាពេលបច្ចុប្បន្ននេះទេ ក៏ប៉ុន្តែក្នុងឆ្នាំ២០០៤ គណៈកម្មាធិការជាតិអង្កេតស្រាវជ្រាវមរណភាពមាតា (NCMDA) ត្រូវបានបង្កើតឡើងក្នុងប្រទេសកម្ពុជា ដែលមានសមាជិកមកពីមជ្ឈមណ្ឌលគាំពារមាតា និងទារក (NRMNCHC) និងនាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល (DPHI)។ មន្ទីរសុខាភិបាលរាជធានី ខេត្ត គឺទទួលខុសត្រូវលើការអនុវត្តជាផ្លូវការក្នុងការអង្កេតស្រាវជ្រាវមរណភាពមាតា និងពិនិត្យលើទំនាក់ទំនងករណីនីមួយៗ។ ក្នុងឆ្នាំ២០០៥ គណៈកម្មាធិការស្រាវជ្រាវមរណភាពមាតា (Maternal Audit Committees) បានចុះអនុវត្តការងារ នៅក្នុង ១៨ ខេត្ត (នៃ ២៤ រាជធានី ខេត្ត)។ បច្ចុប្បន្ន ប្រទេសកម្ពុជាកំពុងពិនិត្យពិចារណាតើត្រូវវិភាគ បកស្រាយ និងប្រើប្រាស់ព័ត៌មានទាំងនេះឱ្យបានល្អយ៉ាងដូចម្តេច។

ដើម្បីប្រមូលបាននូវមូលហេតុសមរម្យនៃការស្លាប់ទាំងនេះ វិធីសាស្ត្រធ្វើការអង្កេតសាកសួរផ្ទាល់មាត់ត្រូវតែបង្កើតឡើង។ មន្ត្រីសុខាភិបាលក្នុងសហគមន៍នឹងអាចត្រូវបានចល័តដើម្បីបំពេញការងារធ្វើការអង្កេតសាកសួរផ្ទាល់មាត់ ព្រោះតែពួកគាត់ស្ថិតនៅជិតសហគមន៍ និងដែលត្រូវចុះទៅសហគមន៍ពេលចាក់ថ្នាំបង្ការ និងអប់រំសុខភាព។ ការបណ្តុះបណ្តាលគ្រប់គ្រាន់ និងការលើកទឹកចិត្ត នឹងត្រូវបានផ្តល់ដល់អ្នកចុះធ្វើអង្កេតសាកសួរផ្ទាល់មាត់ (VA enumerators) ដើម្បីធ្វើការបញ្ជាក់ និងរាយការណ៍ពីមរណភាពទាំងអស់។

**អនុសមាសភាគ គ៤- ការអនុវត្តដែលមានភាពប៉ះពាល់ទៅនឹងគុណភាពទិន្នន័យ មូលហេតុនៃការស្លាប់**

ពុំមានមធ្យោបាយដើម្បីឱ្យដឹងពីចំនួនតួលេខ និងមូលហេតុនៃការស្លាប់ នៅក្រៅមូលដ្ឋានសុខាភិបាល។ ដូចនេះប្រព័ន្ធសុខាភិបាលត្រូវពឹងផ្អែកទៅលើប្រព័ន្ធអត្រានុកូលដ្ឋានក្នុងការកត់ត្រាពីព្រឹត្តិការណ៍ទាំងនោះ ដើម្បីឱ្យយល់កាន់តែស៊ីជម្រៅទៅលើស្ថិតិ ស្តីពីមរណភាព។

ទម្រង់សំបុត្រមរណភាពមិនមែនជាលិខិតបញ្ជាក់មូលហេតុនៃការស្លាប់ តាមផ្នែកវេជ្ជសាស្ត្រអន្តរជាតិទេ ហើយមិនស្របទៅនឹងការអនុវត្តចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) ក្នុងការសន្មត់ពីមូលហេតុនៃការស្លាប់នោះដែរ។

phak

**ទម្រង់អន្តរជាតិស្តីពីការបញ្ជាក់ដោយវេជ្ជសាស្ត្រនូវមូលហេតុនៃការស្លាប់**

| **មូលហេតុនៃការស្លាប់** | | **រយៈពេលប្រហែលរវាងកំណើត និងការស្លាប់** |
|---|---|---|
| **១.** | | |
| ជំងឺ ឬមូលហេតុជាក់ស្តែង | (ក)........................................ | ........................ |
| ដែលនាំឱ្យស្លាប់ * | ដោយសារ (ឬ ជាលទ្ធផលនៃ) | |
| **មូលហេតុដែលមានពីមុនមក** | (ខ)........................................ | ........................ |
| ស្ថានភាពជំងឺ ប្រសិនបើមាន | ដោយសារ (ឬ ជាលទ្ធផលនៃ) | |
| លើកឡើងនូវមូលហេតុខាងលើ | (គ)........................................ | ........................ |
| បង្ហាញពីមូលហេតុដែលបានបញ្ជាក់ | ដោយសារ (ឬ ជាលទ្ធផលនៃ)) | |
| ក្រោយគេ | (ឃ)........................................ | ........................ |
| | ដោយសារ (ឬ ជាលទ្ធផលនៃ) | |
| **២.** | | |
| មូលហេតុផ្សេងៗទៀតដែលនាំ | ........................................ | ........................ |
| ឱ្យស្លាប់ ប៉ុន្តែមិនទាក់ទងទៅនឹង | | |
| ជំងឺ ឬមូលហេតុដែលនាំឱ្យស្លាប់ | ........................................ | ........................ |
| ** មិនមែនជារបៀបនៃការស្លាប់ ឧ. ជំងឺគាំងបេះដូង ជំងឺពិបាកដកដង្ហើម ។ គឺសំដៅលើជំងឺ ការរងរបួស ឬមូលហេតុស្មុគស្មាញដទៃទៀត ដែលនាំឱ្យស្លាប់ ។* | | |

នាពេលបច្ចុប្បន្ន ទិន្នន័យមូលហេតុនៃការស្លាប់នៅក្នុងបញ្ជីអត្រានុកូលដ្ឋានមិនត្រូវបានចងក្រងពីមូលហេតុចម្បងនៃការស្លាប់ ឬប្រើសម្រាប់ការរៀបចំគោលនយោបាយសុខុមាលភាពសាធារណៈទេ។ ទន្ទឹមនឹងលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) នៅមានកម្រិត និងរបាយការណ៍មរណភាពនៃមូលហេតុមរណភាពមិនត្រូវបានបែងចែកទៅតាមមូលហេតុនៃការស្លាប់ទេ។

**បញ្ហាប្រឈម :**

- លិខិតបញ្ជាក់មរណភាពជាអន្តរជាតិមានការបញ្ជាក់ពីមូលហេតុនៃស្លាប់ដោយវេជ្ជសាស្ត្រ គឺតម្រូវឱ្យមានការប្រើប្រាស់ និងការបណ្តុះបណ្តាលវេជ្ជបណ្ឌិតទូទៅលើការចុះសំបុត្រមរណភាព។
- តម្រូវឱ្យមានការធ្វើឱ្យប្រសើរឡើងនូវគុណភាពនៃលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) និងបង្កើតឱ្យមានការតភ្ជាប់ជាមួយប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន (CRVS) មានតែ ១២% ទេសម្រាប់មរណភាពដែលទំនងជាមានលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD)។ ទាំងនេះ គឺជាមរណភាពដែលកត់ត្រាតាមរយៈប្រព័ន្ធសុខាភិបាល និងភាគច្រើនពីមន្ទីរពេទ្យសាធារណៈ។ មានតិចតួចប៉ុណ្ណោះពីសេវាឯកជនដែលរាយការណ៍ពីព្រឹត្តិការណ៍សំខាន់ៗទៅក្រសួងសុខាភិបាល។
- ចាប់ពីជាង ៥០% នៃមរណភាពក្នុងប្រទេសកម្ពុជានៅតែកើតឡើងក្រៅមន្ទីរពេទ្យ នោះវាជាតម្រូវការដើម្បីសាកល្បងប្រើប្រាស់បច្ចេកទេសការអង្កេតសាកសួរផ្ទាល់មាត់ ដើម្បីកត់ត្រានូវមូលហេតុសមស្របជាងគេសម្រាប់មរណភាពទាំងនេះ។
- ការប្រើប្រាស់ប្រាស់កូដ ICD ត្រូវបានណែនាំឱ្យមានលក្ខណៈមជ្ឈការ និងក្រុមអ្នកហ្វឹកហ្វឺនបង្ហាត់សម្រាប់

phaR

ជុំវិញមរណភាពដែលជាការអៀនខ្មាស់ និងជាចំណុចរសើបក្នុងសង្គម ដោយសារតែអត្តឃាត អេដស៍ និងមរណភាពមាតាហាក់ដូចជាសង្គមត្រូវទទួលយកពីមូលហេតុនៃការស្លាប់ឱ្យបានច្រើន។ សម្រាប់មូលហេតុនៃការស្លាប់ផ្សេងៗទៀត ឬក្នុងករណីដែលមរណភាពត្រូវបានសង្ស័យដោយសារអំពើហឹង្សា ការស៊ើបសង្កេតផ្នែកបទឧក្រិដ្ឋត្រូវបានធ្វើឡើងដោយគណៈកម្មការស៊ើបសង្កេតដែលមានសមាភាពពីប៉ូលីស អាជ្ញាធរមូលដ្ឋាន និងវេជ្ជបណ្ឌិត ហើយដោយផ្អែកតាមការធ្វើកោសល្យវិច្ច័យរបស់ប៉ូលីស នោះមូលហេតុនៃការស្លាប់ត្រូវបានសន្មត់។

ខាងក្រោមនេះ គឺជាលិខិតបញ្ជាក់មរណភាពរបស់មន្ទីរពេទ្យ ដែលមានបន្ទាត់ប្រើសម្រាប់រោគវិនិច្ឆ័យ ទម្រង់នៃមរណភាព និងមូលហេតុនៃការស្លាប់។ ទម្រង់នេះ មិនស្របទៅនឹងការអនុវត្តរបស់ចំណាត់ថ្នាក់នៃជំងឺអន្តរជាតិ (ICD) សម្រាប់សំបុត្រមរណភាពទេ។ គ្មានប្រអប់គូសសម្រាប់ការមានផ្ទៃពោះលើសំបុត្រមរណភាពទេ ក៏ប៉ុន្តែរបាយការណ៍ប្រចាំខែរបស់ប្រព័ន្ធព័ត៌មានសុខាភិបាល (HMIS) ចេញពីមូលដ្ឋានសុខាភិបាល គឺមានរបាយការណ៍ស្តីពីមរណភាពមាតា។

**លិខិតបញ្ជាក់មរណភាព**



ក្នុងបរិបទនៃការបណ្តុះបណ្តាលលើលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) ដែលជាផ្នែកមួយក្នុងកាលវិភាគសាលាពេទ្យ មានបង្រៀនមេរៀន ស្តីពីការអនុវត្តលិខិតបញ្ជាក់មូលហេតុនៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD)។ វាត្រូវបានផ្តល់អនុសាសន៍ថា ដើម្បីទទួលបានគ្រប់គ្រាន់លើមូលដ្ឋានមូលហេតុនៃការស្លាប់ នោះលិខិតបញ្ជាក់ពីមូលហេតុមរណភាពជាអន្តរជាតិ ត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀន។ លើសពីនេះ ការតម្រង់ទិសដៅទូទាំងប្រទេស និងការចែករំលែកបទពិសោធន៍របស់វេជ្ជបណ្ឌិតលើការអនុវត្តលិខិតមរណភាពតម្រូវឱ្យធ្វើឡើង។

phak

អ្នកដាក់កូដ គឺទាមទារឱ្យមានការបណ្តុះបណ្តាលគ្រូបង្គោល ។

- កិច្ចសហប្រតិបត្តិការរវាងក្រសួងសុខាភិបាល និងក្រសួងមហាផ្ទៃត្រូវតែបង្កើតឡើង និងមានយន្តការថ្នាក់បច្ចេកទេសជាអ្នកសម្របសម្រួល និងទំនាក់ទំនង ។

**អនុសាសន៍**

១. ការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងភាពពេញលេញនៃទិន្នន័យមូលហេតុនៃការស្លាប់ :

ក. សម្រាប់មរណភាពក្រៅមន្ទីរពេទ្យ: ការកត់ត្រាមូលហេតុដ៏សមរម្យនៃការស្លាប់ ដោយប្រើប្រាស់ការធ្វើអង្កេតសាកសួរផ្ទាល់មាត់នៅផ្ទះអ្នកស្លាប់ ។

ខ. សម្រាប់មរណភាពនៅក្នុងមូលដ្ឋានសុខាភិបាល: ការបញ្ជាក់ពីមូលហេតុនៃការស្លាប់ ធ្វើតាមលិខិតបញ្ជាក់ជាអន្តរជាតិពីមរណភាព។ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) គឺជាអាទិភាពចម្បងរបស់ប្រទេសកម្ពុជា ។

គ. សម្រាប់មរណភាពដោយសារមូលហេតុផ្សេងៗ : ការចូលរួមពីអាជ្ញាធរមូលដ្ឋាន ដើម្បីរកមរណភាពលើមូលហេតុនៃការស្លាប់ ។

**២. ការទទួលយកលិខិតបញ្ជាក់ជាអន្តរជាតិស្តីពីមូលហេតុនៃការស្លាប់:** ការណែនាំពីទម្រង់អន្តរជាតិនៃលិខិតបញ្ជាក់ផ្នែកវេជ្ជសាស្ត្រអំពីមូលហេតុនៃការស្លាប់ គឺត្រូវធ្វើការពិចារណា។ បញ្ហានេះត្រូវរៀបចំឡើងដើម្បីសម្របសម្រួលដល់ការធ្វើរោគវិនិច្ឆ័យដ៏ត្រឹមត្រូវ និងដឹងពីមូលហេតុនៃការស្លាប់ ព្រមទាំងជំរុញឱ្យមានទម្រង់ឯកភាពមួយក្នុងការអនុវត្តចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) សម្រាប់មរណភាពដែលត្រូវបានកំណត់ទាំងអស់ ។

**៣. ការធ្វើមជ្ឈការលើការកត់ត្រាលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) និងការដាក់លេខកូដមូលហេតុនៃការស្លាប់ ដោយប្រើប្រាស់ចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) នៅក្រសួងសុខាភិបាល** : ការផ្តល់អនុសាសន៍ពីការចម្លងលិខិតបញ្ជាក់មរណភាពដោយវេជ្ជសាស្ត្រ ត្រូវផ្តល់ជូនទៅការិយាល័យចុះបញ្ជីអត្រានុកូលដ្ឋាន ទោះបីជាការកត់ត្រា ការដាក់លេខកូដមូលហេតុនៃការស្លាប់ ត្រូវបានធ្វើឡើងនៅក្រសួងសុខាភិបាលក៏ដោយ ។ ដោយសារតែមូលហេតុនៃការស្លាប់ (CoD) ជាញឹកញាប់ត្រូវបានបាត់បង់ព្រោះតែបញ្ហាភាសា ដើម្បីធ្វើមជ្ឈការតួនាទីនេះ ដោយអនុញ្ញាតឱ្យមានការបកប្រែលិខិតបញ្ជាក់នៃមូលហេតុនៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD) (ជាភាសាអង់គ្លេស បារាំង ឬខ្មែរ) នៅកម្រិតថ្នាក់ជាតិ ។

**៤. ការបណ្តុះបណ្តាល និងការចែករំលែកបទពិសោធន៍ទូទាំងប្រទេសសម្រាប់វេជ្ជបណ្ឌិតអំពីលិខិតបញ្ជាក់នៃការស្លាប់តាមផ្នែកវេជ្ជសាស្ត្រ (MCCD)** : សិក្ខាសាលាថ្នាក់ជាតិ និងការចែករំលែកបទពិសោធន៍ស្តីពីលិខិតបញ្ជាក់មរណភាព និងការដាក់លេខកូដជំងឺអន្តរជាតិ (ICD) ដល់វេជ្ជបណ្ឌិតដែលកំពុងបម្រើការងារត្រូវតែរៀបចំឡើង ។ ការបណ្តុះបណ្តាលបណ្តើរនឹងធ្វើការងារបណ្តើរ គួរត្រូវបានគ្រោង និងអនុវត្តសម្រាប់វេជ្ជបណ្ឌិតដូចគ្នា ។

phaR

៥. **ការអង្កេតសាកសួរផ្ទាល់មាត់ :** មន្ត្រីអត្រានុកូលដ្ឋាន និងអ្នកស្ម័គ្រចិត្តសុខាភិបាលសហគមន៍ទាមទារឱ្យមានការវិនិច្ឆ័យត្រឹមត្រូវលើចំណុចសំខាន់ៗនៃមូលហេតុនៃការស្លាប់ ហើយពួកគេគួរត្រូវបានបណ្តុះបណ្តាលក្នុងការអនុវត្តការធ្វើអង្កេតសាកសួរផ្ទាល់មាត់ និងមានកុំព្យូទ័រសម្រាប់ដាក់លេខកូដ ដែលទាំងនេះគឺទាមទារឱ្យមានការសាកល្បង។ លើសពីនេះ ជាអនុសាសន៍ត្រូវជំរុញសហប្រតិបត្តិការរវាងអ្នកស្ម័គ្រចិត្តសុខាភិបាលសហគមន៍ ក៏គួរត្រូវសាកល្បងផងដែរស្របពេលដែលអ្នកផ្តល់ព័ត៌មាននៃមរណភាពទៅមណ្ឌលសុខភាពសហគមន៍អាចទទួលខុសត្រូវក្នុងការអនុវត្ត ការអង្កេតសាកសួរផ្ទាល់មាត់ និងមានគម្រោងសាកល្បងមួយបង្កើតឡើងក្នុងឃុំចំនួន១០។

៦. **សៀវភៅណែនាំ :** សៀវភៅណែនាំសម្រាប់វេជ្ជបណ្ឌិតត្រូវបានរៀបចំ។ វាមានសារៈសំខាន់សម្រាប់ធ្វើឱ្យប្រសើរឡើងនូវលិខិតបញ្ជាក់ពីមូលហេតុនៃការស្លាប់ និងការទុកដាក់ជាឯកសារ។ មធ្យោបាយនេះត្រូវបានរៀបចំឡើងដោយគណៈកម្មការដែលមានសមាជិកមកពីក្រសួងសុខាភិបាល មន្ទីរពេទ្យ (មូលដ្ឋានសុខាភិបាលដទៃទៀត និងពីមហាវិទ្យាល័យពេទ្យ)។

**សមាសភាគ ឃ : ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ ICD**

ការអនុវត្តចំណាត់ថ្នាក់ជាអន្តរជាតិ (ICD 10) ត្រូវបានកំណត់ជាសកម្មភាពចម្បងក្នុងផែនការយុទ្ធសាស្ត្រព័ត៌មានសុខាភិបាលនៅប្រទេសកម្ពុជាឆ្នាំ២០០៨-២០១៥។ ក៏ប៉ុន្តែនាពេលបច្ចុប្បន្ន ប្រទេសកម្ពុជាមិនទាន់បានអនុវត្តការដាក់លេខកូដចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD 10) សម្រាប់រោគវិនិច្ឆ័យនៅឡើយទេ។

ជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល (HMIS) ក្រសួងសុខាភិបាលកំពុងព្យាយាមរៀបចំផែនទីជំងឺឆ្លងដែលមានបច្ចុប្បន្នដែលបានរាយការណ៍ពីមូលហេតុនៃការស្លាប់ក្នុងចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD10)។ ទោះបីការដាក់លេខកូដជាលក្ខណៈស្តង់ដារតាមបច្ចេកទេសក៏ដោយ ប៉ុន្តែមិនទាន់មានប្រព័ន្ធប្រើប្រាស់ឡើយ។

**អនុសាសន៍**

១. **ការអនុវត្តដាក់លេខកូដ ICD-10 សម្រាប់មរណភាព :** ការអនុវត្ត ICD 10 ត្រូវបានកំណត់ជាសកម្មភាពចម្បងក្នុងផែនការយុទ្ធសាស្ត្រព័ត៌មានសុខាភិបាលកម្ពុជាឆ្នាំ២០០៨-២០១៥។ វាត្រូវបានផ្តល់អនុសាសន៍ថាការបណ្តុះបណ្តាលគ្រូបង្គោលត្រូវតែកំណត់ ថាតើនរណាគួរស្វែងយល់ជាមួយចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD 10) ដោយប្រើប្រាស់ឧបករណ៍បណ្តុះបណ្តាលរបស់ WHO-ICD online មុនពេលទទួលបានការបណ្តុះបណ្តាលស៊ីជម្រៅនៅមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ។

២. **តារាងមរណភាពស្តង់ដាដើម្បីរៀបចំមូលហេតុនៃការស្លាប់ :** ដោយសារការប្រើប្រាស់តារាងមូលហេតុនៃការស្លាប់ គ្មានស្តង់ដាពីមន្ទីរពេទ្យនោះ ក្រសួងសុខាភិបាលគួរទទួលយកតារាងមរណភាពស្តង់ដាសម្រាប់រៀបចំមូលហេតុនៃការស្លាប់ (COD)។

៣. **ការធ្វើមជ្ឈការលើការដាក់លេខកូដ :** ការធ្វើមជ្ឈការលើការដាក់លេខកូដមូលហេតុនៃការស្លាប់ គឺត្រូវបានផ្តល់ជាអនុសាសន៍។ វានឹងជួយសម្របសម្រួលដល់កិច្ចការអនុវត្តឱ្យបានជាប់លាប់ និងស្តង់ដា។ លើសពីនេះ ការវាយតម្លៃលើគុណភាព និងរក្សាទុកការងារអ្នកដាក់លេខកូដដែលទទួលបានការបណ្តុះបណ្តាលល្អនឹង


phan

ងាយស្រួលពង្រឹងការងារ ។

៤. **ស្តង់ដាកាលវិភាគ :** កាលវិភាគបណ្តុះបណ្តាលសម្រាប់អ្នកដាក់លេខកូដទាំងអស់គួរតែមានស្តង់ដាជាតិ ។ មជ្ឈមណ្ឌលបណ្តុះបណ្តាលកិច្ចសហប្រតិបត្តិការរបស់អង្គការសុខភាពពិភពលោក (WHO) នៃចំណាត់ថ្នាក់អន្តរជាតិ ផ្តល់វគ្គបណ្តុះបណ្តាលជាទៀងទាត់ក្នុងការដាក់លេខកូដចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) ។ វគ្គបណ្តុះបណ្តាលទាំងនេះ មានតម្លៃជាពិសេសសម្រាប់អ្នកបណ្តុះបណ្តាល ដែលផ្តល់ការបណ្តុះបណ្តាលចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) ថ្នាក់ជាតិ ឬនៅពេលដែលកំណែថ្មីរបស់ចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) ត្រូវបានប្រើប្រាស់ ។

៥. **ឧបករណ៍ដាក់លេខកូដមរណភាព :** ឧបករណ៍ដាក់លេខកូដមរណភាព គួរត្រូវបានណែនាំឱ្យប្រើប្រាស់ ដែលនេះអាចជួយដល់អ្នកដាក់លេខកូដឱ្យកំណត់ពីទំនាក់ទំនងសមស្រប និងធានាដល់កិច្ចអនុវត្តជាប់លាប់នៃការប្រមូលផ្តុំចំណាត់ថ្នាក់ជំងឺអន្តរជាតិ (ICD) និងនីតិវិធីនៃការកែសម្រួល ដែលផ្តល់លទ្ធផលដល់ការប្រៀបធៀបទិន្នន័យមូលហេតុនៃការស្លាប់ ។ ឧទាហរណ៍នូវឧបករណ៍ទាំងនោះមាន ACME decision tables, MMDS decision tables, IRIS, etc.

៦. **ការតាមដានជាទៀងទាត់ :** នៅពេលយន្តការដាក់លេខកូដត្រូវបានបង្កើតឡើង ការធ្វើតាមដានត្រួតពិនិត្យជាទៀងទាត់លើការដាក់លេខកូដទាមទារឱ្យធ្វើឡើង ដើម្បីកំណត់ និងកែតម្រូវកំហុសឆ្គង ឬការយល់ខុស ។

## សមាសភាព ខ: ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ

### អនុសមាសភាគ ខ១- គុណភាពទិន្នន័យ និងភាពត្រឹមត្រូវនៃការត្រួតពិនិត្យ

នាពេលបច្ចុប្បន្នគ្មានស្ថិតិអត្រានុកូលដ្ឋានត្រូវបានចងក្រងពីទិន្នន័យអត្រានុកូលដ្ឋានទេ ។ ទោះបីជាមានពេលវេលាកំណត់សម្រាប់ធ្វើសេចក្តីរាយការណ៍ពីថ្នាក់ឃុំ សង្កាត់ ស្រុក ខណ្ឌ និងរាជធានី ខេត្តក៏ដោយ តែការអនុវត្តនៅតែមានភាពធូរលុងនៅឡើយ ហើយក្រសួងមហាផ្ទៃមិនបានទទួលរបាយការណ៍ទៀងទាត់ស្តីពីអត្រានុកូលដ្ឋានពីគ្រប់រាជធានី ខេត្ត។ នៅពេលដំណាច់ឆ្នាំ ក្រសួងមហាផ្ទៃចងក្រងរបាយការណ៍ស្តីពីចំនួនសរុបចុះបញ្ជីកំណើត និងមរណភាព ធ្វើការបែងចែកតាមភេទ ក៏ប៉ុន្តែគ្មានការបែងចែកតាមអាយុឡើយ ។ នៅថ្នាក់ជាតិ ក្រសួងមហាផ្ទៃបានចែករំលែកទិន្នន័យបូកសរុបប្រចាំឆ្នាំ CRVS ជាមួយក្រសួងផែនការ ចាប់តាំងពីទិន្នន័យទាំងនេះត្រូវបានវិភាគ ក៏ប៉ុន្តែការចែករំលែកទិន្នន័យជាលំអិតនាពេលខាងមុខ កំពុងពិភាក្សានៅឡើយ ។

រហូតដល់បច្ចុប្បន្ននេះ ចាប់តាំងពីស្ថិតិអត្រានុកូលដ្ឋានមិនត្រូវបានយកមកគណនា ដោយផ្អែកលើទិន្នន័យអត្រានុកូលដ្ឋានក្នុងប្រទេសកម្ពុជា ការត្រួតពិនិត្យលើគុណភាពសម្រាប់សូចនាករមរណភាព និងលទ្ធភាពបង្កើតកូនដែលត្រូវគណនាចេញពីទិន្នន័យអត្រានុកូលដ្ឋានមិនទាន់ត្រូវបានអនុវត្តនៅឡើយ ។ ដូចគ្នាផងដែរ ចំពោះទិន្នន័យមូលហេតុនៃការស្លាប់ត្រូវបានប្រមូលតាមមធ្យោបាយនៅមានកម្រិត និងភាគរយដែលត្រូវកំណត់ចំពោះប្រភេទជំងឺក៏ពុំទាន់បានបង្កើតឡើង រួមទាំងការត្រួតពិនិត្យភាពត្រឹមត្រូវផងដែរ ។ លើសពីនេះ វាបានផ្តល់នូវបរិបទប្រវត្តិស្មុគស្មាញដល់ប្រទេសកម្ពុជា វាច្បាស់ថាប្រព័ន្ធអត្រានុកូលដ្ឋានបំពេញបំណងមិនត្រឹមតែកំណើត និងមរណភាពក្នុងឆ្នាំនោះទេ ថែមទាំងគ្រប់ដណ្តប់ទៅលើកិច្ចការដែលមិនទាន់ធ្វើរួច ។ ទោះបីជានៅឆ្នាំខាងមុខ ជាពិសេសជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន និងការចូលរួមពីវិទ្យាស្ថានស្ថិតិជាតិក្រសួងផែនការនោះ វាត្រូវបានផ្តល់ជាអនុសាសន៍ថា

phat

គុណភាពទិន្នន័យ និងភាពត្រឹមត្រូវក្នុងការត្រួតពិនិត្យត្រូវតែធ្វើឡើងជាប្រចាំ។ បច្ចុប្បន្ន មានការចុះបញ្ជីកំណើតស្ទួន ជាពិសេសក្នុងអំឡុងពេលចុះបញ្ជីចល័ត ដែលបានបន្សល់ទុកនូវបញ្ហាប្រឈមចម្បងជាច្រើន។

ការធ្វើជំរឿនប្រជាជនត្រូវធ្វើឡើងរាល់១០ឆ្នាំម្តង និងការជំរឿនចុងក្រោយនៅឆ្នាំ២០០៨។ ជំរឿននេះក៏រួមមានសំនួរពាក់ពន្ធ័ការចុះបញ្ជីកំណើតចុងក្រោយ ប្រសិនបើមរណភាពកើតឡើងក្នុងផ្ទះក្នុងអំឡុងពេល១២-២៤ខែចុងក្រោយ ប្រសិនបើមរណភាពចុងក្រោយត្រូវបានចុះបញ្ជី និងរួមទាំងមូលហេតុនៃការស្លាប់។ ជាបន្ត ការប៉ាន់ប្រមាណលើភាពមានកូន និងមរណភាព ព្រមទាំងចំនួនកំណើត និងមរណភាព ក្នុងចំណោមចំនួនប្រជាជនទាំងអស់អាចត្រូវបានកែសម្រួល ដោយប្រើប្រាស់ទិន្នន័យជំរឿន។

**អនុសមាសភាគ ១២-ការរៀបចំតារាងទិន្នន័យ**

នៅកម្ពុជា ទិន្នន័យមូលហេតុនៃការស្លាប់ដែលប្រមូលតាមរយៈប្រព័ន្ធអត្រានុកូលដ្ឋាន គឺនៅមានបញ្ហានៅឡើយ ហើយទិន្នន័យទាំងនោះនៅមិនបានរៀបចំជាតារាងដោយទាញចេញពី (ទិន្នន័យនៃប្រព័ន្ធអត្រានុកូលដ្ឋាន)។ ទំហំនៃការរៀបចំជាតារាងទិន្នន័យនាពេលបច្ចុប្បន្ន គឺជាការកំណត់នៅក្នុងរបាយការណ៍ប្រចាំខែនៃចំនួនតួលេខសរុបកំណើត និងមរណភាពដែលបានចុះបញ្ជី ដោយធ្វើការបែងចែកទៅតាមភេទ ដែលបានបញ្ជូនពីសាលាឃុំ សង្កាត់ ទៅស្រុក ខណ្ឌ ទៅរាជធានី ខេត្ត និងទៅនាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ។ របាយការណ៍ត្រូវធ្វើនៅគ្រប់ថ្នាក់រដ្ឋបាលទាំងអស់។ ជាអនុសាសន៍ គឺថាទិន្នន័យបានពីប្រព័ន្ធចុះបញ្ជី គឺត្រូវបានបញ្ជូនពីឃុំ សង្កាត់ ទៅថ្នាក់កណ្តាល ដូចនេះការត្រួតពិនិត្យពីគុណភាពមួយចំនួនត្រូវចាប់ផ្តើមធ្វើឡើង ដោយចាប់ផ្តើមចេញពីកម្រិតដែលទិន្នន័យត្រូវបានចងក្រងពីបញ្ជីនីមួយៗ។ ការចាប់ផ្តើមការត្រួតពិនិត្យគួរត្រូវធ្វើឡើងសម្រាប់ព័ត៌មានទិន្នន័យដែលបាត់បង់ (ដូចជា ភេទ ថ្ងៃខែឆ្នាំកំណើត ថ្ងៃខែឆ្នាំមរណភាព) ឬកំហុសនៃការចម្លងអាចកើតឡើងនៅពេលទិន្នន័យត្រូវបានចងក្រង។ នៅកម្ពុជា ទិន្នន័យកំណើត និងមរណភាពត្រូវបានរក្សាទុកផ្អែកតាមថ្ងៃចុះបញ្ជី និងឈ្មោះសាលាឃុំ សង្កាត់។ នៅពេលខាងមុខ ការរៀបចំជាតារាងទិន្នន័យអំពីកំណើត និងមរណភាព គួរត្រូវអនុវត្តដូចខាងក្រោមនេះដែលជាអនុសាសន៍គោល៖

**ប្រអប់ទី៣: ការរៀបចំតារាងទិន្នន័យជាមូលដ្ឋានសម្រាប់កំណើតរស់**

សម្រាប់គោលបំណងសុខភាពសាធារណ: ជាបឋមការរៀបចំតារាងទិន្នន័យកំណើតគួរបញ្ចូលចំនួនកំណើតរស់សម្រាប់ឆ្នាំជាក់លាក់៖

- ភេទរបស់ក្មេង អាយុគតិ និងទំងន់ទារក
- រៀបជាលំដាប់កំណើតរស់ទៅតាមចន្លោះឃ្លាតរវាងកូនកើតរស់ចុងក្រោយ និងកូនកើតរស់បន្ទាប់។
- ទីកន្លែងកើត ទីលំនៅបច្ចុប្បន្នរបស់ម្តាយ និងខែកំណើត
- ទីកន្លែងចុះបញ្ជី និងខែចុះបញ្ជី
- អាយុ កម្រិតវប្បធម៌ដែលមាន និង
- អាយុឪពុក តាមទីលំនៅបច្ចុប្បន្ន
- ទីកន្លែងសម្រាល អ្នកចូលរួមនៅពេលកើត និងខែដែលការគាំពារទារកមុនកើត

UNSD, 2001; WHO, 2007

phak

| ប្រអប់ទី៤: ប្រអប់ទី៤ការរៀបចំតារាងទិន្នន័យជាមូលដ្ឋានសម្រាប់កំណើតរស់ |
|---|
| សម្រាប់គោលបំណងសុខភាពសាធារណៈ: ជាបឋមការរៀបចំតារាងទិន្នន័យមរណភាពគួរបញ្ចូលចំនួនមរណភាពសម្រាប់ឆ្នាំជាក់លាក់មួយតាម :<br>• ភេទ (ឧ. ការញែករវាងប្រុស និងស្រី)<br>• អាយុពេលស្លាប់ ដោយប្រើប្រាស់ក្រុមអាយុ ខាងក្រោម :<br>  • ស្ថិតក្នុងរយៈពេល ២៤ម៉ោងក្រោយសម្រាល (កត់ត្រាទុកក្នុងកំណត់ហេតុជានាទី ឬពេញម៉ោង)<br>  • រវាង ១ ទៅ ៧ថ្ងៃក្រោយសម្រាល<br>  • រវាង ៧ ទៅ ២៨ថ្ងៃក្រោយសម្រាល<br>  • រវាង១ ទៅ ១១ខែ<br>  • រវាង ១ ទៅ ៤ឆ្នាំ<br>  • ៥ឆ្នាំ ទៅ ៩ឆ្នាំ<br>  • ១០ ទៅ ១៤ឆ្នាំ (បន្តដោយក្រុមអាយុ ៥ឆ្នាំ រហូតដល់ ៨០ ទៅ ៨៤ឆ្នាំ)<br>  • ត្រឹម ៨៥ និងលើសពី ៨៥ឆ្នាំទៅ<br>• មូលហេតុរៀបតាមលំដាប់ ICD<br>• តំបន់ភូមិសាស្ត្រ |
| UNSD, 2001 |

**អនុសមាសភាគ ១៣- ការប្រើប្រាស់ និងការផ្សព្វផ្សាយទិន្នន័យ**

នាពេលបច្ចុប្បន្ន សេចក្តីរាយការណ៍ពីបណ្តារាជធានី ខេត្តចំពោះទិន្នន័យ CRVS មិនទៀងទាត់ នោះបង្ហាញថាគ្មានស្ថិតិអត្រានុកូលដ្ឋានត្រូវបានគណនាពីទិន្នន័យអត្រានុកូលដ្ឋាននៅកម្ពុជា និងថែមទាំងមិនបានប្រើប្រាស់សម្រាប់ការរៀបចំផែនការគោលនយោបាយ និងការបែងចែកធនធាននោះទេ។ មានការគាំទ្រ និងទទួលស្គាល់ពីតម្លៃសម្រាប់មូលហេតុនៃការស្លាប់ និងទិន្នន័យស្ថិតិអត្រានុកូលដ្ឋានសម្រាប់គោលបំណងសុខុមាលភាពសាធារណៈ។ ទោះបីជា ក្រសួងសុខាភិបាល គឺតួអង្គមួយដែលទទួលបានផលប្រយោជន៍ច្រើនជាងគេពីទិន្នន័យស្ថិតិអត្រានុកូលដ្ឋាន ហើយក៏មានស្ថាប័នផ្សេងៗទៀតរួមមាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រសួងសង្គមកិច្ច និងក្រសួងសាធារណៈការនិងដឹកជញ្ជូន និងភ្នាក់ងារដទៃទៀតដែលជាប់ពាក់ព័ន្ធក្នុងការបែងចែកធនធានជាយុទ្ធសាស្ត្រ អាចទទួលបានផលប្រយោជន៍ស្មើគ្នាពីការផ្សព្វផ្សាយនូវទិន្នន័យដែលទាន់ពេល និងត្រឹមត្រូវនេះ។ លើសពីនេះ តាមរយៈការចងក្រងនិងបោះពុម្ពទិន្នន័យស្ថិតិអត្រានុកូលដ្ឋានប្រចាំឆ្នាំ ការវិនិយោគដ៏ធំត្រូវបានបង្កើតរួចហើយនៅក្នុងប្រព័ន្ធអត្រានុកូលដ្ឋាននៃប្រទេសកម្ពុជា ដែលនេះជាសុទិដ្ឋិនិយមទៅថ្ងៃអនាគត។

phar

**អនុសាសន៍ :**

១. **នីតិវិធីបង្ហាញទិន្នន័យ :** ការរៀបចំអភិវឌ្ឍន៍ និងអនុវត្តនីតិវិធីនៃការបង្ហាញទិន្នន័យជាមួយនឹងស្តង់ដានៃការត្រួតពិនិត្យភាពត្រឹមត្រូវ និងភាពជាប់លាប់។ ការគណនាទៀងទាត់នៃអត្រាទាំងអស់ដែលតម្រូវសម្រាប់ការត្រួតពិនិត្យភាពត្រឹមត្រូវ និងភាពជាប់លាប់ គួរត្រូវបានធ្វើឡើង។ នេះទាមទារឱ្យមានកិច្ចសហប្រតិបត្តិការដ៏រឹងមាំជាមួយក្រសួងផែនការ ក្នុងការផ្សព្វផ្សាយទិន្នន័យឱ្យបានទាន់ពេលវេលា និងការបោះពុម្ពទិន្នន័យស្ថិតិអត្រានុកូលដ្ឋាន។

២. **ការរៀបចំតារាងស្ថិតិកំណើត និងមរណភាព :** អនុវត្តស្តង់ដាអន្តរជាតិសម្រាប់ការរៀបចំ និងប្រមូលផ្តុំទិន្នន័យ។ អង្គការសហប្រជាជាតិផ្តល់អនុសាសន៍នូវតារាងតូចមួយស្តីពីចរិកលក្ខណៈក្នុងការរៀបចំស្ថិតិកំណើត និងមរណភាព។ ស្ថិតិដែលបង្ហាញក្នុងប្រអប់ ៣ និង ៤ ខាងលើ គឺតម្រូវឱ្យមានការអនុវត្ត។ លើសពីនេះការខំប្រឹងប្រែងទាំងឡាយទាមទារឱ្យមានការធ្វើឡើង ដើម្បីឱ្យប្រសើរឡើងនូវទិន្នន័យមូលហេតុនៃការស្លាប់។ បន្ទាប់មក តារាង ICD 10 គួរត្រូវប្រើសម្រាប់ទិន្នន័យមរណភាព (មូលហេតុនៃការស្លាប់)។ សេចក្តីណែនាំរបស់ WHO (តារាងមូលហេតុស្តង់ដាចំនួន៦៥ ហើយក្រៅពីនេះគឺគ្មានមូលហេតុ) គួរត្រូវបានអនុវត្តសម្រាប់ចងក្រងមូលហេតុចម្បងនៃមរណភាព ដោយផ្អែកលើទិន្នន័យចុះបញ្ជីអត្រានុកូលដ្ឋាន។ ស្ថិតិគួរត្រូវបានរៀបចំ ដោយផ្អែកលើទីកន្លែងកើតជាក់លាក់ដែលព្រឹត្តិការណ៍កើតឡើង (មន្ទីរពេទ្យ មណ្ឌលសុខភាព ផ្ទះ ...។ល។) និងចំនួនក្រុមអាយុគួរត្រូវបានពង្រីក។

៣. **គណៈកម្មការចំរុះ :** គណៈកម្មការមួយដែលមានសមាជិកចូលរួមពាក់ព័ន្ធ និងការងារស្ថិតិអត្រានុកូលដ្ឋាន ដើម្បីពិភាក្សាឱ្យបានទៀងទាត់លើតម្រូវការទិន្នន័យជាមួយនឹងអ្នកប្រើប្រាស់ចម្បង គួរត្រូវបានបង្កើតឡើង។

៤. **ការបង្កើតពិធីសារ :** ពិធីសារទូទៅសម្រាប់ការបញ្ចូល ការផ្សព្វផ្សាយទិន្នន័យ រួមមានសារៈសំខាន់ក្នុងការផ្តល់និយមន័យ និងទស្សនៈទានដែលរៀបរាប់ពីភាពចាំបាច់ត្រូវបង្កើតឡើង។

៥. **វគ្គបណ្តុះបណ្តាល :** វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងបណ្តុះបណ្តាលឡើងវិញ ដើម្បីបង្កើនសមត្ថភាពនៃការវិភាគទិន្នន័យ និងការលើកទឹកចិត្តដល់បុគ្គលិកប្រមូលទិន្នន័យ។ ដូច្នេះពួកគេនឹងពេញចិត្តនឹងការងារដែលបានធ្វើទាំងនេះត្រូវកំណត់ជាសកម្មភាពអាទិភាព។ លើសពីនេះ បុគ្គលិកសុខាភិបាលត្រូវមានការលើកទឹកចិត្តដើម្បីរក្សានូវការកត់ត្រាបញ្ជីផ្នែកវេជ្ជសាស្ត្រពេញលេញ ដែលអាចជំនះបានរាល់ឧបសគ្គដែលកំពុងកើតមាន។

៦. **ការចងក្រង និងបោះពុម្ពទិន្នន័យ:** ជាទៀងទាត់ ការបោះពុម្ពទិន្នន័យស្ថិតិអត្រានុកូលដ្ឋានដែលបានចងក្រងគឺផ្តល់ឱ្យដល់អ្នកប្រើប្រាស់ដោយមិនគិតថ្លៃ តាមរយៈគេហទំព័រ CRVS ដែលដំណើរការ និងគ្រប់គ្រងដោយក្រសួងមហាផ្ទៃ ដែលនេះគឺជាការជំរុញឱ្យមានវប្បធម៌ក្នុងការប្រើប្រាស់ទិន្នន័យ និងលើកទឹកចិត្តដល់ការធ្វើគោលនយោបាយផ្អែកលើភស្តុតាង។

phar

## សេចក្តីសន្និដ្ឋាន ៖

ការត្រួតពិនិត្យឡើងវិញនៅលើប្រព័ន្ធ CRVS នៅប្រទេសកម្ពុជាបានបង្ហាញឱ្យឃើញនូវចំណុចខ្លាំង និងខ្សោយនៃប្រព័ន្ធ។ ចំណុចចាប់ផ្តើមនៃប្រព័ន្ធនេះ និងក្នុងបរិបទប្រវត្តិសាស្ត្រស្មុគស្មាញដែលកើតមានឡើង។ សមិទ្ធផលចម្បងៗសម្រេចបានក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ចាប់តាំងពីប្រព័ន្ធនេះត្រូវបានបង្កើតឡើង។ ជាពិសេសពាក់ព័ន្ធនឹងការចុះបញ្ជីកំណើត យុទ្ធនាការចុះបញ្ជីអត្រានុកូលដ្ឋានចល័តពិតជាបានរួមចំណែកក្នុងការកើនឡើងនៃការចុះបញ្ជីកំណើត ដែលប្រមាណ ៥% មុនពេលយុទ្ធនាការកើនទៅ ៩០% ក្រោយយុទ្ធនាការ។ លើសពីនេះ ដោយមានការគាំទ្រពី ADB និង SIDA ក្រសួងមហាផ្ទៃបានវាយបញ្ចូលបញ្ជីកំណើតប្រមាណ ៦លាន ទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យាអត្រានុកូលដ្ឋាន។ ស្របគ្នានេះ ការសាកល្បងប្រើប្រាស់តាមប្រព័ន្ធព័ត៌មានវិទ្យា Web-based CRVS ក៏ត្រូវបានសាកល្បងក្នុងឃុំ សង្កាត់ចំនួន ១១ នៅក្នុងខេត្តកំពង់ចាម។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងទូទាំងប្រទេសកំពុងអនុវត្ត តាមរយៈផ្ទាំងរូបភាព និងស្ពតវិទ្យុ សម្រាប់ព្រឹត្តិការណ៍អត្រានុកូលដ្ឋានទាំងអស់។

ទោះបីជាមានសញ្ញាបង្ហាញពីការសន្យាពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ក៏ដោយ ជាការចាំបាច់ត្រូវបន្តការខិតខំប្រឹងប្រែងបំពេញការងារក្នុងកិច្ចសហប្រតិបត្តិការដើម្បីទទួលបានភាពពេញលេញនៃការចុះបញ្ជីកំណើត និងមរណភាព។ ការចុះបញ្ជីមរណភាព និងលិខិតបញ្ជាក់ពីមូលហេតុនៃការស្លាប់ ត្រូវបានកំណត់ថាជាផ្នែកសំខាន់ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ជាបន្ទាន់។ យុទ្ធសាស្ត្រធម្មតាមួយចំនួនដូចជាការលើកទឹកចិត្តឱ្យចុះបញ្ជីមរណភាព ដោយផ្តល់ជូនប្រាក់បញ្ចុះសព យុទ្ធនាការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ឬការប្រើប្រាស់បុគ្គលិកពេទ្យជាអ្នកជូនដំណឹងពីមរណភាព អាចជំរុញកំណើនចំនួននៃការចុះបញ្ជីមរណភាព។

លើសពីនេះ ការបង្កើតឱ្យមានគណៈកម្មការអន្តរក្រសួងដោយមានសមាជិកពីក្រសួងមហាផ្ទៃ (ផ្នែកស៊ីវិល និងនគរបាល) ក្រសួងសុខាភិបាល ក្រសួងផែនការ និងតម្រូវការរបស់អង្គការក្រៅរដ្ឋាភិបាលត្រូវបានបង្កើត ដើម្បីកំណត់អាទិភាព និងត្រួតពិនិត្យលើដំណើរការរីកចំរើនជាមូលដ្ឋានរបស់ CRVS។

ស្ថិតិអត្រានុកូលដ្ឋាន គឺវិស័យអាទិភាពមួយទៀត ដែលបន្សល់ទុកនូវការមិនបានប្រើប្រាស់យូរហើយ និងដោយមានការចូលរួមពីវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការ អត្ថប្រយោជន៍នៃស្ថិតិអត្រានុកូលដ្ឋានដែលអាចជឿទុកចិត្ត ដែលបង្កើតចេញពីទិន្នន័យអត្រានុកូលដ្ឋានដែលមានចិរភាព និងទាន់ពេលវេលាសម្រាប់រៀបចំគោល-នយោបាយសុខុមាលភាពសាធារណៈ និងការបែងចែកធនធានអាចត្រូវបានបង្កើតឡើង។ ស្ថិតិអត្រានុកូលដ្ឋាន គឺជាសមិទ្ធផលដ៏មានតម្លៃនៃហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធអត្រានុកូលដ្ឋានដែលបង្កើតឡើង។ ជាមួយនឹងការវិនិយោគបន្ថែមលើស្ថិតិអត្រានុកូលដ្ឋានអាចត្រួសត្រាយផ្លូវសម្រាប់រៀបចំគោលនយោបាយផ្អែកលើភស្តុតាង និងការត្រួតពិនិត្យកាន់តែទៀងទាត់លើនិន្នាការខាងប្រជាសាស្ត្រលើគ្រប់វិស័យ។

ជាចុងក្រោយ ការផ្តោតជាខ្លាំង គឺពឹងផ្អែកទៅលើការអភិវឌ្ឍន៍សមត្ថភាពដាក់កូដ ICD នៅកម្ពុជា ក្រសួងសុខាភិបាលបានចាប់ផ្តើមបោះជំហានមួយចំនួនក្នុងទិសដៅនេះកាលពីពេលកន្លងមក ក៏ប៉ុន្តែកំពុងឈានទៅមុខដោយយន្តការកាន់តែលឿនផ្អែកលើកូដស្តង់ដា ICD និងនីតិវិធីតម្រូវឱ្យបង្កើតឡើងនៅថ្នាក់ជាតិ។
សមាភាគទាំង៥ក្នុងប្រព័ន្ធ CRVS នឹងផ្តល់អត្ថប្រយោជន៍តាមរយៈទស្សនៈកិច្ចសិក្សាធ្វើឡើងដោយសមាជិកមកពី

ស្ថាប័នពាក់ព័ន្ធទាំងអស់។ នេះនឹងអនុញ្ញាតសម្រាប់ជាភស្តុតាងដំបូងនៃមុខងារដំណើរការគ្រប់ទិដ្ឋភាពទាំងអស់នៃប្រព័ន្ធដែលបង្កើតឡើងដោយរលូន។ មេរៀនបទពិសោធន៍អាចត្រូវបានចែករំលែក និងដំណោះស្រាយថ្មីៗ បានបង្កើតឡើងដោយប្រទេសនានាក្នុងតំបន់ត្រូវបានកែលម្អឱ្យសមស្របនឹងបរិបទកម្ពុជា។

សរុបសេចក្តីមក វាអាចបញ្ជាក់ជាវិជ្ជមានថាការអនុវត្តក្របខណ្ឌវាយតម្លៃរបស់ WHO គឺជាការចាំបាច់សម្រាប់ជំរុញឱ្យមានការរីកចំរើននៃប្រព័ន្ធ CRVS។ ទោះបីជានាពេលបច្ចុប្បន្ន ដំណើរការប្រព័ន្ធ CRVS ទទួលបាននូវការពេញចិត្តជាមធ្យមក្តី ការវាយតម្លៃគឺជាឧបករណ៍ក្នុងការធ្វើឱ្យប្រសើរឡើងនូវចំណេះដឹងរបស់អ្នកពាក់ព័ន្ធថាតើដំណើរការប្រព័ន្ធធ្វើឡើងយ៉ាងដូចម្តេច និងកំណត់ពីចំណុចខ្សោយដែលកើតមានក្នុងប្រព័ន្ធ។ ក្របខណ្ឌវាយតម្លៃគឺធានាដល់ការរៀបចំអនុសាសន៍មួយចំនួនធំ និងលក្ខណៈទូលំទូលាយសម្រាប់ធ្វើឱ្យប្រសើរឡើង និងដំណើរការធានាដល់ការចូលរួមរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការវាយតម្លៃ ហើយតាមរយៈនេះ បង្កើតឱ្យមានភាពជាម្ចាស់នៃរបកគំហើញ នេះនឹងជួយសម្រួលដល់ការពន្លឿននៃការអនុវត្តអនុសាសន៍ចម្បង និងនាំឆ្ពោះឱ្យការងារស្ថិតិអត្រានុកូលដ្ឋាននៅកម្ពុជាកាន់តែមានភាពប្រសើរឡើង។

## ទិសដៅអនុវត្ត (ជំហានបន្ទាប់)

ជាការចាំបាច់ក្នុងការគូសបញ្ជាក់នៅក្នុងដំណាក់កាលនេះ ដើម្បីលើកឡើងពីភាពជាម្ចាស់របស់ប្រទេសគឺជាឆ្អឹងខ្នងនៃរាល់គម្រោងអន្តរាគមន៍ជោគជ័យទាំងអស់។ ភ្នាក់ងាររដ្ឋាភិបាលផ្សេងៗដែលពាក់ព័ន្ធក្នុងប្រព័ន្ធ CRVS នៅកម្ពុជា និងដើរតួនាទីស្នូលក្នុងការដឹកនាំការវាយតម្លៃ និងបន្តជាស្ថាបនិកដឹកនាំ និងជាអ្នកអនុវត្តសម្រាប់ជំហានបន្ទាប់។ ជាការពិតណាស់ថារដ្ឋាភិបាលនឹងដឹកនាំការរៀបចំអភិវឌ្ឍន៍ និងអនុម័តផែនការយុទ្ធសាស្ត្រជាតិ ដោយអនុវត្តតាមរយៈកម្មវិធីជាតិ និងគម្រោងជាតិដែលមានទ្រង់ទ្រាយធំ។

បន្ទាប់មកដើម្បីសម្រេចបាននូវការវាយតម្លៃនេះ ជំហានបន្ទាប់គឺមានការពាក់ព័ន្ធនឹងការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងការប្រើប្រាស់ព័ត៌មានកំណើត មរណភាព និងមូលហេតុនៃការស្លាប់នៅកម្ពុជា រួមមាន:

- **ការបង្កើតគណៈកម្មាធិការដឹកនាំជាតិមួយ:** ក្នុងការបង្កើនសមត្ថភាពរចនាសម្ព័ន្ធអភិបាលកិច្ចដឹកនាំមួយដែលផ្តល់នូវទិសដៅ ការត្រួតពិនិត្យ និងអាណត្តិច្បាស់លាស់ពាក់ព័ន្ធនឹងប្រព័ន្ធ CRVS នៅក្នុងប្រទេសកម្ពុជា។ គណៈកម្មាធិការនេះគួរមានសមាជិកដែលមន្ត្រីជាន់ខ្ពស់សំខាន់ៗ ដែលពាក់ព័ន្ធក្នុងការធ្វើសេចក្តីសម្រេចចិត្តដល់ការរៀបចំ និងអភិវឌ្ឍន៍ចក្ខុវិស័យនៃប្រព័ន្ធ CRVS ការឯកភាព និងទទួលយកចក្ខុវិស័យ និងដំណើរការនៃអនុសាសន៍របស់ខ្លួន។ គណៈកម្មាធិការត្រូវសម្របសម្រួល ពិនិត្យលើការអនុវត្ត និងត្រួតពិនិត្យវាយតម្លៃទៅលើសកម្មភាពជាមូលដ្ឋាន។
- **បង្កើតគម្រោងយុទ្ធសាស្ត្រដែលអាចជឿជាក់បាន:** ដោយផ្អែកលើមតិជាតិទូទៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តអនុសាសន៍ចម្បង។ គម្រោងគួរកំណត់ឱ្យច្បាស់ពីសកម្មភាព និងពេលវេលាក្នុងការបង្កើតដំណើរការជាក់ស្តែង ទៅលើអ្វីដែលបាននិយាយរួចហើយ។
- **ការព្រាងគម្រោងថវិកាលំអិតជាមួយតម្លៃប៉ាន់ស្មាន :** ត្រូវសមស្របជាមួយសកម្មភាពនីមួយៗដែលលើកឡើង។
- **បង្កើតឱ្យមានកិច្ចប្រជុំរវាងអ្នកពាក់ព័ន្ធចម្បង :** គោលបំណងនៃកិច្ចប្រជុំនេះ គឺការប្រមូលការឯកភាព និងគាំទ្រលើផែនការយុទ្ធសាស្ត្រជាតិ ដើម្បីធានាថាការអនុវត្តសម្រាប់ធ្វើឱ្យប្រសើរឡើងលើប្រព័ន្ធស្ថិតិអត្រានុកូលដ្ឋានបច្ចុប្បន្ន អាចនឹងត្រូវចាប់ផ្តើម។

phatz

**អនុម័តដោយ**

លោក **ស្មោក់ សំអឿន**
ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ
អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន
ក្រសួងមហាផ្ទៃ
ថ្ងៃខែឆ្នាំ: 05/05/2014

លោក **ទី យាម**
ប្រធាននាយកដ្ឋានស្ថិតិប្រជាសាស្ត្រជំរឿន និងអង្កេត
ក្រសួងផែនការ
ថ្ងៃខែឆ្នាំ: 05/05/2014

លោក **ឡូ វាសនាគិរី**
ប្រធាននាយកដ្ឋានផែនការ និងសុខាភិបាល
ក្រសួងសុខាភិបាល
ថ្ងៃខែឆ្នាំ: 05/05/2014

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

**នាយកដ្ឋានរដ្ឋបាលទូទៅ**

**សិក្ខាសាលា**

**ស្តីពី**

**ការវាយតម្លៃប្រព័ន្ធចុះបញ្ជីអត្រានុកូលដ្ឋាន និងស្ថិតិអត្រានុកូលដ្ឋាន**

**នៅកម្ពុជា**

ខេត្តព្រះសីហនុ ថ្ងៃទី ០៩ ដល់ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៣

១.សមាសភាគអ្នកចូលរួម

ក.ថ្នាក់ជាតិ

- តំណាងមកពីក្រសួងមហាផ្ទៃ ១០ រូប
- តំណាងមកពីក្រសួងសុខាភិបាល ០៣ រូប
- តំណាងមកពីក្រសួងផែនការ ០៣ រូប
- តំណាងមកពីអគ្គស្នងការនគរបាលជាតិ ០២ រូប
- ដៃគូអភិវឌ្ឍន៍ ១០ រូប

ខ. ថ្នាក់ខេត្ត ( ព្រះសីហនុ កណ្តាល ព្រៃវែង និងខេត្តកំពង់ចាម )

- នាយករងរដ្ឋបាលសាលាខេត្ត ០១ រូប
- ប្រធានការិយាល័យស្ថិតិ និងអត្រានុកូលដ្ឋានសាលាខេត្ត ០១ រូប
- តំណាងមន្ទីរសុខាភិបាល ០១ រូប
- តំណាងមន្ទីរពេទ្យបង្អែកខេត្ត ០១ រូប



phak

គ. ថ្នាក់ក្រុង ស្រុក

- អភិបាលរងស្រុកទទួលបន្ទុកការងារអត្រានុកូលដ្ឋាន ០១ រូប
- ប្រធានការិយាល័យរដ្ឋបាលហិរញ្ញវត្ថុ ០១ រូប
- តំណាងការិយាល័យព័ត៌មានសុខាភិបាលក្នុងស្រុកប្រតិបត្តិ ០១ រូប

ឃ. ថ្នាក់ឃុំ សង្កាត់

- មេឃុំ ឬចៅសង្កាត់ ០១ រូប
- ស្មៀនឃុំ ឬសង្កាត់ ០១ រូប

២.កម្មវិធីប្រជុំ

| ថ្ងៃទី១ ៖ ថ្ងៃច័ន្ទ ទី០៩ ខែកញ្ញា ឆ្នាំ២០១៣ | | |
|---|---|---|
| ពេលវេលា | សកម្មភាព | អ្នកទទួលខុសត្រូវ |
| ០៧:៣០-០៨:១៥ | ចុះបញ្ជីវត្តមាន | ក្រុមការងារ ក្រសួងមហាផ្ទៃ |
| ០៨:១៥-០៩:០០ | មតិស្វាគមន៍ និងបើកកិច្ចប្រជុំ | -តំណាងមកពីអង្គការ WHO និងក្រសួងមហាផ្ទៃ |
| ០៩:០០-១០:០០ | សារៈសំខាន់នៃប្រព័ន្ធ CRVS | ក្រុមការងារក្រសួងមហាផ្ទៃ និងសុខាភិបាល |
| ១០:០០:១០:២០ | សម្រាកអាហារសម្រន់ | |
| ១០:២០-១១:០០ | ទិដ្ឋភាពទូទៅនៃប្រព័ន្ធ CRVS | ក្រុមការងារក្រសួងមហាផ្ទៃ |
| ១១:០០-១២:០០ | ដំណើរវាយតម្លៃប្រព័ន្ធ CRVS : ទិដ្ឋភាពទូទៅ | ទីប្រឹក្សា WHO |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| សមាសភាគ ក ៖ មូលដ្ឋានច្បាប់ និងធនធានសម្រាប់ **CRVS** | | |
| ១៤:០០-១៤:៣០ | ទិដ្ឋភាពទូទៅ | ទីប្រឹក្សា WHO |
| សមាសភាគ ខ ៖ ការអនុវត្តក្នុងការចុះបញ្ជី ការគ្របដណ្តប់ និងភាពពេញលេញ | | |
| ១៤:៣០-១៥:០០ | ទិដ្ឋភាពទូទៅ | ទីប្រឹក្សា WHO |

phur

| | | |
|---|---|---|
| សមាសភាគ គ៖ សំបុត្រមរណភាព និងមូលហេតុនៃការស្លាប់ | | |
| ១៥:០០-១៥:៣០ | ទិដ្ឋភាពទូទៅ | ទីប្រឹក្សា WHO |
| **១៥:៣០-១៥:៥០** | សម្រាកអាហារសម្រន់ | |
| សមាសភាគ ឃ ៖ ការអនុវត្តពាក់ព័ន្ធការចុះលេខកូដតាមចំណាត់ថ្នាក់ជំងឺអន្តរជាតិ **ICD** | | |
| ១៥:៥០-១៦:២០ | ទិដ្ឋភាពទូទៅ | ទីប្រឹក្សា WHO |
| ១៦:២០-១៧:០០ | ការពិភាក្សាក្រុម | សម្របសម្រួលដោយក្រសួងមហាផ្ទៃ |
| ថ្ងៃទី២ ៖ ថ្ងៃអង្គារ៍ ទី១០ ខែកញ្ញា ឆ្នាំ២០១៣ | | |
| ០៨:០០-០៨:៣០ | សង្ខេបថ្ងៃទី១ | ក្រុមការងារ **MoI/MoH** |
| សមាសភាគ ង ៖ការប្រើប្រាស់ និងការត្រួតពិនិត្យគុណភាពទិន្នន័យ | | |
| ០៨:៣០-០៩:០០ | ទិដ្ឋភាពទូទៅ | ទីប្រឹក្សា **WHO** |
| ០៩:០០-១០:០០ | ការវាយតម្លៃរហ័សពីប្រព័ន្ធ**CRVS:** ដោយប្រើប្រាស់ឧបករណ៍របស់ **WHO/UQ Tool** | ទីប្រឹក្សា **WHO** |
| ១០:០០-១០:២០ | សម្រាកអាហារសម្រន់ | |
| ១០:២០-១២:០០ | ការពិភាក្សាក្រុមតូចៗ៖ វាយតម្លៃលើសមាសភាគជាក់លាក់មួយ (ស្ថានការបច្ចុប្បន្ន កត្តារាំងស្ទះ និងសកម្មភាពធ្វើឱ្យប្រសើរឡើង) ។ ដោយបែងចែកជាបួនក្រុមតូច១ដូចខាងក្រោម ៖<br>១. ក្រុមទី១ សម្រាប់សមាសភាគ ក<br>២. ក្រុមទី២ សម្រាប់សមាសភាគ ខ<br>៣. ក្រុមទី៣ សម្រាប់សមាសភាគ គ និង ឃ<br>៤. ក្រុមទី៤ សម្រាប់សមាសភាគ ង | អ្នកចូលរួមទាំងអស់ដែលស្ថិតក្នុងក្រុមរបស់ខ្លួន |
| **១២:០០-១៤:០០** | សម្រាកអាហាថ្ងៃត្រង់ | |
| ១៤:០០-១៥:៣០ | ការពិភាក្សាក្រុមតូចៗ៖ វាយតម្លៃលើសមាភាគជាក់លាក់មួយ (ស្ថានការបច្ចុប្បន្ន កត្តារាំងស្ទះ និងសកម្មភាពធ្វើឱ្យប្រសើរឡើង) ។ ដោយបែងចែកជាបួនក្រុមតូច១ដូចខាងក្រោម ៖<br>១. ក្រុមទី១ សម្រាប់សមាសភាគ ក | អ្នកចូលរួមទាំងអស់ដែលស្ថិតក្នុងក្រុមរបស់ខ្លួន |

 phak

| | | |
|---|---|---|
| | ២. ក្រុមទី២ សម្រាប់សមាសភាគ ខ<br>៣. ក្រុមទី៣ សម្រាប់សមាសភាគ គ និង ឃ<br>៤. ក្រុមទី៤ សម្រាប់សមាសភាគ ង | |
| **១៥:៣០-១៦:០០** | សម្រាកអាហារសម្រន់ | |
| ១៦:០០-១៧:០០ | ក្រុមតូចៗបន្តការពិភាក្សា | សមាជិកក្រុម |
| ថ្ងៃទី៣ ៖ ថ្ងៃពុធ ទី១១ ខែកញ្ញា ឆ្នាំ២០១៣ | | |
| ០៨:០០-១០:០០ | ការពិភាក្សាក្រុមតូចៗ ៖ វាយតម្លៃលើសមាភាគជាក់លាក់មួយ (ស្ថានការបច្ចុប្បន្ន កត្តារាំងស្ទះ និងសកម្មភាពធ្វើឱ្យប្រសើរឡើង) ។ ដោយបែងចែកជាបួនក្រុមតូចៗដូចខាងក្រោម ៖<br>១. ក្រុមទី១ សម្រាប់សមាសភាគ ក<br>២. ក្រុមទី២ សម្រាប់សមាសភាគ ខ<br>៣. ក្រុមទី៣ សម្រាប់សមាសភាគ គ និង ឃ<br>៤. ក្រុមទី៤ សម្រាប់សមាសភាគ ង | អ្នកចូលរួមទាំងអស់ដែលស្ថិតក្នុងក្រុមរបស់ខ្លួន |
| ១០:០០-១០:៣០ | សម្រាកអាហារសម្រន់ | |
| ១០:៣០-១២:០០ | ក្រុមពិភាក្សាតូចៗធ្វើសេចក្តីសង្ខេបពីចំណុចដែលរកឃើញ និងស្នើឡើងនូវសកម្មភាពធ្វើឱ្យប្រសើរឡើង | តំណាងក្រុម |
| **១២:០០-១៤:០០** | សម្រាកអាហាថ្ងៃត្រង់ | |
| ១៤:០០-១៥:០០ | ក្រុមតូចៗធ្វើបទបង្ហាញពីអ្វីដែលរកឃើញពីការវាយតម្លៃ | អ្នកចូលរួមទាំងអស់ |
| ១៥:០០-១៥:៣០ | សម្រាកអាហារសម្រន់ | |
| ១៥:៣០-១៧:០០ | ពីការវាយតម្លៃទៅជាផែនការយុទ្ធសាស្ត្រសម្រាប់ធ្វើឱ្យប្រសើរឡើង។ ធ្វើសេចក្តីសរុប និងជំហានបន្ទាប់នេះគឺជាការធ្វើបញ្ចប់សិក្ខាសាលានេះ។ ពិធីបិទត្រូវធ្វើឡើងដោយតំណាងមកពីក្រសួងសុខាភិបាល និងតំណាងអង្គការ **WHO** | ទីប្រឹក្សា **WHO** តំណាងពីក្រសួង **MoI, MoH** និង **WHO** |

## ឧបសម្ព័ន្ធ២

## សំបុត្របញ្ជាក់កំណើត






## ឧបសម្ព័ន្ធ៣

## សំបុត្រមរណភាព




